Public Disclosure Authorized
Public Disclosure Authorized
Public Disclosure Authorized
Public Disclosure Authorized

# បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា




## ការអភិវឌ្ឍសេដ្ឋកិច្ចនាពេលថ្មីៗ និងទស្សនវិស័យ

### អត្ថបទជម្រើស

**វិនិយោគលើអនាគតកម្ពុជា ៖**

សុខភាព និងអាហារូបត្ថម្ភសម្រាប់វ័យកុមារ

**ខែ ឧសភា ឆ្នាំ ២០១៩**

ក្រុមធនាគារពិភពលោក

# បច្ចុប្បន្នភាព សេដ្ឋកិច្ច កម្ពុជា

ខែ ឧសភា ឆ្នាំ ២០១៩

## ការអភិវឌ្ឍសេដ្ឋកិច្ចនាពេលថ្មីៗ និងទស្សនវិស័យ

ក្រុមធនាគារពិភពលោក



# មាតិកា


**សេចក្តីថ្លែងអំណរគុណ** ........ ១
**អក្សរកាត់** ........ ២
**សេចក្តីសង្ខេប** ........ ៣
**ការអភិវឌ្ឍសេដ្ឋកិច្ចថ្មីៗ និងទស្សនៈវិស័យ** ........ ៩
**ការអភិវឌ្ឍថ្មីៗ** ........ ៩
សេដ្ឋកិច្ចកម្ពុជានៅតែដំណើរការល្អជាងការរំពឹងទុកកាល ពីឆ្នាំមុន ........ ៩
ការនាំចេញសំខាន់ៗបានកើនឡើង ........ ៩
កំណើនយ៉ាងលឿននៃការវិនិយោគលើទំនិញធ្វើដំណើរបានជួយជំរុញការនាំចេញ ........ ១០
ទំនុកចិត្តប្រកបដោយសុទិដ្ឋិនិយមរបស់វិនិយោគិន បានជួយដល់កំណើនលឿនក្នុងវិស័យសំណង់ ........ ១០
តម្រូវការក្នុងស្រុកមានភាពរឹងមាំ ........ ១១
ឱនភាពគណនីចរន្តទទួលបានហិរញ្ញប្បទានទាំងស្រុងពីលំហូរចូលនៃការវិនិយោគផ្ទាល់ពីបរទេស ........ ១១
លំហូរចូលនៃការវិនិយោគផ្ទាល់ពីបរទេស ជួយរក្សាសកម្មភាពសំណង់ឲ្យរស់រវើក ........ ១១
ចំនួនវិនិយោគិនចិនបានកើនដល់ជាង 2 លាននាក់ទៅហើយ (ដែលនេះជាគោលដៅកំណត់សម្រាប់ឆ្នាំ 2020) ........ ១២
ភ្ញៀវទេសចរចិនជិតមួយភាគបួន ចូលមកកម្ពុជាដើម្បីធ្វើជំនួញ ........ ១២
ភ្ញៀវទេសចរតែ 5 ភាគរយ នៃចំនួនភ្ញៀវដែលចូលមកប្រទេសវៀតណាម និងភ្ញៀវ 13.5 ភាគរយនៃចំនួនភ្ញៀវដែលចូលមកប្រទេសថៃ បានបន្តដំណើរទេសចរណ៍មកកាន់ប្រទេសកម្ពុជា ........ ១៣
លក្ខខណ្ឌអាកាសធាតុមិនសូវអំណោយផលដល់ការធ្វើកសិកម្ម ........ ១៤
សហភាពអឺរ៉ុបបានដាក់វិធានការការពារលើអង្ករនាំចូលពីកម្ពុជា និងមីយ៉ាន់ម៉ា ........ ១៤
ការកាត់បន្ថយភាពក្រីក្រនៅតែបន្ត ប៉ុន្តែក្រុមមនុស្សចំនួន 40 ភាគរយដែលនៅផ្នែកខាងក្រោមបំផុត កំពុងមានការលំបាកជាងមុន ........ ១៥
អតិផរណាថយចុះបន្តិច ដោយសារតែការធ្លាក់ចុះតម្លៃប្រេងឥន្ធនៈជួយប៉ះប៉ូវការឡើងថ្លៃម្ហូបអាហារ ........ ១៦
លំហូរនៃការវិនិយោគទុនផ្ទាល់ពីបរទេសជួយដល់ប្រាក់បញ្ញើជារូបិយប័ណ្ណបរទេស ........ ១៧
មានការផ្លាស់ប្តូរនៃការផ្តល់ឥណទានក្នុងស្រុកទៅផ្តល់ហិរញ្ញប្បទានដល់វិស័យសេវា ........ ១៨
កំណើននាពេលថ្មីៗនៃលំហូរការវិនិយោគផ្ទាល់ពីបរទេសជួយទ្រទ្រង់កំណើនការសាងសង់ ........ ១៨
ប្រាក់ចំណូលត្រូវបានប៉ាន់ស្មានថាមានអត្រាខ្ពស់ថ្មីមួយនៅឆ្នាំ 2018 ........ ១៩
យុទ្ធសាស្ត្រប្រមូលប្រាក់ចំណូលថ្មីមានគោលដៅធ្វើទំនើបកម្មរដ្ឋបាល ........ ១៩
ប្រាក់បៀវត្សរ៍ក្នុងវិស័យសាធារណៈត្រូវបានប៉ាន់ស្មានថាមានចំនួន 8.6 ភាគរយនៃ ផសស នៅឆ្នាំ 2018 ........ ២០
ការវិភាគនិរន្តរភាពបំណុលឆ្នាំ 2018 ដោយធនាគារពិភពលោក/មូលនិធិរូបិយវត្ថុអន្តរជាតិ បង្ហាញពីវិបត្តិបំណុលទាបនៅកម្ពុជា ........ ២១
ចិនជាអ្នកផ្តល់ឥណទានធំជាងគេ ដែលមានចំនួន 50 ភាគរយនៃបំណុលសរុបរបស់កម្ពុជា ........ ២១
ថវិកាឆ្នាំ 2019 បង្ហាញពីពង្រឹងសារពើពន្ធរបស់អាជ្ញាធរកម្ពុជា ........ ២១
ចំណាយលើប្រាក់បៀវត្សរ៍នៅឆ្នាំ 2019 ត្រូវបានប៉ាន់ស្មានថាមានចំនួន 7.6 ភាគរយនៃ ផសស ........ ២២
កញ្ចប់ថវិកាឆ្នាំ ២០១៩ បានបង្កើនចំណែកថវិកាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិចំនួន 30 ភាគរយ ........ ២២
**ទស្សនៈវិស័យ** ........ ២២
ដោយសារដំណើរការនាំចេញល្អជាងការរំពឹងទុក ទស្សនៈវិស័យកំណើនត្រូវបានកែសម្រួលឡើងវិញ ដោយធៀបនឹងការព្យាករពីមុន ........ ២២
**ហានិភ័យ** ........ ២៣
កម្ពុជាពឹងផ្អែកកាន់តែខ្លាំងលើប្រទេសចិនក្នុងរក្សាបានការវិនិយោគទុនផ្ទាល់ពីបរទេស និងកំណើនភ្ញៀវទេសចរ ........ ២៣
ភាពមិនប្រាកដប្រជាកាន់តែខ្លាំងផ្នែកពាណិជ្ជកម្មបានបង្កើនហានិភ័យកាន់តែខ្ពស់ ........ ២៦
ការវិភាគការប្រែប្រួលតម្លៃផលិតផលនាំចេញ គឺ សម្លៀកបំពាក់ ស្បែកជើង អង្ករ និងកង់ ជួយកំណត់ទំហំផលប៉ះពាល់នៃការព្យួរ EBA ........ ២៦
ប្រសិនបើមានការព្យួរ EBA ទំហំប៉ាន់ស្មាននៃការថយចុះការនាំចេញផលិតផលសម្លៀកបំពាក់ជាអតិបរមាទៅកាន់ទីផ្សារសហភាពអឺរ៉ុបគឺ 10.4 ភាគរយ ........ ២៧
ទំហំប៉ាន់ស្មាននៃការថយចុះការនាំចេញស្បែកជើងទៅកាន់ទីផ្សារសហភាពអឺរ៉ុបគឺ 25.2 ភាគរយ ........ ២៧
ការកាត់បន្ថយចំណាយលើផលិតកម្ម និងការនាំចេញ អាចជួយសម្រាលផលប៉ះពាល់នៃការព្យួរ EBA បាន ........ ២៨
ការកាត់បន្ថយភាពងាយរងគ្រោះផ្នែកម៉ាក្រូសេដ្ឋកិច្ចគឺជាការចាំបាច់បំផុត ........ ៣០
**អត្ថបទជម្រើស ៖ វិនិយោគលើអនាគតរបស់កម្ពុជា៖ សុខភាព និងអាហារូបត្ថម្ភសម្រាប់វ័យកុមារភាព** ........ 33
**១.សេចក្តីផ្តើម** ........ ៣៣
**២.មូលធនមនុស្ស និងការរួមចំណែកនៃមូលធនមនុស្សដល់ការអភិវឌ្ឍសេដ្ឋកិច្ចរបស់កម្ពុជា** ........ ៣៣
**៣.ស្ថានភាពសុខភាព និងអាហារូបត្ថម្ភរបស់កុមារនៅកម្ពុជា** ........ ៣៧
**៤.កត្តាជំរុញឲ្យមានបញ្ហាកង្វះអាហារូបត្ថម្ភលើកុមារ** ........ ៣៩
ក.ការប្រព្រឹត្តិដែលធ្វើឲ្យមានកង្វះអាហារូបត្ថម្ភ ........ ៣៩
ខ.កង្វះលទ្ធភាពអាចរកបាន និងលទ្ធភាពទិញអាហារមានសារជាតិចិញ្ចឹម ........ ៤១
គ.ចំណុចខ្វះខាតក្នុងការផ្តល់សេវាអាហារូបត្ថម្ភដោយវិស័យសុខាភិបាល ........ ៤២
ឃ.កង្វះលទ្ធភាពទទួលបានសេវាកម្មទឹកស្អាត និងអនាម័យល្អប្រសើរ ........ ៤៣
ង.បញ្ហាធនធានសម្រាប់ស្ត្រីក្នុងការទទួលបានការថែទាំល្អបំផុត ........ ៤៤
ច.កង្វះខាតការទទួលបាន និងប្រសិទ្ធភាពនៃការចំណាយសាធារណៈលើសុខភាព និងអាហារូបត្ថម្ភសម្រាប់កុមារ ........ ៤៦
**៥.ជម្រើសគោលនយោបាយ** ........ ៤៩
**ឧបសម្ព័ន្ធ ១ ៖ ការប្រែប្រួលតម្លៃសម្លៀកបំពាក់ ស្បែកជើង និងអង្ករក្នុងពិភពលោក** ........ ៥២
**ឧបសម្ព័ន្ធ ២ ៖ ប្រទេសកម្ពុជា៖ សូចនាករសំខាន់ៗ** ........ ៥៣
**ឯកសារយោង** ........ ៥៤

# សេចក្ដីថ្លែងអំណរគុណ

ការរៀបចំរបាយការណ៍បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជាឆ្នាំ ២០១៩ នៅកម្ពុជា (CEU) ស្ថិតក្រោមការដឹកនាំរបស់លោក លី សូដេត ដោយមានការរួមចំណែកពីលោក Miguel Eduardo Sánchez Martín លោក ភឹម រុនស៊ីណារិទ្ធ លោកស្រី គី លីនណា លោក តុង គឹមស៊ុន Anne Marie Provo, លោក Somil Nagpal, and លោកស្រីEkaterine Vashakmadze។ លោក ប៊ូ សារឿន និងលោកស្រី អាត សុជាតិ ជួយលើការងារផ្សព្វផ្សាយតាមសារព័ត៌មាន ភស្តុភារ ការបង្ហាញតាមគេហទំព័រ និងពិធីផ្សព្វផ្សាយរបាយការណ៍នេះ។

ក្រុមការងារនេះបានធ្វើការក្រោមការដឹកនាំរួមរបស់ លោក Deepak Mishra។ ក្រុមការងារសូមថ្លែងអំណរគុណចំពោះដំបូន្មាន និងយោបល់របស់លោកស្រី Ellen A. Goldstein និង លោកស្រី Inguna Dobraja។ សហសេវិករបស់ធនាគារពិភពលោកមួយចំនួន ដែលរួមមាន លោក Andrew Mason, លោក Ergys Islamaj និង លោកស្រី Francesca de Nicola បានផ្ដល់យោបល់លើសេចក្ដីព្រាងចុងក្រោយនៃរបាយការណ៍នេះ។

ក្រុមការងារសូមអរគុណដល់អាជ្ញាធរកម្ពុជា ជាពិសេសក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជា សម្រាប់កិច្ចសហប្រតិបត្តិការ និងការគាំទ្ររបស់ពួកគាត់។ របាយការណ៍ក៏ទទួលបានផលប្រយោជន៍ពីដំបូន្មាន យោបល់ និងទស្សនៈរបស់អ្នកពាក់ព័ន្ធនានានៅក្នុងប្រទេសកម្ពុជា រួមទាំងអ្នកអាន និងអ្នករិះគន់ផងដែរ។

របាយការណ៍នេះត្រូវបានផលិតពីរដងក្នុងមួយឆ្នាំ ផ្ដល់ព័ត៌មានបច្ចុប្បន្នភាពស្ដីពីការអភិវឌ្ឍម៉ាក្រូសេដ្ឋកិច្ចនៅកម្ពុជា។ ឯកសារនេះត្រូវបានចែកចាយ និងពិភាក្សាយ៉ាងទូលំទូលាយ រួមទាំងក្នុងចំណោមអាជ្ញាធរកម្ពុជា ដៃគូអភិវឌ្ឍន៍ វិស័យឯកជន ស្ថាប័នស្រាវជ្រាវ និងផ្ដល់យោបល់ អង្គការសង្គមស៊ីវិល និងសាកលវិទ្យាល័យនានា។

សម្រាប់ព័ត៌មានអំពីធនាគារពិភពលោក និងសកម្មភាពរបស់ធនាគារពិភពលោកនៅកម្ពុជា សូមមើលគេហទំព័ររបស់យើងតាមរយៈអាស័យដ្ឋាន: www.worldbank.org/cambodia ។

ដើម្បីបញ្ចូលនៅក្នុងបញ្ជីចែកចាយអ៊ីមែលរបស់របាយការណ៍នេះ និងការបោះពុម្ពផ្សាយដែលពាក់ព័ន្ធសូមទាក់ទង លោកស្រី អាត សុជាតិ (sath@worldbank.org)។ សម្រាប់សំណួរអំពីខ្លឹមសារនៃអត្ថបទនេះសូមទាក់ទងលោក ប៊ូ សារឿន (sbou@ world bank.org) ។

របកគំហើញ ការបកស្រាយ និងសេចក្ដីសន្និដ្ឋានដែលមានក្នុងរបាយការណ៍នេះ មិនប្រាកដថាឆ្លុះបញ្ចាំងពីទស្សនៈរបស់នាយកប្រតិបត្តិនៃធនាគារពិភពលោក ឬរដ្ឋាភិបាលដែលធនាគារពិភពលោកតំណាងនោះទេ។ ធនាគារពិភពលោកមិនធានាទៅលើភាពត្រឹមត្រូវនៃទិន្នន័យដែលមានក្នុងឯកសារនេះទេ។ ព្រំប្រទល់ ពណ៌ កំណត់សម្គាល់ និងព័ត៌មានផ្សេងៗដែលមាននៅលើផែនទីនៅក្នុងឯកសារនេះមិនបង្ហាញពីការវាយតម្លៃរបស់ធនាគារពិភពលោកពាក់ព័ន្ធនឹងស្ថានភាពច្បាប់ដែនដី ឬការអនុម័ត ឬការទទួលយកព្រំប្រទល់ទាំងនោះទេ។

# អក្សរកាត់

| | |
|---|---|
| AFTA | កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន |
| ASEAN | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ |
| CEU | បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា |
| CDHS | ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា |
| CR | ប្រាក់រៀល |
| C/S | ឃុំសង្កាត់ |
| EAP | អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក |
| EBA | អ្វីគ្រប់យ៉ាង លើកលែងតែអាវុធ |
| EC | គណៈកម្មការអឺរ៉ុប |
| EMDEs | ទីផ្សារដែលងើបឡើង និងប្រទេសកំពុងអភិវឌ្ឍន៍ |
| EU | សហភាពអឺរ៉ុប |
| FCD | ប្រាក់បញ្ញើរូបិយវត្ថុបរទេស |
| FDI | វិនិយោគដោយផ្ទាល់ពីបរទេស |
| GDP | ផលិតផលក្នុងស្រុកសរុប |
| GVC | សង្វាក់តម្លៃសកល |
| HIV/AIDS | មេរោគអេដស៍/ជំងឺអេដស៍ |
| HS | ប្រព័ន្ធសម្រួល |
| IDP | គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម |
| IMF | មូលនិធិរូបិយវត្ថុអន្តរជាតិ |
| LPCO | ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា |
| MCH | សុខភាពមាតា និងកុមារ |
| MDI | ស្ថាប័នមីក្រូហិរញ្ញវត្ថុ |
| MEF | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| MFI | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ |
| MOEYS | ក្រសួងអប់រំ យុវជន និងកីឡា |
| MOH | ក្រសួងសុខាភិបាល |
| MOP | ក្រសួងផែនការ |
| NCD | វិញ្ញាបនប័ត្របញ្ញើដែលអាចជួញដូរបាន |
| NIS | វិទ្យាស្ថានជាតិស្ថិតិ |
| NPL | កម្ចីមិនដំណើរការ |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| RMS | យុទ្ធសាស្ត្រប្រមូលចំណូល |
| RS | យុទ្ធសាស្ត្រចតុកោណ |
| SDR | សិទ្ធិដកប្រាក់ពិសេស |
| SME | សហគ្រាសធុនតូច និងមធ្យម |
| TVET | ការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ |
| TEU | ឯកតាដែលមានចំនួនស្មើនឹងម្ភៃហ្វូត |
| UK | ចក្រភពអង់គ្លេស |
| UNAIDS | កម្មវិធីរួមរបស់សហប្រជាជាតិស្តីពីជំងឺអេដស៍ |
| UNICEF | មូលនិធិសហប្រជាជាតិសម្រាប់កុមារ |
| US | សហរដ្ឋអាមេរិក |
| US$ | ដុល្លារអាមេរិក |
| VAT | ពន្ធលើតម្លៃបន្ថែម |
| WBG | ក្រុមធនាគារពិភពលោក |
| WHO | អង្គការសុខភាពពិភពលោក |
| YTD | ពីដើមឆ្នាំដល់បច្ចុប្បន្ន |
| y/y or yoy | ធៀបនឹងឆ្នាំមុន |



# សេចក្ដីសង្ខេប

## ការអភិវឌ្ឍថ្មីៗ

**ការប៉ាន់ស្មានបឋមបង្ហាញពីកំណើនពិតដែលមានកម្រិតខ្ពស់ក្នុងរយៈពេលបួនឆ្នាំកន្លងទៅនេះ គឺ កំណើន 7.5 ភាគរយនៅឆ្នាំ 2018 ធៀបនឹងអត្រាកំណើន 7.0 ភាគរយនៅឆ្នាំ 2017។** ដោយសារតែកំណើនយ៉ាងឆាប់រហ័សនៃការនាំចេញ និងតម្រូវការក្នុងស្រុកខ្ពស់ សេដ្ឋកិច្ចកម្ពុជាដំណើរការទៅល្អជាងការរំពឹងទុក។ ការនាំចេញកើនឡើងយ៉ាងឆាប់រហ័ស ដោយសារតែការកើនឡើងនៃតម្រូវការខាងក្រៅ ជាពិសេសការនាំចេញទៅទីផ្សារសហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប មានភាពរឹងមាំ។ ការនាំចេញសម្លៀកបំពាក់ និងស្បែកជើងដែលមានចំនួនជាងពីរភាគបីនៃការនាំចេញទំនិញសរុប កើនឡើងពី 8.3 ភាគរយនៅឆ្នាំ 2017 ដល់ 17.6 ភាគរយនៅឆ្នាំ 2018។ នេះជាអត្រាកំណើនខ្ពស់បំផុតក្នុងរយៈពេល 5 ឆ្នាំកន្លងមក។

**ទំនុកចិត្តប្រកបដោយសុទិដ្ឋិនិយមរបស់អ្នកប្រើប្រាស់ទំនិញបានធ្វើឲ្យមានកំណើននៃការនាំចូល។** ការនាំចូលយានយន្ត និងដែកសំណង់ ដែលបង្ហាញពីតម្រូវការនៃការប្រើប្រាស់ និងការសាងសង់ក្នុងស្រុក បានកើនឡើង ក្នុងអត្រា 50 ភាគរយសម្រាប់យានយន្ត និង 48 ភាគរយសម្រាប់ដែកសំណង់។

**ឱនភាពគណនីចរន្តកើនឡើងពី 9.7 ភាគរយនៃ ផសស នៅឆ្នាំ 2017 មកត្រឹម 10.4 ភាគរយនៃ ផសស នៅឆ្នាំ 2018 ប៉ុន្តែ នៅតែទទួលហិរញ្ញប្បទានទាំងស្រុងពីការវិនិយោគផ្ទាល់ពីបរទេស។** តាមការប៉ាន់ស្មាន ការវិនិយោគផ្ទាល់ពីបរទេសបានឈានដល់បរិមាណខ្ពស់បំផុតគឺជាង 3 ពាន់លានដុល្លា ឬស្មើនឹង 13.4 ភាគរយនៃ ផសស នៅឆ្នាំ 2018។ កំណើនការនាំចេញ និងលំហូរចូលនៃការវិនិយោគផ្ទាល់ពីបរទេស បានរួមចំណែកដល់កំណើនបន្ថែមនៃទុនបម្រុងអន្តរជាតិសរុប ដែលឡើងដល់ 10.1 ពាន់លានដុល្លានៅឆ្នាំ 2018 ឬស្មើនឹងការនាំចូលនាពេលអនាគតប្រហែល 6 ខែ។

**បីភាគបួននៃលំហូរចូលនៃការវិនិយោគផ្ទាល់ពីបរទេស (ដែលបានអនុម័ត) មានប្រភពពីប្រទេសចិន។** ក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ការវិនិយោគរបស់ចិនមានកំណើនខ្ពស់ ដោយវិនិយោគជាសំខាន់លើវិស័យសំណង់ (ហេដ្ឋារចនាសម្ព័ន្ធ តំបន់ពាណិជ្ជកម្ម និងលំនៅដ្ឋាន) ទេសចរណ៍ និងវិស័យកម្មន្តសាល និងកសិកម្ម (ក្នុងបរិមាណតិចជាងគេ)។ ទីក្រុងតំបន់ឆ្នេរសមុទ្រនៃក្រុងព្រះសីហនុបានប្រែក្លាយទៅជាតំបន់សំខាន់នៃការរីកចម្រើនយ៉ាងរហ័សនៃសំណង់នាពេលបច្ចុប្បន្ន។

**ទំនុកចិត្តលើប្រព័ន្ធធនាគារប្រសើរឡើងធ្វើឲ្យមានកំណើនប្រាក់បញ្ញើជារូបិយប័ណ្ណបរទេស។** ប្រាក់បញ្ញើជារូបិយប័ណ្ណបរទេសកើន 26.5 ភាគរយក្នុងឆ្នាំ 2018 កើនពី 23.6 ភាគរយក្នុងឆ្នាំ 2017។ ការផ្ដល់ឥណទានដោយធនាគារដល់វិស័យឯកជន បានកើនឡើងជាងមុនបន្តិច ដូចពីមុនដែរដោយកើនពី 19.6ភាគរយនៅឆ្នាំ 2017 ដល់ 24.2 ភាគរយនៅឆ្នាំ 2018។ ការផ្ដល់កម្ចី

ដោយធនាគារដល់វិស័យសំណង់ និងអចលនទ្រព្យ នៅតែបន្តជំរុញកំណើនឥណទានក្នុងស្រុក ដោយរួមចំណែកប្រមាណ 40 ភាគរយនៃកំណើនឥណទាន។ វិស័យបន្ទាប់ដែលទទួលបានកម្ចីពីធនាគារគឺ វិស័យលក់ដុំ និងលក់រាយដែលមានចំនួនមួយភាគប្រាំនៃកំណើនកម្ចីក្នុងស្រុក។

**អតិផរណាបានថយចុះបន្តិច ទ្រទ្រង់មួយផ្នែកដោយស្ថិរភាពនៃអត្រាប្តូរប្រាក់។** ការថយតម្លៃប្រេងឥន្ទនៈចាប់តាំងពីត្រីមាសទីបួនក្នុងឆ្នាំ 2018 បានជួយប៉ះប៉ូវកំណើនថ្លៃម្ហូបអាហារ។ ជាលទ្ធផល អតិផរណាបានថយចុះមកត្រឹម 1.6 ភាគរយគិតត្រឹមខែ ធ្នូ ឆ្នាំ 2018 ចុះពី 2.2 ភាគរយនៅឆ្នាំ 2017។ ប្រាក់រៀលដែលធៀបនឹងប្រាក់ដុល្លាអាមេរិក នៅតែមានតម្លៃថេរក្នុងអត្រា 4018 រៀលក្នុងមួយដុល្លានៅបំណាច់ឆ្នាំ 2018 ធៀបនឹងអត្រា 4037 រៀលក្នុងមួយដុល្លា នៅឆ្នាំ 2017។

**ការឡើងប្រាក់បៀវត្សរ៍លឿនក្នុងវិស័យសាធារណៈបានដាក់សម្ពាធលើស្ថានភាពសារពើពន្ធ ប៉ុន្តែដំណើរការបង្កើតប្រាក់ចំណូលដែលល្អជាងការរំពឹងទុក បានទប់ទល់នឹងឱនភាពសារពើពន្ធ។** បើទោះជាមានការបង្កើនប្រាក់បៀវត្សរ៍នៅឆ្នាំ 2018 រួមនឹងការបង្កើនការចំណាយមូលធនពីពេលដំបូងដែលទទួលបានហិរញ្ញប្បទានក្នុងស្រុកក្តី ក៏ឱនភាពរួមនៅតែអាចទប់ទល់បាន។ ឱនភាព (រួមទាំងជំនួយឥតសំណង) ត្រូវបានប៉ាន់ស្មានថាកើនដល់ 1.9 ភាគរយនៃ ផសស នៅឆ្នាំ 2018 កើនពី 1.6 ភាគរយនៃ ផសស នៅឆ្នាំ 2017។

យោងតាមការវិភាគទៅលើនិរន្តរភាពបំណុលដោយធនាគារពិភពលោក និងមូលនិធិរូបិយវត្ថុអន្តរជាតិ នៅឆ្នាំ 2018 **កម្រិតវិបត្តិបំណុលរបស់កម្ពុជានៅតែមានកម្រិតទាប** ដោយសារតែបំណុលសាធារណៈ គឺជាប្រភេទបំណុលសម្បទាន និងកម្រិតឱនភាពទាបកន្លងមក។ ក្រោយការរក្សាបានដំណើរការសារពើពន្ធល្អប្រសើរជាច្រើនឆ្នាំ អាជ្ញាធរកម្ពុជាបានបង្កើនប្រាក់បញ្ញើរដ្ឋាភិបាលរហូតដល់ 14.9 ភាគរយនៃ ផសស នៅឆ្នាំ 2018។

## ទស្សនៈវិស័យ

**ក្រោយពីមានកំណើនខ្ពស់ចំនួន 7.5 ភាគរយនៅឆ្នាំ 2018 សេដ្ឋកិច្ចកម្ពុជាត្រូវបានរំពឹងថា នឹងមានកំណើនរយៈពេលវែងប្រមាណ 7 ភាគរយ។** ដោយសារតែការនាំចេញថយចុះបន្តិចទន្ទឹមនឹងការថយចុះនៃតម្រូវការសកល (សូមមើលប្រអប់ 1) កំណើនពិតត្រូវបានព្យាករថានឹងថយមកត្រឹម 7 ភាគរយនៅឆ្នាំ 2019។ កំណើនសេដ្ឋកិច្ចរឹងមាំត្រូវបានរំពឹងថានឹងបន្តជួយកាត់បន្ថយភាពក្រីក្រ។

**ទោះជាយ៉ាងណាក៏ដោយ ទស្សនៈវិស័យរយៈពេលវែងអាស្រ័យលើលទ្ធភាពរបស់កម្ពុជា ក្នុងការស្រូបយកកំណើនលំហូរចូលនៃការវិនិយោគផ្ទាល់ពីបរទេសប្រកបដោយផលិតភាព និងជំរុញការវិនិយោគក្នុងស្រុក។** ក្នុងគោលបំណងនេះ ជាការសំខាន់ត្រូវមានតម្លៃថាមពល និងការចំណាយផ្នែកភស្តុភារមានកម្រិតទាប មានកម្លាំងពលកម្មជំនាញ និងមានការភ្ជាប់ទំនាក់ទំនងល្អទៅនឹងសង្វាក់ផ្គត់ផ្គង់ ដើម្បីរក្សាភាពប្រកួតប្រជែងបាន។ ក្នុងរយៈពេលខ្លី ចាំបាច់ត្រូវបំពេញការខ្វះខាតជំនាញ ហើយត្រូវចាប់ផ្តើមដោះស្រាយបញ្ហាខ្វះខាតមូលធនមនុស្ស ដើម្បីគាំទ្រដល់បំណងប្រាថ្នារយៈពេលវែងរបស់កម្ពុជា។ សូមអានការលើកឡើងលម្អិតស្តីពីការខ្វះខាតជំនាញ និងមូលធនមនុស្សនៅកម្ពុជានៅក្នុងផ្នែកអត្ថបទជម្រើស។

## ហានិភ័យ និងបញ្ហាប្រឈម

**ភាពមិនប្រាកដប្រជាកាន់តែខ្លាំងបានបង្កើនហានិភ័យ។** នៅខែកុម្ភៈ សហភាពអឺរ៉ុបបានចាប់ផ្តើមដំណើរការមួយដែលអាចឈានទៅដល់ការព្យួរការអនុគ្រោះពន្ធសម្រាប់កម្ពុជាតាមរយៈប្រព័ន្ធ “អ្វីគ្រប់យ៉ាង លើកលែងតែអាវុធ (EBA)” ជាបណ្តោះអាសន្ន។ ទីផ្សារសហភាពអឺរ៉ុបបច្ចុប្បន្នមានទំហំជាងមួយភាគបីនៃការនាំចេញសំខាន់ៗរបស់កម្ពុជា ភាគច្រើនជាសម្លៀកបំពាក់ ស្បែកជើង និងកង់។ ដូច្នេះ ការបាត់បង់ការអនុគ្រោះពន្ធនេះ ដែលបច្ចុប្បន្នផ្តល់ការអនុគ្រោះពន្ធដល់កម្ពុជាក្នុងការនាំចូលទៅកាន់សហភាពអឺរ៉ុប អាចនឹងធ្វើឲ្យការនាំចេញ និងកំណើនថមថយល្បឿន។

**ការថយចុះសន្ទុះសេដ្ឋកិច្ចក្នុងប្រទេសចិន និងកំណើនហួសកម្រិតនៃវិស័យហិរញ្ញវត្ថុ បានបង្កជាហានិភ័យដល់ទស្សនៈវិស័យកំណើនរបស់កម្ពុជា។** ដោយសារតែកម្ពុជាពឹងផ្អែកយ៉ាងខ្លាំងលើលំហូរចូលនៃមូលធន និងភ្ញៀវទេសចរពីប្រទេសចិន ការថយចុះសន្ទុះសេដ្ឋកិច្ចចិន អាចប៉ះពាល់ដល់ទស្សនៈវិស័យកំណើន។ ការអូសបន្លាយនៃការរីកឡើងនៃកំណើនឥណទានក្នុងស្រុក ដែលភាគច្រើនជាមូលហេតុនៅពីក្រោយកំណើនវិស័យសំណង់ និងអចលនទ្រព្យ ដែលធ្វើឲ្យវិស័យហិរញ្ញវត្ថុរីកហួសកម្រិត។ ដោយសារតែវិស័យសំណង់ និងអចលនទ្រព្យងាយប្រឈមនឹងវដ្តនៃការឡើងចុះ ការកើនឡើងនៃឥណទានក្នុងស្រុកសម្រាប់វិស័យសំណង់ បានបង្កើនភាពងាយរងគ្រោះនៃវិស័យហិរញ្ញវត្ថុ។

**ត្រូវចាត់វិធានការជាបន្ទាន់ដើម្បីសម្រាលផលប៉ះពាល់អវិជ្ជមានដែលអាចកើតឡើងដោយសារការព្យួរប្រព័ន្ធអនុគ្រោះពន្ធ។** យោងតាមរបាយការណ៍ស្តីពីការធ្វើធុរៈកិច្ច ឆ្នាំ 2019[9] កម្ពុជាឈរនៅលំដាប់ទី 185 ក្នុងចំណោមប្រទេស 190 ពាក់ព័ន្ធនឹងភាពងាយស្រួលក្នុងការចាប់ផ្តើមអាជីវកម្ម។ ចំណាយលើការធ្វើពាណិជ្ជកម្មមានឥទ្ធិពលយ៉ាងខ្លាំងទៅលើរចនាសម្ព័ន្ធនៃការនាំចេញរបស់កម្ពុជា និងដំណើរការរបស់ក្រុមហ៊ុននាំចេញ។ ការរួមចំណែកនៃ

---

[៩] សូមមើលរបាយការណ៍ស្តីពីការធ្វើធុរៈកិច្ច ឆ្នាំ 2019, ធនាគារពិភពលោក។

ការដឹកជញ្ជូន និងភស្តុភារចំពោះតម្លៃបន្ថែមសរុបនៃការនាំចេញកើនដល់ 14 ភាគរយ ដែលជាអត្រាខ្ពស់ជាងពីរដង បើធៀបនឹងប្រទេសថៃ និងខ្ពស់ជាង 3.5 ដង បើធៀបនឹងម៉ាឡេស៊ី ឬវៀតណាម។ ទំនាក់ទំនងទៅនឹងសង្វាក់ផ្គត់ផ្គង់រវាងក្រុមហ៊ុនបរទេស និងក្រុមហ៊ុនក្នុងស្រុក មានភាពទន់ខ្សោយ។ ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ ចាំបាច់ត្រូវធ្វើកំណែទម្រង់ផ្នែករចនាសម្ព័ន្ធ ជាពិសេសកំណែទម្រង់ដែលអាចជួយកែលម្អបរិយាកាសវិនិយោគ និងកាត់បន្ថយការចំណាយលើការធ្វើធុរៈកិច្ច រួមទាំងការផ្ដល់តម្លៃថាមពលដែលមានភាពប្រកួតប្រជែង និងការកាត់បន្ថយចំណាយលើផ្នែកភស្តុភារ។ សូមមើលប្រអប់ 2 ស្ដីពីវិធានការរបស់អាជ្ញាធរកម្ពុជាក្នុងការកាត់បន្ថយតម្លៃ និងសម្របសម្រួលពាណិជ្ជកម្ម កាលពីខែ មីនា ឆ្នាំ 2019។

**អាជ្ញាធរកម្ពុជាអាចពិចារណាចាត់វិធានការប្រុងប្រយ័ត្នផ្នែកម៉ាក្រូសេដ្ឋកិច្ចបន្ថែមទៀត ដូចជា ការរឹតត្បិតការវិនិយោគរបស់វិស័យធនាគារទៅលើវិស័យសំណង់ និងអចលនទ្រព្យ។** ដោយសារតែកំណើនឥណទានក្នុងស្រុករយៈពេលយូរ ដែលជាមូលដ្ឋាននៃកំណើនលឿននៃវិស័យសំណង់ និងអចលនទ្រព្យ ការពង្រឹងសមត្ថភាពត្រួតពិនិត្យ និងការត្រៀមខ្លួនទប់ទល់នឹងវិបត្តិក្នុងវិស័យហិរញ្ញវត្ថុ គឺជាវិធានការសំខាន់ដំបូងមួយ។ កំណើនលំហូរចូលនៃការវិនិយោគផ្ទាល់ពីបរទេសបានជួយរក្សាកំណើនខ្លាំងរយៈពេលយូរនៃការសាងសង់ ក៏ដូចជាលាក់បាំងភាពងាយរងគ្រោះរបស់វិស័យហិរញ្ញវត្ថុ ក្រោយពីមានកំណើននៃការផ្ដល់កម្ចីយ៉ាងឆាប់រហ័សក្នុងរយៈពេលជាច្រើនឆ្នាំកន្លងមក។ យ៉ាងណាក៏ដោយ លំហូរចូលនៃមូលធនយ៉ាងច្រើនពីបរទេសបែបនេះប្រហែលជាគ្មាននិរន្តរភាពទេ ជាពិសេសក្នុងបរិបទនៃកំណើនភាពមិនប្រាកដប្រជាក្នុងពិភពលោក និងការថយចុះសន្ទុះសេដ្ឋកិច្ចក្នុងប្រទេសចិន។ ការថយចុះនៃការវិនិយោគពីបរទេសលើការសាងសង់ អាចធ្វើឲ្យថ្លៃធ្លាក់ចុះ និងបង្ហាញពីភាពងាយរងគ្រោះរបស់វិស័យហិរញ្ញវត្ថុ។



# ទិដ្ឋភាពរួមស្ដីពីការអភិវឌ្ឍថ្មីៗនៅកម្ពុជា

### កំណើនពិតកើនឡើងយ៉ាងលឿន...

កំណើនពិត (ភាគរយ)




### ...ដោយសារតែកំណើនការនាំចេញសំខាន់ៗ និង

ការនាំចេញសម្លៀកបំពាក់ (ការប្រែប្រួលជាភាគរយធៀបនឹងឆ្នាំមុន)




### ...វិស័យសំណង់កើនឡើង...

(ការប្រែប្រួលគិតជាតម្លៃបច្ចុប្បន្ន)




### ...គាំទ្រដោយកំណើនវិនិយោគខ្ពស់បំផុត

(ភាគរយនៃ ផសស)




### ការផ្ដល់កម្ចីដល់វិស័យសំណង់កើនឡើង

(ការរួមចំណែកដល់កំណើនឥណទានក្នុងទម្រង់ជាការផ្ដល់កម្ចីដល់វិស័យសំណង់ និងអចលនទ្រព្យ, ភាគរយពិន្ទុ)




### កំណើនសារពើពន្ធដោយសារតែតម្រូវការក្នុងស្រុក

ចំណាយទូទៅរបស់រដ្ឋាភិបាល (ភាគរយនៃ ផសស)




*ប្រភព* ៖ អាជ្ញាធរកម្ពុជា និងការប៉ាន់ស្មាន និងការព្យាកររបស់បុគ្គលិកធនាគារពិភពលោក

*សម្គាល់* ៖ e=ការប៉ាន់ស្មាន, pre=បឋម





ផ្នែកទី 1

# ការអភិវឌ្ឍសេដ្ឋកិច្ចថ្មីៗ និងទស្សនៈវិស័យ

# ការអភិវឌ្ឍសេដ្ឋកិច្ចថ្មីៗ និងទស្សនៈវិស័យ

## ការអភិវឌ្ឍថ្មីៗ

### សេដ្ឋកិច្ចកម្ពុជានៅតែដំណើរការល្អជាងការរំពឹងទុកកាល ពីឆ្នាំមុន

**ការប៉ាន់ស្មានបឋមបង្ហាញពីកំណើនពិតដែលមានកម្រិតខ្ពស់ក្នុងរយៈពេលបួនឆ្នាំកន្លងមក គឺ 7.5 ភាគរយនៅឆ្នាំ 2018** ធៀបនឹង 7.0 ភាគរយនៅឆ្នាំ 2017 (រូប 1)។ កំណើននេះត្រូវបានជំរុញដោយការនាំចេញ និងតម្រូវការក្នុងស្រុកដ៏ខ្លាំងក្លា។ កម្ពុជាជាប្រទេសមួយនៅអាស៊ីបូព៌ាដែលមានកំណើនលឿនបំផុត និងស្ថិតក្នុងចំណោមប្រទេសមួយចំនួនតូចដែលមានដំណើរការសេដ្ឋកិច្ចល្អជាងការព្យាករនៅឆ្នាំ 2018 (ដូចគ្នានឹងប្រទេសម៉ុងហ្គោលី និងវៀតណាម)។

**កំណើនក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍នៅអាស៊ីបូព៌ា និងប៉ាស៊ីហ្វិក នៅតែរឹងមាំ បើទោះជាស្ថានភាពនៅសកលលោកមិនល្អក្តី។** ភាពរឹងមាំនៃកំណើនក្នុងតំបន់នេះត្រូវបានជំរុញដោយតម្រូវការក្នុងស្រុកខ្ពស់ ដោយទទួលបានការគាំទ្រពីសម្ពាធអតិផរណាតិចតួច ទីផ្សារការងាររឹងមាំ និងក្នុងករណីមួយចំនួនមានការជំរុញផ្នែកសារពើពន្ធ។ ភាពក្រីក្របន្តថយចុះ នៅពេលមានកំណើនរឹងមាំ ដែលទទួលការគាំទ្រដោយការនាំចេញ បើទោះជាការនាំចេញនេះមានសន្ទុះយឺតជាងពេលកន្លងទៅក្តី។ យ៉ាងណាក៏ដោយ នៅតែមានភាពរាំងស្ទះនៃសេដ្ឋកិច្ចសកលដោយសារតែភាពតានតឹងផ្នែកពាណិជ្ជកម្មដែលមិនទាន់បានដោះស្រាយ និងការថយចុះបន្តិចនៃតម្រូវការជាសកល។

### ការនាំចេញសំខាន់ៗបានកើនឡើង

**ការនាំចេញដែលជាផ្នែកសំខាន់នៃសេដ្ឋកិច្ចកម្ពុជា កើនឡើងដោយសារតម្រូវការខាងក្រៅមានភាពរឹងមាំ។** ការនាំចេញសម្លៀកបំពាក់ និងស្បែកជើង បានកើនឡើង 17.7 ភាគរយនៅឆ្នាំ 2018 ដោយកើនពី 8.4 ភាគរយនៅឆ្នាំ 2017 (រូប 2)។ កម្ពុជាទទួលបានអត្ថប្រយោជន៍ពីកំណើនដ៏រឹងមាំនៅប្រទេសដែលមានប្រាក់ចំណូលខ្ពស់ ជាពិសេសសហរដ្ឋអាមេរិក។ សហរដ្ឋអាមេរិកមានកំណើនរហូតដល់ 2.9 ភាគរយនៅឆ្នាំ 2018 ដែលទទួលបានការគាំទ្រដោយការជំរុញផ្នែកសារពើពន្ធ និងវិធានការកាត់បន្ថយនិយតកម្ម[២]។ ពាណិជ្ជកម្មលក់រាយរបស់សហរដ្ឋអាមេរិកក៏បានកើនឡើងដែរកាលពីឆ្នាំមុន[៣]។ ពាណិជ្ជកម្មលក់រាយ (មិនរាប់បញ្ចូលរថយន្ត) កើនពី 4.5 ភាគរយនៅឆ្នាំ 2017 ដល់ 5.3 ភាគរយនៅឆ្នាំ 2018[៤]។ ការពង្រីកប្រព័ន្ធអនុគ្រោះពន្ធពាណិជ្ជ

**រូប 1 ៖ កត្តារួមចំណែកដល់កំណើនពិត** (ភាគរយពិន្ទុ)




*ប្រភព* ៖ អាជ្ញាធរកម្ពុជា

*សម្គាល់* ៖ pre=ការប៉ាន់ស្មានបឋម

**រូប 2 ៖ ការនាំចេញសម្លៀកបំពាក់ និងស្បែកជើងទៅកាន់ប្រទេសគោលដៅធំៗ** (លានដុល្លារអាមេរិក)




*ប្រភព* ៖ អាជ្ញាធរកម្ពុជា

*សម្គាល់* ៖ RHS= ខាងស្តាំ

[២] បច្ចុប្បន្នភាពសេដ្ឋកិច្ចអាស៊ីបូព៌ា និងប៉ាស៊ីហ្វិក ខែ មេសា ឆ្នាំ 2019 ៖ ធនាគារពិភពលោក។

[៣] ទស្សនៈវិស័យគោលនយោបាយរូបិយវត្ថុ ឆ្នាំ 2019 ៖ សុន្ទរកថារបស់លោកអនុប្រធាន Richard H ក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធប្រាក់បម្រុងរបស់សហព័ន្ធ ៖ https://www.federalreserve.gov/newsevents/speech/clarida20190110a.htm

[៤] ពាណិជ្ជកម្មលក់រាយ មិនរាប់បញ្ចូលរថយន្ត ៖ ការលក់សរុបនៅសហរដ្ឋអាមេរិកដោយមិនគិតតាមរដូវ ការិយាល័យជំរឿនសហរដ្ឋអាមេរិក។

កម្មឲ្យគ្របដណ្តប់លើទំនិញទាក់ទងនឹងការធ្វើដំណើរ ដែលបានអនុវត្តតាំងពីខែ មិថុនា ឆ្នាំ 2016 បានជួយជំរុញការនាំចេញរបស់កម្ពុជាទៅទីផ្សារសហរដ្ឋអាមេរិក។ ការនាំចេញរបស់កម្ពុជាទៅកាន់សហភាពអឺរ៉ុបបានកើនឡើងបន្តិច ទោះបីជាកំណើនទៅតំបន់ចាយប្រាក់អឺរ៉ូថយចុះបន្តិចមកត្រឹម 1.8 ភាគរយនៅឆ្នាំ ២០១៨ នៅខណៈពេលដែលតម្រូវការខាងក្រៅមានការអន់ថយ។ ដោយសារតែភាពរឹងមាំនៃការលក់រាយនៅសហរដ្ឋអាមេរិក ការនាំចេញរបស់កម្ពុជាកើនឡើងចំនួន 29 ភាគរយនៅឆ្នាំ 2018 កើនពី 4.6 ភាគរយនៅឆ្នាំ 2017 (រូប 3)។ ការនាំចេញរបស់កម្ពុជាទៅកាន់សហភាពអឺរ៉ុបកើនឡើងចំនួន 12.9 ភាគរយនៅឆ្នាំ 2018 កើនពី 9.3 ភាគរយនៅឆ្នាំ 2017។ ចំណែកនៃការនាំចេញសម្លៀកបំពាក់ និងស្បែកជើងរបស់កម្ពុជា ទៅក្នុងទីផ្សារសហរដ្ឋអាមេរិកកើនដល់ 29.7 ភាគរយនៅឆ្នាំ 2018 កើនពីចំណែក 25.0 ភាគរយនៅឆ្នាំ 2017 រីឯចំណែកនៃការនាំចេញផលិតផលទាំងនេះទៅក្នុងទីផ្សារសហភាពអឺរ៉ុបបានថយចុះមកត្រឹម 39.1 ភាគរយ ថយពីចំណែក 46.0 ភាគរយក្នុងអំឡុងពេលដូចគ្នានេះ។

### កំណើនយ៉ាងលឿននៃការវិនិយោគលើទំនិញធ្វើដំណើរបានជួយជំរុញការនាំចេញ

**ការកើនឡើងយ៉ាងឆាប់រហ័សនៃគម្រោងវិនិយោគលើការផលិតទំនិញធ្វើដំណើរ ត្រូវបានសម្រួលដោយការអនុគ្រោះពន្ធទៅទីផ្សារសហរដ្ឋអាមេរិក។** កាលពីថ្ងៃទី 30 ខែ មិថុនា ឆ្នាំ 2016 ការិយាល័យតំណាងពាណិជ្ជកម្មសហរដ្ឋអាមេរិក (USTR) បានប្រកាសពីការពង្រីកប្រព័ន្ធអនុគ្រោះពន្ធពាណិជ្ជកម្មដ៏សំខាន់មួយ។ ក្រោមកំណែទម្រង់ថ្មីៗលើប្រព័ន្ធអនុគ្រោះពន្ធរបស់សហរដ្ឋអាមេរិក (GSP) កម្ពុជា និងប្រទេសដែលមានការអភិវឌ្ឍតិចតួចបំផុតផ្សេងៗទៀតដែលជាអ្នកទទួលផល ដែលផលិតទំនិញធ្វើដំណើរដូចជា វ៉ាលី កាបូបស្ពាយ កាបូបដៃ និងកាបូបលុយ នឹងអាចនាំចេញផលិតផលទាំងនេះទៅកាន់សហរដ្ឋអាមេរិកដោយមិនបង់ពន្ធ[៥]។ ការពង្រីកប្រព័ន្ធអនុគ្រោះពន្ធ GSP របស់សហរដ្ឋអាមេរិកបានជំរុញការវិនិយោគលើគម្រោងដែលទទួលបានហិរញ្ញប្បទានពីការវិនិយោគផ្ទាល់ពីបរទេស (FDI) (បានអនុម័តរួច) ក្នុងវិស័យទំនិញធ្វើដំណើរ ដែលមានទឹកប្រាក់រហូតដល់ 120 លានដុល្លានៅរយៈពេលពីរខែដំបូងក្នុងឆ្នាំ 2019 កើនពីទំហំទឹកប្រាក់ 50 លានដុល្លានៅឆ្នាំ 2018។

### ទំនុកចិត្តប្រកបដោយសុទិដ្ឋិនិយមរបស់វិនិយោគិន បានជួយដល់កំណើនលឿនក្នុងវិស័យសំណង់

**ការវិនិយោគដោយវិស័យឯកជន ដែលភាគច្រើនបានមកពីលំហូរចូលនៃការវិនិយោគផ្ទាល់ពីបរទេស មានកំណើនខ្ពស់ថ្មី។** នៅឆ្នាំ 2018 តម្លៃនៃគម្រោងវិនិយោគដែលបានអនុម័ត កើនឡើងដល់ 5.8 ពាន់លានដុល្លា ក្នុងនោះ គម្រោងវិនិយោគពីរភាគបីគឺជាការវិនិយោគផ្ទាល់ពីបរទេស។ លំហូរចូលនៃការវិនិយោគផ្ទាល់ពីបរទេស កើនឡើងចំនួន 24.8 ភាគរយ ក្នុងទំហំទឹកប្រាក់ច្រើនមិនធ្លាប់មានពីមុន គឺជាង 3 ពាន់លានដុល្លា ឬស្មើនឹង 13.4 ភាគរយនៃ ផសស នៅឆ្នាំ 2018 (រូប 4)[៦]។ ក្នុងវិស័យ

**រូប 3 ៖ ការលក់រាយនៅសហរដ្ឋអាមេរិក និងការនាំចេញរបស់កម្ពុជាទៅកាន់សហរដ្ឋអាមេរិក**




*ប្រភព* ៖ អាជ្ញាធរកម្ពុជា
*សម្គាល់* ៖ ទីផ្សារសហភាពអឺរ៉ុបនៅឆ្នាំ 2014 រួមទាំងចក្រភពអង់គ្លេស
*RHS*= ខាងស្តាំ

**រូប 4 ៖ ការវិនិយោគផ្ទាល់ពីបរទេស** (ភាគរយនៃ ផសស)




*ប្រភព* ៖ អាជ្ញាធរកម្ពុជា និងការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក

[៥] ព័ត៌មានបន្ថែមមាននៅ https://kh.usembassy.gov/duty-free-access-travel-goods-made-cambodia/
[៦] របាយការណ៍ប្រចាំឆ្នាំ 2018 របស់ធនាគារជាតិនៃកម្ពុជា។

ផលិត មានការវិនិយោគដោយវិស័យឯកជនលើវិស័យសំណង់ អចលនទ្រព្យ និងទេសចរណ៍ដែលសរុបមានចំនួន 60 ភាគរយ នៃការវិនិយោគសរុប (ដែលបានអនុម័ត) នៅឆ្នាំ 2018។ ដោយមានការគាំទ្រដោយកំណើនលឿនក្នុងវិស័យសំណង់ សកម្មភាពក្នុងវិស័យកម្មន្តសាលសំខាន់ៗ ដូចជា សម្ភារសំណង់ គ្រឿងសង្ហារឹម លោហៈធាតុ និងផលិតផលផ្លាស្ទិក កំពុងកើនឡើងយ៉ាងឆាប់រហ័ស។

វិស័យកម្មន្តសាលក្រៅពីកាត់ដេរ មានចំនួនប្រមាណ 20 ភាគរយនៃការវិនិយោគសរុប។ បីភាគបួននៃការវិនិយោគផ្ទាល់ពីបរទេស (ដែលបានអនុម័តរួច) មានប្រភពពីប្រទេសចិន។

### តម្រូវការក្នុងស្រុកមានភាពរឹងមាំ

**ការកើនឡើងយ៉ាងឆាប់រហ័សនៃតម្រូវការក្នុងស្រុកធ្វើឲ្យមានកំណើននៃការនាំចូល។** ការកើនឡើងនៃតម្រូវការប្រើប្រាស់ទំនិញបានជំរុញការទិញទំនិញជាប់ធន់សម្រាប់ប្រើប្រាស់ក្នុងគ្រួសារ។ ការនាំចូលយានយន្ត កើនឡើងចំនួន 52.9 ភាគរយនៅឆ្នាំ 2018 (រូប 5) បន្ទាប់មក ឥន្ធនៈគឺជាផលិតផលនាំចូលច្រើនជាងគេទីពីរ។ ការនាំចូលប្រេងសាំង និងប្រេងម៉ាស៊ូត ក៏កើនឡើង 30 ភាគរយដែរ។ ជាការបង្ហាញពីកំណើនឆាប់រហ័សនៃវិស័យសំណង់ ការនាំចូលដែកថែប បរិក្ខារធ្វើឲ្យត្រជាក់ និងសម្ភារសំណង់ផ្សេងទៀត បានកើនឡើងខ្ពស់ចំនួន 47.6 ភាគរយ សម្រាប់ដែកថែប 54.3 ភាគរយ សម្រាប់បរិក្ខាត្រជាក់ និង 73.0 ភាគរយសម្រាប់សម្ភារសំណង់ (រូប 6)។ ដូចបានពិភាក្សាខាងលើ សកម្មភាពសាងសង់ភាគច្រើនប្រមូលផ្តុំនៅរាជធានីភ្នំពេញ និងក្រុងព្រះសីហនុ។ សេដ្ឋកិច្ចកម្ពុជាពឹងផ្អែកលើវិស័យសំណង់ ដែលបង្កើនហានិភ័យពាក់ព័ន្ធនឹងកំណើននៃវិស័យសំណង់។

### ឱនភាពគណនីចរន្តទទួលបានហិរញ្ញប្បទានទាំងស្រុងពីលំហូរចូលនៃការវិនិយោគផ្ទាល់ពីបរទេស

**ឱនភាពគណនីចរន្តត្រូវបានប៉ាន់ស្មានថាបានកើនឡើងដល់ 10.4 ភាគរយនៃ ផសស នៅឆ្នាំ 2018 កើនពីអត្រា 9.7 ភាគរយនៃ ផសស នៅឆ្នាំ 2017។** ស្ថានភាពល្អប្រសើរនៃការនាំចេញបានជួយប៉ះប៉ូវកំណើនតម្រូវការនាំចូល។ នៅឆ្នាំ 2018 ការនាំចេញទំនិញត្រូវបានប៉ាន់ស្មានថាកើនដល់ 11.2 ពាន់លានដុល្លា ចំណែកការនាំចូលទំនិញបានកើនដល់ 13.8 ពាន់លានដុល្លា។ កំណើននៃសេវាសរុប ត្រូវបានជំរុញជាសំខាន់ដោយសេវាទេសចរណ៍ក្នុងវិស័យទេសចរណ៍ដែលបានកើនឡើង។ ការផ្ទេរសាច់ប្រាក់បច្ចុប្បន្នត្រូវបានគាំទ្រ ដោយបញ្ញើប្រាក់របស់កម្មករនិយោជិត (សរុប) ដែលតាមការប៉ាន់ស្មានមានចំនួន 1.0 ពាន់លានដុល្លា។ ដូច្នេះ ឱនភាពគណនីចរន្តនៅតែទទួលបានហិរញ្ញប្បទានទាំងស្រុងពីលំហូរចូលនៃការវិនិយោគផ្ទាល់ពីបរទេស។ ការនាំចេញដែលមានដំណើរការល្អជាងការរំពឹងទុក និងអត្រាខ្ពស់នៃលំហូរចូល នៃការវិនិយោគផ្ទាល់ពីបរទេស ផ្តល់លទ្ធភាពឲ្យធនាគារជាតិកើនទុនបម្រុងអន្តរជាតិកាន់តែច្រើន ដោយមានចំនួនដល់ទៅ 10.1 ពាន់លានដុល្លាត្រឹមចុងឆ្នាំ 2018 ដែលស្មើនឹងរយៈពេល 6 ខែ នៃការនាំចូល។

### លំហូរចូលនៃការវិនិយោគផ្ទាល់ពីបរទេស ជួយរក្សាសកម្មភាពសំណង់ឲ្យរស់រវើក

**នៅឆ្នាំ 2018 គម្រោងអភិវឌ្ឍន៍សំណង់ពាណិជ្ជកម្ម និងលំនៅដ្ឋានដែលបានអនុម័ត** (មិនរាប់បញ្ចូលគម្រោងធំៗដែលមានទំហំទឹកប្រាក់ចំនួន 1 ពាន់លានដុល្លាឡើងទៅ) **មានចំនួន 4.6 ពាន់លានដុល្លា** ឬស្មើនឹងកំណើន 14 ភាគរយ។ ក្រុងព្រះសីហនុដែលជាទីក្រុងឆ្នេរសមុទ្រធំជាងគេនៅកម្ពុជា បានក្លាយជាមជ្ឈមណ្ឌលសំណង់អគារខ្ពស់ថ្មីៗ និងប្រមូលផ្តុំដោយសកម្មភាពសាងសង់យ៉ាងរស់រវើក ដែលទទួលបានហិរញ្ញប្បទានភាគច្រើនពីវិនិយោគិនចិន។

**រូប 5 ៖ ការកើនឡើងនៃការនាំចូលយានយន្ត**
(ភាគរយប្រែប្រួលធៀបនឹងឆ្នាំមុន)




*ប្រភព* ៖ អាជ្ញាធរកម្ពុជា

**រូប 6 ៖ ការនាំចូលសម្ភារសំណង់ និងដែកថែប**
(ភាគរយប្រែប្រួលធៀបនឹងឆ្នាំមុន)




*ប្រភព* ៖ អាជ្ញាធរកម្ពុជា

**កំណើនដ៏លឿនបំផុតនៃចំនួនសំណង់អគារខ្ពស់ៗក្នុងទីរួមខេត្តព្រះសីហនុ ដែលមិនធ្លាប់មានពីមុន គឺនៅឆ្នាំ 2018 ដែលមានសំណង់ចំនួន 238 អាគារ ត្រូវបានអនុម័ត** កើនឡើងពី 188 អគារនៅឆ្នាំ 2017។ ចំនួនអគារកម្ពស់ចាប់ពី 5 ជាន់ឡើងទៅនៅក្រុងព្រះសីហនុ និងរាជធានីភ្នំពេញ មានចំនួន 1,217 អគារ[៧]។ ភាពទាក់ទាញកាន់តែខ្លាំងនៃតំបន់ឆ្នេរ ជាពិសេសខេត្តព្រះសីហនុ ដែលមានចំនួនភ្ញៀវទេសចរកើនឡើងដល់ 10 ភាគរយនៃចំនួនភ្ញៀវទេសចរសរុបនៅឆ្នាំ 2018 (ធៀបនឹងកំណើនត្រឹមតែ 5.5 ភាគរយនៅឆ្នាំ 2010) និងទទួលបានការគាំទ្រដោយការស្តារ និងពង្រីកព្រលានយន្តហោះអន្តរជាតិដែលនៅជិតទីរួមខេត្តនេះ បានជួយជំរុញកំណើនវិស័យសំណង់នៅទីនោះ។ នៅឆ្នាំ 2018 គម្រោងវិនិយោគដែលបានអនុម័តសរុបសម្រាប់ក្រុងព្រះសីហនុតែមួយគត់ មានទំហំទឹកប្រាក់ចំនួន 1.03 ពាន់លានដុល្លា ក្នុងនោះគម្រោងវិនិយោគ 43 ភាគរយផ្តោតលើវិស័យកម្មន្តសាល។ លើសពីនេះទៀត ដើម្បីបង្កើនទំនាក់ទំនងរវាងខេត្តព្រះសីហនុ និងក្រុងភ្នំពេញ ផ្លូវបើកបរល្បឿនលឿនមួយដែលត្រូវចំណាយទឹកប្រាក់សាងសង់ចំនួន 1.87 ពាន់លានដុល្លាក្រោមគម្រោងសាងសង់ដំណើរការ និងផ្ទេរ (BOT) កំពុងត្រូវបានសាងសង់ឡើង[៨]។

### ចំនួនវិនិយោគិនចិនបានកើនដល់ជាង 2 លាននាក់ទៅហើយ (ដែលនេះជាគោលដៅកំណត់សម្រាប់ឆ្នាំ 2020)

**កំណើនចំនួនភ្ញៀវទេសចរអន្តរជាតិនៅតែមានជាបន្តក្នុងអត្រា 10.7 ភាគរយ ធៀបនឹងឆ្នាំមុន (2018)** ដែលថយពីកំណើន 11.8 ភាគរយក្នុងឆ្នាំ 2017។ កំណើននេះគាំទ្រការកើនឡើងនៃចំនួនភ្ញៀវទេសចរចិន (រូប 7)។ ភ្ញៀវទេសចរចិនឈរនៅលំដាប់លើគេ គឺមានចំនួន 2.03 លាននាក់ ឬស្មើនឹង 32.6 ភាគរយនៃចំនួនភ្ញៀវទេសចរសរុប។ នេះមានន័យថា អាជ្ញាធរកម្ពុជាសម្រេចបានគោលដៅកំណត់មុនពីរឆ្នាំ។ ក្រោមយុទ្ធសាស្រ្ត "ត្រៀមខ្លួនរួចរាល់សម្រាប់ប្រទេសចិន" ដែលត្រូវបានអនុម័តនៅឆ្នាំ 2016 អាជ្ញាធរកម្ពុជាកំណត់គោលដៅទទួលបានចំនួនភ្ញៀវទេសចរចិនចំនួន 2 លាននាក់ ត្រឹមឆ្នាំ 2020។ ចំនួនភ្ញៀវទេសចរមកពីប្រទេសវៀតណាម មានចំនួន 12.9 ភាគរយ ឡាវ មានចំនួន 6.9 ភាគរយ និងថៃ មានចំនួន 6.2 ភាគរយនៃចំនួនភ្ញៀវទេសចរសរុប។ ការកើនឡើងនៃភ្ញៀវទេសចរចិនទាំងនោះត្រូវបានរាយការណ៍ថា ភ្ញៀវទេសចរចិនភាគច្រើនមានគោលបំណងចូលមកធ្វើជំនួញនៅកម្ពុជា។

### ភ្ញៀវទេសចរចិនជិតមួយភាគបួន ចូលមកកម្ពុជាដើម្បីធ្វើជំនួញ

**នៅឆ្នាំ 2018 សេចក្តីរាយការណ៍បង្ហាញថា ភ្ញៀវទេសចរចិនជិតមួយភាគបួន ចូលមកកម្ពុជាដើម្បីធ្វើជំនួញ** (រូប 8)។ ដោយសារតែកំណើនយ៉ាងលឿននៃការចូលមកកម្ពុជាតាមផ្លូវអាកាស គឺតាមរយៈព្រលានយន្តហោះអន្តរជាតិសំខាន់ៗ ៣ នៅភ្នំពេញ សៀមរាប និងព្រះសីហនុ កម្ពុជាទទួលបានចំនួនភ្ញៀវទេសចរជាង 10 លាននាក់ ឬស្មើនឹងកំណើន 25 ភាគរយនៅឆ្នាំ 2018 (រូប 8)។ នៅឆ្នាំ 2018 ព្រលានយន្តហោះទាំងបីទទួលបានភ្ញៀវទេសចរបរទេសជាង 4 លាននាក់ ឬស្មើនឹង 65.8 ភាគរយនៃចំនួនភ្ញៀវទេសចរអន្តរជាតិសរុប និងហោះទៅគោលដៅធ្វើដំណើរចំនួន 89 ក្នុងនោះ គោលដៅ 57 គឺប្រទេសចិន។ ក្នុងចំណោមភ្ញៀវទេសចរ 65.8 ភាគរយនេះ ព្រលានយន្តហោះអន្តរជាតិភ្នំពេញ (មានក្រុមហ៊ុនអាកាសចរណ៍ចំនួន 35 ទៅកាន់គោលដៅអន្តរជាតិ 34 ដែលក្នុងនោះ គោលដៅ 21 គឺជាប្រទេសចិន) និងព្រលានយន្តហោះអន្តរជាតិសៀមរាប (មានក្រុមហ៊ុនអាកាសចរណ៍ចំនួន 32 ទៅកាន់គោលដៅអន្តរជាតិ 46 ដែលក្នុងនោះ គោលដៅ 29 គឺជាប្រទេសចិន) ទទួលបានភ្ញៀវទេសចរ

**រូប 7 ៖ ចំនួនភ្ញៀវទេសចរមកកាន់ប្រទេសកម្ពុជា ថៃ និងវៀតណាម** (ភាគរយប្រែប្រួលធៀបនឹងឆ្នាំមុន)




*ប្រភព* ៖ អាជ្ញាធរកម្ពុជា

**រូប 8 ៖ ចំនួនភ្ញៀវទេសចរចូលមកតាមផ្លូវអាកាស និងចូលមកធ្វើជំនួញនៅកម្ពុជា** (ភាគរយប្រែប្រួលធៀបនឹងឆ្នាំមុន)




*ប្រភព* ៖ អាជ្ញាធរកម្ពុជា

*សម្គាល់* ៖ RHS=ខាងស្តាំ

---

[៧] របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ 2018 និងគោលបំណងនៃការអនុវត្តការងារឆ្នាំ 2019 ថ្ងៃទី 7 ខែ កុម្ភៈ ឆ្នាំ 2019, ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

[៨] សម្រាប់ព័ត៌មានស្តីពីផ្លូវបើកបរល្បឿនលឿនតភ្ជាប់ក្រុងភ្នំពេញ និងខេត្តព្រះសីហនុ សូមមើល http://www.mpwt.gov.kh/ kh/public-works/expressways

អន្តរជាតិចំនួន 31 ភាគរយនៃចំនួនភ្ញៀវអន្តរជាតិសរុប។ ព្រលានយន្តហោះព្រះសីហនុ (មានក្រុមហ៊ុនអាកាសចរណ៍ចំនួន 10 ទៅកាន់គោលដៅអន្តរជាតិ 9 ដែលក្នុងនោះ គោលដៅ 7 គឺជាប្រទេសចិន) ទទួលបានភ្ញៀវអន្តរជាតិ 3.8 ភាគរយដែលនៅសល់នោះ។ ព្រលានយន្តហោះទាំងបីមានជើងហោះហើរទៀងទាត់ប្រមាណ 700 ជើងហោះហើរក្នុងមួយសប្តាហ៍[៩]។

**ភ្ញៀវទេសចរតែ 5 ភាគរយ នៃចំនួនភ្ញៀវដែលចូលមកប្រទេសវៀតណាម និងភ្ញៀវ 13.5 ភាគរយនៃចំនួនភ្ញៀវដែលចូលមកប្រទេសថៃ បានបន្តដំណើរទេសចរណ៍មកកាន់ប្រទេសកម្ពុជា**

**យ៉ាងណាក៏ដោយ កម្ពុជានៅមានសក្តានុពលទេសចរណ៍ជាច្រើនដែលមិនទាន់បានទាញយកផល** ព្រោះភ្ញៀវទេសចរចូលមកប្រទេសវៀតណាមតែ 5 ភាគរយ និងភ្ញៀវទេសចរចូលមកប្រទេសថៃតែ 13.5 ភាគរយប៉ុណ្ណោះដែលបន្តដំណើរទេសចរណ៍មកកាន់ប្រទេសកម្ពុជា[១០]។ នៅឆ្នាំ 2018 ខណៈដែលកម្ពុជាទទួលបានភ្ញៀវទេសចរបរទេសចំនួន 6.2 លាននាក់ (កំណើន 10.7 ភាគរយធៀបនឹងឆ្នាំមុន) ប្រទេសថៃទទួលបានភ្ញៀវទេសចរចំនួន 38.3 លាននាក់ (កំណើន 8.2 ភាគរយធៀបនឹងឆ្នាំមុន) ចំណែកប្រទេសវៀតណាមទទួលបានភ្ញៀវទេសចរចំនួន 15.5 លាននាក់ (កំណើន 20 ភាគរយធៀបនឹងឆ្នាំមុន)។

**ការពង្រីកខ្លួនចូលក្នុងទីផ្សារដែលមានកំណើននៅប្រទេសជិតខាងរបស់កម្ពុជា អាចជាការលំបាក និងប្រហែលជាត្រូវមានការវិនិយោគកាន់តែច្រើន និងការសម្របសម្រួលកាន់តែប្រសើរ។** មានការអនុវត្តគំនិតផ្តួចផ្តើមជាច្រើនដើម្បីកែលម្អ និងពង្រីកសេវាទេសចរណ៍ ដូចជា "ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាកម្មល្អ" ស្តង់ដារអាហារតាមដងផ្លូវ ការផ្តល់សេវា Wi-Fi ដោយមិនគិតថ្លៃនៅតាមទីសាធារណៈ និងគំនិតផ្តួចផ្តើមខ្សែក្រវាត់បៃតង និងទីក្រុងឆ្លាត។ ប៉ុន្តែ ការបង្កើនការវិនិយោគក្នុងការផ្តល់ហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍សាធារណៈគ្រប់គ្រាន់ និងដំណើរការល្អប្រសើរ និងការបង្កើនកិច្ចសហប្រតិបត្តិការរវាងវិស័យពាណិជ្ជកម្ម និងវិស័យសាធារណៈ គឺជាការចាំបាច់។

**ការអភិវឌ្ឍ និងការផ្តល់ហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ ត្រូវបានមើលឃើញថាជាបុរេលក្ខខណ្ឌដើម្បីប្រែក្លាយកម្ពុជាទៅជាគោលដៅទេសចរណ៍ដ៏ទាក់ទាញ។** គោលដៅទេសចរណ៍ដ៏ទាក់ទាញត្រូវពឹងផ្អែកលើធនធានធម្មជាតិ និងហេដ្ឋារចនាសម្ព័ន្ធ សម្ភារបរិក្ខារ និងសេវានៅទីនោះ[១១]។ តួយ៉ាងដូចជា ប្រទេសវៀតណាមបានចំណាយថវិកាប្រមាណ 24 ពាន់លានដុល្លាសម្រាប់អំឡុងឆ្នាំ 2016-2020 ក្នុងនោះ កញ្ចប់ថវិការដ្ឋមានប្រមាណ 8-10 ភាគរយ។ ចំណាយទាំងនេះផ្តោតលើការកសាង និងធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ និងដឹកជញ្ជូននៅតាមខេត្តដែលសំបូរដោយកន្លែងប្រវត្តិសាស្ត្រសំខាន់ៗ ដែលទាក់ទាញភ្ញៀវទេសចរ[១២]។ ចំនួនភ្ញៀវទេសចរមកកាន់ប្រទេសវៀតណាម បានកើនឡើងយ៉ាងខ្លាំងក្នុងរយៈពេល 3 ឆ្នាំកន្លងមក ដោយមានកំណើន 56 ភាគរយ ឬស្មើនឹង 15.5 លាននាក់នៅឆ្នាំ 2018 (កើនពី 9.9 លាននាក់នៅឆ្នាំ 2016)។ នៅឆ្នាំ 2015 ប្រទេសវៀតណាមបានទាក់ទាញភ្ញៀវទេសចរចំនួន 6 លាននាក់ក្នុងមួយឆ្នាំ។

**រូប 9 ៖ ការរួមចំណែកពីទិន្នផលស្រូវវស្សាប្រចាំឆ្នាំ កើនឡើងតិចតួច** (លានតោន)




*ប្រភព* ៖ អាជ្ញាធរកម្ពុជា

**រូប 10 ៖ ការនាំចេញអង្ករមានអត្រាថេរ** (ពាន់តោន)




*ប្រភព* ៖ អាជ្ញាធរកម្ពុជា

[៩] សូមមើល https://corp.cambodia-airports.aero/

[១០] ភ្ញៀវទេសចរបរទេសចំនួន 34.7 ភាគរយមកពីប្រទេសថៃ និង 31.2 ភាគរយមកពីប្រទេសវៀតណាម បានចូលមកប្រទេសកម្ពុជា, របាយការណ៍ប្រចាំឆ្នាំ 2017 របស់ក្រសួងទេសចរណ៍។

[១១] Abdullah, S., Abdul Razak A., Jaafar M., 2014. ហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍សាធារណៈ ៖ បញ្ហាប្រឈមក្នុងសកម្មភាពអភិវឌ្ឍន៍ និងជួសជុលថែទាំ។

[១២] សេចក្តីសម្រេចលេខ 201/QD-TTg នៅថ្ងៃទី 22 ខែ មករា ឆ្នាំ 2013 អនុម័តផែនការមេស្តីពីការអភិវឌ្ឍវិស័យទេសចរណ៍វៀតណាមរហូតដល់ឆ្នាំ 2020 ដោយមានចក្ខុវិស័យឆ្ពោះទៅឆ្នាំ 2030។

### លក្ខខណ្ឌអាកាសធាតុមិនសូវអំណោយផលដល់ការធ្វើកសិកម្ម

**កាលពីឆ្នាំមុន លក្ខខណ្ឌអាកាសធាតុ គឺមិនសូវអំណោយផលឡើយ។** ការធ្វើកសិកម្មរងការប៉ះពាល់ដោយសារគ្រោះរាំងស្ងួតនៅពាក់កណ្តាលរដូវ និងគ្រោះទឹកជំនន់នៅតាមតំបន់មួយចំនួនក្នុងប្រទេស[១៣]។ យ៉ាងណាក៏ដោយ តម្លៃបន្ថែមសរុបរបស់វិស័យកសិកម្ម (តាមតម្លៃបច្ចុប្បន្ន) កើនដល់ 4.4 ភាគរយនៅឆ្នាំ 2018 ដែលមានទឹកប្រាក់ចំនួន 21,913 ពាន់លានរៀល (ឬ 22.0 ភាគរយនៃ ផសស)។ ការបង្កបង្កើនផលស្រូវ ដែលមានប្រមាណ 50 ភាគរយនៃ ផសស វិស័យកសិកម្ម បានកើនឡើង 3.5 ភាគរយ ឬសម្រេចបាន 10.8 លានតោន ដែលទាបជាងឆ្នាំ 2017 ដែលមានកំណើន 5.7 ភាគរយ (រូប 9)។ ក្នុងនោះ ទិន្នផលស្រូវប្រាំងរួមចំណែកចំនួន 2 ភាគរយពិន្ទុ ចំណែកឯទិន្នផលស្រូវវស្សារួមចំណែកចំនួន 1.5 ភាគរយពិន្ទុ។

**នៅឆ្នាំ 2018 កំណើនទិន្នផលមានចំនួន 57 ភាគរយនៃកំណើនផលស្រូវ** ចំណែកភាគរយផ្សេងៗទៀតគឺដោយសារតែការពង្រីកផ្ទៃដីដាំដុះ។ នៅឆ្នាំ 2017 93.2 ភាគរយនៃកំណើនផលស្រូវ បានមកពីការពង្រីកផ្ទៃដីដាំដុះ គួបផ្សំនឹងលក្ខខណ្ឌអាកាសធាតុល្អប្រសើរ។ ដូច្នេះ នៅឆ្នាំ 2018 កំណើនទិន្នផលបង្ហាញពីការប្រើប្រាស់ធនធានកសិកម្មបានកាន់តែល្អប្រសើរ និងមានប្រសិទ្ធភាព។ ទិន្នផលស្រូវវស្សាកើនឡើង 1.7 ភាគរយ ចំណែកទិន្នផលស្រូវប្រាំងកើនឡើង 1.0 ភាគរយ។

**ផ្ទៃដីបង្កបង្កើនផលស្រូវកើនដល់ 3.3 លានហិកតា ឬកើនឡើង 3.3 ភាគរយ ដោយសារតែកំណើនផ្ទៃដីបង្កបង្កើនផលស្រូវវស្សា។** ផ្ទៃដីបង្កបង្កើនផលស្រូវវស្សាកើនឡើងដល់ 2.74 លានហិកតានៅឆ្នាំ 2018 (ឬស្មើកំណើន 3.4 ភាគរយ) ដោយកើនឡើងពី 2.65 លានហិកតានៅឆ្នាំ 2017។ ផ្ទៃដីបង្កបង្កើនផលស្រូវប្រាំងនៅតែមានទំហំ 0.59 លានហិកតាដដែល។ ចំណុចនេះបង្ហាញពីបញ្ហាលំបាកនៃការពង្រីកប្រព័ន្ធធារាសាស្ត្រសម្រាប់ការធ្វើស្រូវក្នុងកំឡុងរដូវប្រាំង។

**ស្ថិតិផ្លូវការបង្ហាញថា អតិរេកទិន្នផលស្រូវនៅកម្ពុជាកើនដល់ 5.8 លានតោន ឬស្មើនឹងអង្ករ 3.7 លានតោន។** ប៉ុន្តែ កម្ពុជាបាននាំចេញផលលើសស្រូវអង្កររបស់ខ្លួន ភាគច្រើនក្នុងទម្រង់ជាស្រូវ ចំណែកឯ ការនាំចេញអង្ករមានចំនួន 0.6 លានតោន (ឬស្មើនឹង 16.7 នៃអតិរេកសរុប) (រូប 10)។

**ការនាំចេញអង្ករក្រអូបប្រណិតរបស់កម្ពុជាមានចំនួន 79 ភាគរយនៃការនាំចេញអង្ករសរុបនៅឆ្នាំ 2018។** ក្នុងនោះអង្ករសគ្រាប់ស្រឡូនមានចំនួន 17 ភាគរយ ហើយអង្ករសំរូបគ្រាប់ស្រឡូនមានចំនួន 4 ភាគរយ[១៤]។ អង្ករក្រអូបប្រណិតបានឈ្នះពានរង្វាន់អង្ករល្អជាងគេលើពិភពលោកជាថ្មីម្តងទៀតនៅឆ្នាំ 2018 នៅក្នុងការប្រកួតប្រជែងអង្ករល្អជាងគេបំផុតលើពិភពលោកដែល The Rice Trader[១៥] រៀបចំឡើងជារៀងរាល់ឆ្នាំ។ ចាប់តាំងពីឆ្នាំ 2009 មកអង្ករផ្កាម្លិះរបស់កម្ពុជាបានប្រកួតប្រជែងជាសកលជាពិសេសអង្ករផ្កាម្លិះថៃ ក្នុងការដណ្តើមពានរង្វាន់អង្ករល្អជាងគេលើពិភពលោក។ កន្លងមក កម្ពុជាឈ្នះពានរង្វាន់បួនដង គឺនៅឆ្នាំ 2012 2013 2014 និង 2018 ចំណែកអង្ករក្រអូបប្រណិតថៃឈ្នះពានរង្វាន់ប្រាំដង។ អង្ករសហរដ្ឋអាមេរិក និងអង្ករមីយ៉ាន់ម៉ាឈ្នះពានរង្វាន់ម្តងម្នាក់។

### សហភាពអឺរ៉ុបបានដាក់វិធានការការពារលើអង្ករនាំចូលពីកម្ពុជា និងមីយ៉ាន់ម៉ា

**គណៈកម្មការសហភាពអឺរ៉ុប (EC) បានដាក់វិធានការការពារលើអង្ករកម្ពុជា។** យោងតាមគណៈកម្មការសហភាពអឺរ៉ុប ការស៊ើបអង្កេតបានបញ្ជាក់ពីកំណើនខ្លាំងនៃការនាំចូលអង្ករស ពីកម្ពុជា និងមីយ៉ាន់ម៉ា មកកាន់សហភាពអឺរ៉ុប ដែលធ្វើឲ្យប៉ះពាល់ដល់សេដ្ឋកិច្ចរបស់អ្នកផលិតនៅអឺរ៉ុប។ ជាការឆ្លើយតបសហភាពអឺរ៉ុបបានសម្រេចយកពន្ធនាំចូលលើអង្ករ ដែលនឹងត្រូវកាត់បន្ថយបន្តិចម្តងៗក្នុងរយៈពេល 3 ឆ្នាំ។ ក្រោយការអនុម័តនៅថ្ងៃទី 18 ខែ មករា ឆ្នាំ 2019 សហភាពអឺរ៉ុបបានយកពន្ធគយឡើងវិញចំនួន 175 អឺរ៉ូក្នុងមួយតោននៅឆ្នាំទីមួយ និងកាត់បន្ថយមកត្រឹម 150 អឺរ៉ូក្នុងមួយតោននៅឆ្នាំទីពីរ និងធ្លាក់មកត្រឹម 125 អឺរ៉ូក្នុងមួយតោននៅឆ្នាំទីបី[១៦]។ ជាលទ្ធផល នៅខែ កុម្ភៈ ឆ្នាំ 2019 ការនាំចេញអង្កររបស់កម្ពុជាទៅកាន់សហភាពអឺរ៉ុបមានតែ 10,080 តោនប៉ុណ្ណោះ ឬថយចុះ 57.8 ភាគរយធៀបនឹងខែមុន។ កម្ពុជាបាននាំចេញអង្ករ 270,000 តោន (ឬស្មើនឹង 43 ភាគរយនៃបរិមាណអង្ករនាំចេញសរុប) ទៅកាន់ទីផ្សារសហភាពអឺរ៉ុបនៅឆ្នាំ 2018។

**ផ្ទុយទៅវិញ ប្រទេសចិនបានបង្កើនកូតានាំចូលអង្ករពីកម្ពុជារហូតដល់ 400,000 តោននៅឆ្នាំ 2019 កើនពី 300,000 តោននៅឆ្នាំ 2018។** នៅឆ្នាំ 2018 ចំនួននៃការនាំចេញអង្ករជាក់ស្តែងទៅកាន់ប្រទេសចិន (ចិនដីគោក តំបន់រដ្ឋបាលពិសេសហុងកុង និងតំបន់រដ្ឋបាលពិសេសម៉ាកាវ) គឺមានចំនួន 170,154 តោន ឬស្មើនឹង 27 ភាគរយនៃការនាំចេញអង្ករសរុប។ សេចក្តីរាយការណ៍បង្ហាញថា ចំនួននាំចេញនេះគឺបណ្តាលមកពីដំណើរការយឺតយ៉ាវនៃការផ្តល់ការអនុញ្ញាត (ដោយគយចិន) ដល់ការនាំចេញទៅប្រទេសចិន។ ដូចទីផ្សារសហភាពអឺរ៉ុបដែរ ទីផ្សារចិនបានទិញអង្ករក្រអូបប្រណិតជាច្រើនពីកម្ពុជា។

**ជារួម ការថយចុះនៃការនាំចេញអង្កររបស់កម្ពុជាទៅកាន់សហភាពអឺរ៉ុបត្រូវបានប៉ះប៉ូវដោយកំណើននៃការនាំចេញអង្ករ**

---

១៣ របាយការណ៍ប្រចាំឆ្នាំ សមិទ្ធផលឆ្នាំ 2018 និងគោលដៅឆ្នាំ 2019 ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខែ មីនា ឆ្នាំ 2018។

១៤ របាយការណ៍ស្តីពីស្ថានភាពនៃការនាំចេញស្រូវអង្កររបស់កម្ពុជានៅឆ្នាំ 2018 លេខាធិការដ្ឋានសេវាច្រកចេញចូលតែមួយសម្រាប់ការនាំចេញស្រូវអង្ករ។

១៥ https://thericetrader.com/conferences/2018-WRC-Hanoi/worlds-best-rice/

១៦ សេចក្តីថ្លែងការណ៍របស់គណៈកម្មការសហភាពអឺរ៉ុប ថ្ងៃទី 19 ខែ មករា ឆ្នាំ 2019 ៖ http://europa.eu/rapid/press-release_IP-19-427_en.htm

**របស់កម្ពុជាទៅកាន់ទីផ្សារចិន។** នៅខែ កុម្ភៈ ឆ្នាំ 2019 នៅពេលដែលវិធានការការពារត្រូវបានអនុវត្តពេញលេញនោះ ការនាំចេញអង្ករទៅកាន់សហភាពអឺរ៉ុបបានថយចុះចំនួន 57.8 ភាគរយបើធៀបនឹងខែមុន។ ផ្ទុយទៅវិញ ការនាំចេញអង្ករបស់កម្ពុជាទៅកាន់ទីផ្សារចិនបានកើនឡើងចំនួន 45.6 ភាគរយ។ ជាលទ្ធផលចំនួននៃការនាំចេញអង្កររបស់កម្ពុជាកើនឡើង 2 ភាគរយក្នុងរយៈពេលពីរខែដំបូងក្នុងឆ្នាំ 2019។ ទិន្នន័យផ្លូវការបង្ហាញថា ការនាំចេញអង្កររបស់កម្ពុជាមានទទួលបាន 413.5 លានដុល្លានៅឆ្នាំ 2018[១៧]។

**នៅរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ មានវឌ្ឍនភាពក្នុងការបង្កើតភាពលេចធ្លោរផ្នែកគុណភាព និងឈ្មោះ។** ដោយសារតែកម្ពុជាមានទីតាំងនៅជិតបណ្តាប្រទេសផលិតធំៗ ដូចជា ម៉ាឡេស៊ី ថៃ និងវៀតណាម កម្ពុជាកំពុងខិតខំធ្វើការជាយុទ្ធសាស្រ្តក្នុងការបង្កើតភាពលេចធ្លោរផ្នែកគុណភាព (ស្រូវ អង្ករ ម្រេច) និរន្តរភាព ("បៃតង") និងបង្កើនសុវត្ថិភាពអាហារ ("ស្អាត") ក៏ដូចជាបន្តទៅជំរុញការកែច្នៃផលិតផលកសិកម្ម (ស្វាយចន្ទីដំណាំម្សៅ)។ ចំពោះការងារនេះ អាជ្ញាធរកម្ពុជាបានប្រើប្រាស់ឈ្មោះអង្ករ "ម្លិះអង្គរ" និងផលិតផលសម្គាល់ភូមិសាស្រ្ត (GI) ដូចជា ម្រេចកំពត និងកាហ្វេមណ្ឌលគិរី។ រោងចក្រកែច្នៃស្វាយចន្ទីមួយចំនួនកំពុងត្រូវបានសាងសង់ឡើង ប៉ុន្តែ ការធ្វើពិពិធកម្មឆ្ពោះទៅការផលិតផលិតផលសត្វ និងជលផល នៅតែទទួលបានជោគជ័យតិចតួច បើទោះបីជាមានកំណើនតម្រូវការ និងថ្លៃយ៉ាងណាក៏ដោយ។ កំណើនប្រាក់ចំណូល និងកំណើនទីប្រជុំជន ដែលគាំទ្រដោយកំណើនវិស័យទេសចរណ៍ កំពុងផ្លាស់ប្តូរការប្រើប្រាស់ម្ហូបអាហារក្នុងគ្រួសារ ជាពិសេសពាក់ព័ន្ធនឹងការប្រើប្រាស់ផលិតផលសត្វ។ ស្ថានភាពនេះក៏កើតឡើងចំពោះការនាំចេញដែរ នៅពេលមានកំណើនប្រជាជនវណ្ណៈកណ្តាលកាន់តែច្រើននៅអាស៊ី ជាពិសេសក្នុងប្រទេសចិន។ ដូច្នេះ ជាការចាំបាច់ត្រូវមានយុទ្ធសាស្រ្តជាតិជំរុញការធ្វើពិពិធកម្ម កសិកម្ម។

### ការកាត់បន្ថយភាពក្រីក្រនៅតែបន្ត ប៉ុន្តែក្រុមមនុស្សចំនួន 40 ភាគរយដែលនៅផ្នែកខាងក្រោមបំផុត កំពុងមានការលំបាកជាងមុន

**ខណៈដែលភាពក្រីក្របន្តថយចុះ កត្តាជំរុញការកាត់បន្ថយភាពក្រីក្រមានការប្រែប្រួល។** ការប៉ាន់ស្មានភាពក្រីក្រសម្រាប់អំឡុងឆ្នាំ 2015-2017 កំពុងស្ថិតក្រោមការពិនិត្យដោយអាជ្ញាធរកម្ពុជា ប៉ុន្តែការបង្ហាញជាបឋមគឺថា អត្រាភាពក្រីក្រនៅតែបន្តថយចុះ។ បើទោះជាបន្តមានវឌ្ឍនភាពសំខាន់ៗក្តី ការថយចុះភាពក្រីក្រនៅអំឡុងឆ្នាំ 2013-2017 តិចជាងការថយចុះភាពក្រីក្រនៅអំឡុងឆ្នាំ 2009-2013 ជាសំខាន់ដោយសារតែកំណើនសេដ្ឋកិច្ចបានផ្តល់ប្រយោជន៍ដល់ប្រជាជនមិនមែនក្រីក្រច្រើនជាងខណៈដែលភាពក្រីក្រនៅតំបន់ទីប្រជុំជនមិនមានការប្រែប្រួលបើធៀបនឹងពេលមុននោះ។ ការប្រើប្រាស់របស់មនុស្សម្នាក់ៗនៃក្រុមមនុស្សចំនួន 40 ភាគរយដែលនៅផ្នែកខាងក្រោមបំផុតកើនឡើង 13 ភាគរយនៅអំឡុងឆ្នាំ 2013-2017 ប៉ុន្តែការប្រើប្រាស់របស់មនុស្សម្នាក់ៗនៃក្រុមមនុស្សចំនួន 60 ភាគរយដែលនៅផ្នែកខាងលើបំផុត កើនឡើង 22 ភាគរយ។ ប្រាក់ឈ្នួលដែលទទួលបានពីការងារផ្សេងក្រៅពីវិស័យកសិកម្ម ដើរតួនាទីកាន់តសំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រនៅអំឡុងឆ្នាំ 2013-2017 ធៀបនឹងអំឡុងឆ្នាំ 2009-2013 នៅពេលដែលកសិកម្មគ្រួសារគឺជាចលករដ៏សំខាន់សម្រាប់កាត់បន្ថយភាពក្រីក្រ។

**រូប 11 ៖ ការរួមចំណែកដល់អត្រាអតិផរណារយៈពេល 12 ខែ**
(ភាគរយ)




*ប្រភព* ៖ អាជ្ញាធរកម្ពុជា

**រូប 12 ៖ សម្ពាធអតិផរណាថយចុះយ៉ាងខ្លាំងក្នុងបណ្តាប្រទេសដែលមានសេដ្ឋកិច្ចរីកចម្រើន...**
អត្រាអតិផរណាសំខាន់ៗ (ភាគរយធៀបនឹងឆ្នាំមុន ចុងគ្រា)




*ប្រភព* ៖ បច្ចុប្បន្នភាពសេដ្ឋកិច្ចអាស៊ីបូព៌ា និងប៉ាស៊ីហ្វិក ខែ មេសា ឆ្នាំ 2019 ធនាគារពិភពលោក

[១៧] នៅឆ្នាំ 2018 ចំនួននៃការនាំចេញស្មើនឹងអង្ករ 567,500 តោន (ទិន្នន័យគយ) ប៉ុន្តែ ទិន្នន័យរបស់សហព័ន្ធស្រូវអង្ករកម្ពុជាបង្ហាញថា ការនាំចេញអង្ករមានចំនួន 626,200 តោន។

**ការថយចុះភាពក្រីក្រផ្នែករូបិយវត្ថុ ត្រូវបានបង្ហាញឲ្យឃើញតាមរយៈភាពប្រសើរឡើងនៃជីវភាពគ្រួសារ។** ជាតួយ៉ាង ការមានកង្ហាររអគ្គិសនីប្រើប្រាស់កើនដល់ 37 ភាគរយពិន្ទុនៅអំឡុងឆ្នាំ 2013-2017 ចំណែកលទ្ធភាពទទួលបានអគ្គិសនីកើនដល់ 27 ភាគរយពិន្ទុ ហើយលទ្ធភាពទទួលបានអនាម័យប្រសើរកើនដល់ 24 ភាគរយពិន្ទុ។ អត្រាលទ្ធភាពទទួលបានអនាម័យ និងអគ្គិសនីប្រសើរ កើនឡើងលឿនជាងអត្រានៅអំឡុងឆ្នាំ 2009-2013។ ប៉ុន្តែ នៅតែមានគ្រួសារជាច្រើនដែលស្ថិតនៅលើបន្ទាត់ភាពក្រីក្រតែបន្តិច និងមិនសូវមានលទ្ធភាពទប់ទល់នឹងវិបត្តិផ្សេងៗ សូម្បីតែជាវិបត្តិតូចតាចក៏ដោយ។ នៅពេលមានវិបត្តិណាមួយដែលកាត់បន្ថយការប្រើប្រាស់សម្រាប់មនុស្សម្នាក់ក្នុងចំនួនទឹកប្រាក់ 2,000 រៀល (0.50 ដុល្លា) នោះនឹងបង្កើនភាពក្រីក្រទ្វេដង។

### អតិផរណាថយចុះបន្តិច ដោយសារតែការធ្លាក់ចុះតម្លៃប្រេងឥន្ធនៈជួយប៉ះប៉ូវការឡើងថ្លៃម្ហូបអាហារ

**អត្រាអតិផរណាមានកម្រិតទាបបំផុតក្នុងរយៈពេលបួនឆ្នាំកន្លងមក។** នៅឆ្នាំ 2018 អតិផរណាថយចុះបន្តិចដោយសារតែការថយចុះតម្លៃប្រេងឥន្ធនៈតាំងពីត្រីមាសទីបួនក្នុងឆ្នាំ 2018 បានជួយប៉ះប៉ូវការឡើងថ្លៃម្ហូបអាហារ។ សន្ទស្សន៍តម្លៃនៃការប្រើប្រាស់ថយចុះមកត្រឹម 1.6 ភាគរយនៅឆ្នាំ 2018 ចុះពី 2.2 ភាគរយនៅខែ ធ្នូ ឆ្នាំ 2017 (រូប 11) សំខាន់ដោយសារតែការថយចុះការចំណាយនៃសមាសភាគដឹកជញ្ជូន (សន្ទស្សន៍រង) នៅពេលដែលតម្លៃលក់រាយប្រេងសាំង និងប្រេងម៉ាស៊ូតថយចុះ និងសម្រួលដោយការថយចុះនៃថ្លៃប្រេង នៅទីផ្សារអន្តរជាតិនៅចុងឆ្នាំ 2018។ ដោយសារតែដុល្លារូបនីយកម្មមានកម្រិតខ្ពស់នៅកម្ពុជា ការឡើងថ្លៃប្រាក់ដុល្លាអាមេរិកនៅឆមាសទីពីរក្នុងឆ្នាំ 2018 បានរួមចំណែកដល់ការរក្សាអត្រាអតិផរណាឲ្យនៅទាប។

**នៅខែ កក្កដា ឆ្នាំ 2018 ដើម្បីរក្សាស្ថិរភាពតម្លៃលក់រាយនៃផលិតផលប្រេងឥន្ធនៈ នៅពេលមានការឡើងថ្លៃប្រេងនៅទីផ្សារអន្តរជាតិ អាជ្ញាធរកម្ពុជាបានកាត់បន្ថយអាករពិសេស** (អាករមួយក្នុងចំណោមអាករបួន ៖ ពន្ធគយ ពន្ធតម្លៃបន្ថែម ពន្ធអាករ និងអាករពិសេស) លើផលិតផលប្រេងឥន្ធនៈនាំចូល។ អាករពិសេសលើប្រេងសាំង ត្រូវបានកាត់បន្ថយមកត្រឹម 15 ភាគរយ (ចុះពី 35 ភាគរយ) ចំណែកអាករពិសេសលើប្រេងម៉ាស៊ូតត្រូវបានកាត់បន្ថយមកត្រឹម 5.5 ភាគរយ (ចុះពី 15 ភាគរយ) ហើយអាករពិសេសលើប្រេងកាតត្រូវបានកាត់បន្ថយមកត្រឹម 5 ភាគរយ (ចុះពី 15 ភាគរយ)[១៨]។ ការបាត់បង់ប្រាក់ចំណូលពន្ធពីផលិតផលទាំងនេះដែលបានរាយការណ៍គឺ 30 លានដុល្លាក្នុងមួយឆ្នាំ។ បើទោះជាកម្ពុជានាំចូលផលិតផលប្រេងឥន្ធនៈទាំងអស់ និងមាន "ការផ្ទេរ" អតិផរណាពេញពីតម្លៃប្រេងក្នុងទីផ្សារអន្តរជាតិលើតម្លៃលក់រាយក្នុងស្រុក អាជ្ញាធរកម្ពុជាតែងចេញផ្សាយតម្លៃប្រេងសាំង និងប្រេងម៉ាស៊ូតលក់រាយរៀងរាល់ពីរខែម្តង ដើម្បីឲ្យក្រុមហ៊ុនលក់រាយផលិតផលប្រេងឥន្ធនៈផ្លូវការអនុវត្តតាម។

**នៅតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក សម្ពាធអតិផរណាថយចុះបន្តិចក្នុងចំណោមបណ្តាប្រទេសដែលមានសេដ្ឋកិច្ចរីកចម្រើនដែលភាគច្រើនជាដៃគូពាណិជ្ជកម្មរបស់កម្ពុជា។** ភាគច្រើននៃប្រទេសដែលមានសេដ្ឋកិច្ចរីកចម្រើនក្នុងតំបន់នេះ មានអត្រាអតិផរណាថយចុះ (រូប 12)[១៩]។ ដោយសារតែប្រទេសចិន ថៃ

**រូប 13 ៖ ការរួមចំណែកដល់កំណើនរូបិយវត្ថុទូលាយ**
(ភាគរយពិន្ទុ)




*ប្រភព ៖ អាជ្ញាធរកម្ពុជា*

**រូប 14 ៖ ចរាចរណ៍ប្រាក់រៀលថយចុះ**
(ភាគរយប្រែប្រួលធៀបនឹងឆ្នាំមុន)




*ប្រភព ៖ អាជ្ញាធរកម្ពុជា*

---

១៨ http://cnv.org.kh/petroleum-price-decrease-0-03-first-july/

១៩ បច្ចុប្បន្នភាពសេដ្ឋកិច្ចអាស៊ីបូព៌ា និងប៉ាស៊ីហ្វិក ខែ មេសា ឆ្នាំ 2019 ក្រុមធនាគារពិភពលោក វ៉ាស៊ីនតោនឌីស៊ី។

និងវៀតណាមជាដៃគូពាណិជ្ជកម្មសំខាន់ៗរបស់កម្ពុជា ការថយចុះអត្រាអតិផរណាក្នុងប្រទេសទាំងនេះ បានជួយរក្សាសម្ពាធអតិផរណានៅកម្ពុជា។ ប្រទេសមានសេដ្ឋកិច្ចរីកចម្រើនជាច្រើនក្នុងតំបន់នេះបានអនុវត្តគោលនយោបាយរូបិយវត្ថុរឹតត្បិត ដើម្បីឆ្លើយតបនឹងការថយចុះអត្រាប្តូរប្រាក់ និងគោលនយោបាយធ្វើឲ្យមានលំនឹងរូបិយវត្ថុរបស់សហរដ្ឋអាមេរិក។ ដោយសារតែភាគច្រើននៃប្រទេសដែលមានសេដ្ឋកិច្ចរីកចម្រើនទាំងនេះ មានអត្រាអតិផរណាថេរ គោលនយោបាយរឹតត្បិតបានជួយកាត់បន្ថយថ្លៃបន្ថែមទៀត។

### លំហូរនៃការវិនិយោគទុនផ្ទាល់ពីបរទេសជួយដល់ប្រាក់បញ្ញើជារូបិយប័ណ្ណបរទេស

**បើទោះជាកំណើនរូបិយវត្ថុទូលាយនៅតែមានអត្រា 24.0 ភាគរយនៅឆ្នាំ 2018 ប៉ុន្តែ ប្រាក់បញ្ញើជារូបិយប័ណ្ណបរទេសកើនឡើង ជំនួសការដាក់ប្រាក់បញ្ញើជាប្រាក់រៀល និងចរាចរណ៍ប្រាក់រៀល។** ប្រាក់បញ្ញើជារូបិយប័ណ្ណបរទេសបានកើនឡើង 26.5 ភាគរយនៅឆ្នាំ 2018 កើនពី 23.6 ភាគរយនៅឆ្នាំ 2017។ ប្រាក់នេះបានរួមចំណែក 22.1 ភាគរយពិន្ទុនៃកំណើនរូបិយវត្ថុទូលាយ 24.0 ភាគរយនេះ (រូប 13)។ ដោយសារតែដុល្លារូបនីយកម្មមានកម្រិតខ្ពស់ ប្រាក់រូបិយប័ណ្ណបរទេស ដែលជាចំណែកមួយនៃរូបិយវត្ថុទូលាយនៅឆ្នាំ 2018 មានចំនួន 84.8 ភាគរយ កើនពី 83.1 ភាគរយនៅឆ្នាំ 2017។

**ការសន្សំទុនបម្រុងអន្តរជាតិសរុបថយចុះ ដោយសារការបញ្ចូលរូបិយប័ណ្ណក្នុងស្រុកយឺតៗទៅក្នុងទីផ្សារដោយធនាគារជាតិ។** ធនាគារជាតិបានទិញប្រាក់ដុល្លា 875 លាននៅឆ្នាំ 2018 ដែលថយចុះ 9 ភាគរយ បើធៀបនឹងឆ្នាំ 2017។ ជាលទ្ធផល ទុនបម្រុងអន្តរជាតិសរុប ថយចុះមកត្រឹម 16.0 ភាគរយនៅឆ្នាំ 2018 ថយពី 30 ភាគរយនៅឆ្នាំ 2017។ យ៉ាងណាក៏ដោយ ទុនបម្រុងអន្តរជាតិបានកើនដល់ 10.1 ពាន់លានដុល្លា ឬស្មើនឹងការនាំចូលនាពេលអនាគតរយៈពេល 6 ខែនៅឆ្នាំ 2018។ កំណើនចរាចរណ៍ប្រាក់រៀលថយមកត្រឹម 11.5 ភាគរយនៅឆ្នាំ 2018 ចុះពី 28.2 ភាគរយនៅឆ្នាំ 2017 ដោយសារតែរូបិយប័ណ្ណក្នុងស្រុករងសម្ពាធកាន់តែច្រើនពីកំណើនតម្រូវការនាំចូល (រូប 14)។

**យ៉ាងណាក៏ដោយ អត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លាអាមេរិកដែលធ្លាក់ថ្លៃនៅត្រីមាសទីបីនៃឆ្នាំ 2018 រក្សាបានស្ថិរភាពនៅចុងឆ្នាំ 2018។** អត្រាប្តូរប្រាក់គឺ 4,018 រៀលក្នុងមួយដុល្លានៅខែ ធ្នូ ឆ្នាំ 2018 ធៀបនឹងអត្រា 4,037 រៀលក្នុងមួយដុល្លានៅឆ្នាំ 2017។ ប្រាក់រៀលចុះថ្លៃបន្តិចបើធៀបនឹងប្រាក់បាតថៃ ប៉ុន្តែឡើងថ្លៃបើធៀបនឹងប្រាក់ដុងវៀតណាម និងប្រាក់យ័នចិន។ ធៀបនឹងរូបិយប័ណ្ណរបស់ទីផ្សារនាំចេញសំខាន់ៗរបស់កម្ពុជា (ក្រៅពីសហរដ្ឋអាមេរិក) ប្រាក់រៀលឡើងថ្លៃ បើធៀបនឹងប្រាក់អឺរ៉ូ ប្រាក់ដុល្លាកាណាដា និងប្រាក់ផោនអង់គ្លេស។

**ការជំរុញការប្រើប្រាស់រូបិយប័ណ្ណក្នុងស្រុក ត្រូវបានគាំទ្រដោយភាពជោគជ័យនៃប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា** ដែលត្រូវបានចាប់ផ្តើមអនុវត្តកាលពីខែ តុលា ឆ្នាំ 2016 ដើម្បីបង្កើតកម្រិតកំណត់សម្រាប់កម្ចីជារូបិយប័ណ្ណក្នុងស្រុក។ គម្រោងប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា ដែលតម្រូវឲ្យមានវិញ្ញាបនបត្របញ្ញើដែលអាចជួញដូរ ជាទ្រព្យបញ្ចាំដើម្បីទទួលបានរូបិយប័ណ្ណក្នុងស្រុក (ជាមួយនឹងលក្ខខណ្ឌបង្កើនកម្ចីជាប្រាក់រៀល រហូតដល់យ៉ាងហោចណាស់ 10 ភាគរយនៃទំហំប្រាក់កម្ចីសរុបត្រឹមចុងឆ្នាំ 2019) បានផ្តល់លទ្ធភាពឲ្យធនាគារជាតិបញ្ចូលរូបិយប័ណ្ណក្នុងស្រុក នៅពេលដែលរក្សា

**រូប 15 ៖ ការផ្តល់ឥណទានដោយវិស័យធនាគារនៅកម្ពុជាដល់វិស័យឯកជន មានកម្រិតខ្ពស់** (ឥណទានក្នុងស្រុកធៀបគិតជាភាគរយ ផសស ឆ្នាំ 2017)




*ប្រភព* ៖ សូចនាករអភិវឌ្ឍន៍ពិភពលោក, ធនាគារពិភពលោក

**រូប 16 ៖ ការរួមចំណែកដល់កំណើនឥណទានក្នុងស្រុក** (ភាគរយពិន្ទុ)




*ប្រភព* ៖ អាជ្ញាធរកម្ពុជា

ស្ថិរភាពនៃអត្រាប្តូរប្រាក់រៀល-ដុល្លារអាមេរិក[២០]។ ការណែនាំវិធានការនេះបានជួយកាត់បន្ថយអត្រាកម្ចីជាប្រាក់រៀលបន្តិចម្តងៗ។

**អត្រាការប្រាក់រយៈពេលខ្លីថយចុះបន្តិចម្តងៗ ទោះបីជាពីដំបូងមានកំណើនក្តី។** មធ្យមភាគនៃអត្រាផ្តល់ប្រាក់កម្ចីពីធនាគារថយចុះមកត្រឹម 11.08 ភាគរយក្នុងមួយឆ្នាំ នៅខែ កញ្ញា ឆ្នាំ 2018 ថយចុះពី 11.7 ភាគរយក្នុងមួយឆ្នាំ នៅចុងឆ្នាំ 2017។ ប៉ុន្តែ អត្រាផ្តល់កម្ចីជាមធ្យមពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានកម្រិតខ្ពស់ជាងបើធៀបនឹងអត្រាផ្តល់កម្ចីពីធនាគារ។ អត្រាការប្រាក់បញ្ញើមានការប្រែប្រួលតិចតួច។ មធ្យមភាគនៃអត្រាការប្រាក់បញ្ញើជាប្រាក់ដុល្លារអាមេរិក (រយៈពេល 12 ខែ) នៅតែមាន 4.42 ភាគរយក្នុងមួយឆ្នាំនៅខែ កញ្ញា ឆ្នាំ 2018។

**ទ្រទ្រង់ដោយសកម្មភាពសេដ្ឋកិច្ចដ៏រស់រវើក ការផ្តល់កម្ចីដល់វិស័យឯកជនមានកំណើនជាថ្មី** បន្ទាប់ពីថយចុះបន្តិចនៅចុងឆ្នាំ 2017 និងដើមឆ្នាំ 2018។ កំណើនឥណទានមានចំនួន 24.4 ភាគរយ កើនពីអត្រា 19.6 ភាគរយនៅឆ្នាំ 2017។ កម្ពុជាមានអត្រាកំណើនយ៉ាងឆាប់រហ័សនៃការផ្តល់កម្ចីដោយធនាគារជាពិសេសក្រោយពីវិបត្តិហិរញ្ញវត្ថុសកល។ កំឡុងពេលនេះមានការរីកលូតលាស់នៃវិស័យសំណង់ និងអចលនទ្រព្យ។ ការប្រៀបធៀបរវាងប្រទេសបង្ហាញថា ឥណទានធនាគាររបស់កម្ពុជាធៀបនឹងភាគរយ ផសស មានកម្រិតខ្ពស់ជាងឥណទានធនាគាររបស់ឥណ្ឌូនេស៊ី និងហ្វីលីពីន បើទោះជាវិស័យធនាគារនៅកម្ពុជាទើបតែដំណើរការក្តី (រូប 15)។

### មានការផ្លាស់ប្តូរនៃការផ្តល់ឥណទានក្នុងស្រុកទៅផ្តល់ហិរញ្ញប្បទានដល់វិស័យសេវា

**នាពេលថ្មីៗនេះ ឥណទានក្នុងស្រុកដែលផ្តល់ឲ្យវិស័យសេវាមានការកើនឡើង។** វិស័យសេវានេះរួមមាន ការលក់ដុំ ការដឹកជញ្ជូន និងទូរគមនាគមន៍ និងការប្រើប្រាស់ផ្ទាល់ខ្លួន (រូប 16)។ និន្នាការនេះបង្ហាញពីកំណើននៃការប្រើប្រាស់ និងតម្រូវការសាងសង់ ដោយមានពាណិជ្ជកម្មលក់ដុំដែលបង្កើនការនាំចូលទំនិញជាប់ធន់ មានជាអាទិ៍ យានយន្ត និងសម្ភារសំណង់។ ផ្ទុយទៅវិញ ឥណទានក្នុងស្រុកដែលផ្តោតលើវិស័យកសិកម្ម សកម្មភាពកម្មន្តសាល ឬសេវាលក់រាយ (ដូចជា វិស័យម្ហូបអាហារ) មានការថយចុះ។

**ប្រាក់កម្ចីមិនទាន់សងសរុបដែលផ្តល់ហិរញ្ញប្បទានដោយវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុ មានចំនួនជាង 100 ភាគរយនៃផសស** ឬស្មើនឹងទឹកប្រាក់ 104.2 ទ្រីលានរៀលនៅឆ្នាំ 2018។ ក្នុងនោះ ហិរញ្ញប្បទាន 80 ភាគរយទទួលបានពីវិស័យធនាគារ ហើយ 20 ភាគរយទៀត ទទួលបានពីវិស័យមីក្រូហិរញ្ញវត្ថុ។ យ៉ាងណាក៏ដោយ តួលេខនេះមិនរាប់បញ្ចូលឥណទានដែលផ្តល់ដោយប្រព័ន្ធ “ធនាគារស្រមោល” ដែលបង្កើតឡើងដោយអ្នកអភិវឌ្ឍន៍វិស័យអចលនទ្រព្យ ក្រុមហ៊ុនជួល ហាងបញ្ចាំ និងអ្នកផ្តល់កម្ចីក្រៅផ្លូវការឡើយ។ ដូច្នេះ ទំហំឥណទានសរុបក្នុងសេដ្ឋកិច្ចទាំងមូល មានកម្រិតខ្ពស់ជាងនេះច្រើន។

**ការរាយការណ៍បង្ហាញថា ផលធៀបកម្ចីមិនដំណើរការសម្រាប់វិស័យធនាគារថយចុះបន្តិច។** ផលធៀបកម្ចីមិនដំណើរការសម្រាប់វិស័យធនាគារបានកើនឡើងដល់ 2.8 ភាគរយនៅឆ្នាំ 2018 កើនពីអត្រា 2.3 ភាគរយនៅចុងឆ្នាំ 2017[២១]។ កម្ចីមិនដំណើរការក្នុងវិស័យកសិកម្មមានកម្រិតខ្ពស់បំផុតគឺ 8 ភាគរយ ចំណែកវិស័យសំណង់ និងវិស័យកម្មន្តសាលមានអត្រាស្មើគ្នា គឺ4 ភាគរយ។ កម្ចីមិនដំណើរការសម្រាប់វិស័យមីក្រូហិរញ្ញវត្ថុមានភាពប្រសើរឡើងដោយថយចុះមកត្រឹម 1.0 ភាគរយនៅឆ្នាំ 2018 ថយពី 2.0 ភាគរយនៅឆ្នាំ 2017។ យ៉ាងណាក៏ដោយ ត្រូវមានការបកស្រាយផលធៀបកម្ចីមិនដំណើរការដោយប្រុងប្រយ័ត្ន ព្រោះមានភាពមិនស៊ីសង្វាក់គ្នាលើការចាត់ថ្នាក់ប្រភេទកម្ចី ការបន្តសងប្រាក់ និងការផ្តល់កម្ចីឡើងវិញ។

### កំណើននាពេលថ្មីៗនៃលំហូរការវិនិយោគផ្ទាល់ពីបរទេសជួយទ្រទ្រង់កំណើនការសាងសង់

**កំណើននាពេលថ្មីៗនេះនៃលំហូរការវិនិយោគផ្ទាល់ពីបរទេសមិនត្រឹមតែជួយទ្រទ្រង់កំណើនការសាងសង់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានលាក់បាំងភាពងាយរងគ្រោះរបស់វិស័យហិរញ្ញវត្ថុទៀតផង។** ការរួមចំណែកនៃការផ្តល់ឥណទានដល់វិស័យសំណង់ អចលនទ្រព្យ និងការបញ្ចាំ មានចំនួន 8 ភាគរយពិន្ទុ ឬស្មើនឹង 40 ភាគរយនៃកំណើនឥណទានក្នុងស្រុកសរុប។ ជាទូទៅ វិស័យសំណង់ និងអចលនទ្រព្យងាយប្រឈមនឹងវដ្តនៃការឡើង-ចុះ ហើយការថយចុះនៃលំហូរការវិនិយោគផ្ទាល់ពីបរទេស អាចលាក់បាំងការប្រឈម និងភាពងាយរងគ្រោះនៃវិស័យធនាគារបាន។

**យ៉ាងណាក៏ដោយ មានកិច្ចខិតខំប្រឹងប្រែងជាច្រើនក្នុងការរក្សាស្ថិរភាពវិស័យហិរញ្ញវត្ថុ និងជំរុញការប្រើប្រាស់រូបិយប័ណ្ណក្នុងស្រុក** តាមរយៈការកាត់បន្ថយដុល្លារូបនីយកម្ម។ វិធានការប្រុងប្រយ័ត្នផ្នែកម៉ាក្រូសេដ្ឋកិច្ចដែលបានអនុវត្តកន្លងមករួមមានការប្រើប្រាស់ផលធៀបគ្របដណ្តប់សន្ទនីយភាពនៅឆ្នាំ 2015 និងការបង្កើនផលធៀបនេះរហូតដល់ឆ្នាំ 2020 គួបផ្សំនឹងការពង្រឹងការពិនិត្យតាមដានភាពមិនស៊ីសង្វាក់រវាងរូបិយវត្ថុ និងកាលកំណត់[២២]។ កម្រិតមូលធនអប្បបរមាថ្មីត្រូវបានកំណត់នៅត្រីមាសទីមួយក្នុងឆ្នាំ 2018។ ធនាគារជាតិបានធ្វើការវាយតម្លៃមួយដែលបង្ហាញថា ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុមានភាពរឹងមាំ លើកលែងតែគ្រឹះស្ថានហិរញ្ញវត្ថុមួយចំនួនដែលត្រូវមានការពិនិត្យតាមដានយ៉ាងប្រុងប្រយ័ត្ន។

[២០] សូមមើល បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា ខែ មេសា ឆ្នាំ 2018 សម្រាប់ការពិភាក្សាលម្អិតស្តីពីការប្រើប្រាស់ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានាក្នុងវិស័យរូបិយវត្ថុ។

[២១] របាយការណ៍ឆ្នាំ 2018 របស់ធនាគារជាតិនៃកម្ពុជា។

[២២] របាយការណ៍ប្រចាំឆ្នាំ 2017 និង 2018 របស់ធនាគារជាតិនៃកម្ពុជា។

### ប្រាក់ចំណូលត្រូវបានប៉ាន់ស្មានថាមានអត្រាខ្ពស់ថ្មីមួយនៅឆ្នាំ 2018

**ប្រាក់ចំណូលក្នុងស្រុក (រួមទាំងជំនួយឥតសំណង) ត្រូវបានប៉ាន់ស្មានថាកើនដល់អត្រាខ្ពស់ដែលមិនធ្លាប់មានពីមុនគឺ 22.3 ភាគរយនៃ ផសស នៅឆ្នាំ 2018 ដោយសារតែភាពប្រសើរឡើងនៃការគ្រប់គ្រងពន្ធ (រូប 17)។** ពន្ធលើទំនិញ និងសេវា (ពន្ធប្រយោល) នៅតែជាប្រភពប្រាក់ចំណូលក្នុងស្រុកដ៏សំខាន់ ដែលរួមចំណែក 50 ភាគរយនៃចំណូលពន្ធសរុបកាលពីឆ្នាំមុន។ ក្នុងនោះ ពន្ធតម្លៃបន្ថែម និងពន្ធអាករ (ពន្ធលើការនាំចូល) មានចំនួន 70 ភាគរយ ចំណែកពន្ធផ្ទាល់ មានភាពប្រសើរឡើងយ៉ាងច្រើនកាលពីប៉ុន្មានឆ្នាំមុន ដោយមានចំនួន 4.3 ភាគរយនៃ ផសស នៅឆ្នាំ 2018 (កើនពី 4.2 ភាគរយនៅឆ្នាំ 2017)។ កំណើននេះបណ្តាលមកពីការគ្រប់គ្រងប្រាក់ចំណូលបានល្អជាងមុន ជាពិសេសសេវាបង់ពន្ធតាមប្រព័ន្ធអេឡិចត្រូនិក ដែលគ្របដណ្តប់លើពន្ធផលចំណេញ ដែលបានបង្កើតឡើង មានដូចជាពន្ធចុះបញ្ជី និងពន្ធតម្លៃបន្ថែមតាមប្រព័ន្ធអេឡិចត្រូនិក និងការប្រើប្រាស់ប្រព័ន្ធធនាគារសម្រាប់ការបង់ពន្ធ។

**លើសពីនេះទៀត គាំទ្រដោយកំណើនការនាំចូល ការប្រមូលពន្ធពាណិជ្ជកម្មត្រូវបានប៉ាន់ស្មានថាបានកើនឡើង បើធៀបនឹងឆ្នាំមុន** ដោយរួមចំណែកចំនួន 2.4 ភាគរយនៃ ផសស ឬស្មើនឹងអត្រាកំណើន 20 ភាគរយបើធៀបនឹងឆ្នាំមុន (រូប 18) កើនពីអត្រា 2.2 ភាគរយនៅឆ្នាំ 2017 បើទោះជាមានការប្តេជ្ញាចិត្តក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន (AFTA) ក្តី។

**គំនិតផ្តួចផ្តើមថ្មីក្នុងការកែលម្អការគ្រប់គ្រងប្រាក់ចំណូលមិនមែនពន្ធ រួមមានការប្រើប្រាស់ប្រព័ន្ធព័ត៌មានគ្រប់គ្រងប្រាក់ចំណូលមិនមែនពន្ធ (NRMIS)។** វិធានការនេះ គួបផ្សំនឹងប្រកាសអន្តរក្រសួង និងប្រព័ន្ធចេញវិក្កយបត្រស្តង់ដារ បានជួយកែលម្អការគ្រប់គ្រងប្រាក់ចំណូលមិនមែនពន្ធ និងរក្សានិរន្តរភាពនៃការប្រមូលប្រាក់ចំណូលមិនមែនពន្ធ។ ប្រាក់ចំណូលមិនមែនពន្ធ (និងប្រាក់ចំណូលផ្សេងទៀត) ត្រូវបានប៉ាន់ស្មានថារួមចំណែកចំនួន 3.7 ភាគរយនៃ ផសស នៅឆ្នាំ 2018 កើនពីអត្រា 3.5 ភាគរយនៅឆ្នាំ 2017។

### យុទ្ធសាស្ត្រប្រមូលប្រាក់ចំណូលថ្មីមានគោលដៅធ្វើទំនើបកម្មរដ្ឋបាល

**អាជ្ញាធរកម្ពុជាគ្រោងនឹងអនុវត្តយុទ្ធសាស្ត្រប្រមូលប្រាក់ចំណូលថ្មី** សម្រាប់ឆ្នាំ 2019-2023 ដែលផ្តោតលើការធ្វើទំនើបកម្មរដ្ឋបាល និងគោលនយោបាយពន្ធ និងគយ។ យុទ្ធសាស្ត្រនេះរួមមាន កំណែទម្រង់ពន្ធលើទំនិញប្រើប្រាស់ និងពន្ធប្រាក់ចំណូល។ យុទ្ធសាស្ត្រថ្មីនេះនឹងកំណត់ប្រភពប្រាក់ចំណូលថ្មីៗ ដើម្បីបង្កើនការប្រមូលប្រាក់ចំណូលឲ្យបានច្រើនបំផុត ដោយលើកកម្ពស់គំនិតកែច្នៃថ្មី និងធានាឲ្យមានការប្រកួតប្រជែងដោយស្មើភាព និងសមធម៌។ ការកែសម្រួលការលើកទឹកចិត្តផ្នែកពន្ធត្រូវបានរំពឹងថានឹងជួយដល់ការទទួលបានមូលធន និងការច្នៃប្រឌិតថ្មី ចំណែកឯការប្រមូលពន្ធប្រាក់ចំណូលបុគ្គលជួយឲ្យមានសមធម៌។ អាករនឹងត្រូវរៀបចំឲ្យដោះស្រាយបញ្ហាខាងក្រៅ និងការប្រកួតប្រជែងដោយមិនស្មើភាព។ ខណៈដែលយុទ្ធសាស្ត្រឆ្នាំ 2014-2018 មានគោលដៅសម្រេចចំនួន 0.5 ភាគរយនៃ ផសស ពីការប្រមូលប្រាក់ចំណូល (បច្ចុប្បន្ន) ក្នុងមួយឆ្នាំ ការពិភាក្សាបឋមបង្ហាញថា យុទ្ធសាស្ត្រថ្មីកំណត់អត្រាទាបជាងនេះ គឺកំណើនប្រាក់ចំណូលក្នុងមួយឆ្នាំ ត្រឹមតែ 0.3 ភាគរយនៃ ផសស ប៉ុណ្ណោះ។

**រូប 17 ៖ សមាសភាគសំខាន់ៗ**
(ភាគរយនៃ ផសស)




*ប្រភព* ៖ អាជ្ញាធរកម្ពុជា
*សម្គាល់* ៖ e= ការប៉ាន់ស្មាន

**រូប 18 ៖ ការប្រមូលពន្ធពាណិជ្ជកម្ម កើនឡើងកាលពីឆ្នាំមុន**
(ភាគរយប្រែប្រួលធៀបនឹងឆ្នាំមុន)




*ប្រភព* ៖ អាជ្ញាធរកម្ពុជា
*សម្គាល់* ៖ e= ការប៉ាន់ស្មាន

### ប្រាក់បៀវត្សរ៍ក្នុងវិស័យសាធារណៈត្រូវបានប៉ាន់ស្មានថាមានចំនួន 8.6 ភាគរយនៃ ផសស នៅឆ្នាំ 2018

**ប្រាក់បៀវត្សរ៍ក្នុងវិស័យសាធារណៈត្រូវបានប៉ាន់ស្មានថាបានកើនឡើងដល់ 8.6 ភាគរយនៃ ផសស នៅឆ្នាំ 2018** (រូប 19 និង 20)។ អត្រានេះមានកំណើនមួយជាបី (បើធៀបនឹងអត្រានៅឆ្នាំ 2013) នៃប្រាក់បៀវត្សរ៍អប្បបរមាសម្រាប់មន្ត្រីរាជការដែលកើនដល់ 1 លានរៀលក្នុងមួយខែនៅឆ្នាំ ២០១៨។ ការបង្កើនប្រាក់បៀវត្សរ៍បន្ថែមទៀតនឹងមិនមាននិរន្តរភាពយូរអង្វែងឡើយ និងចាំបាច់ត្រូវពន្លឿនកិច្ចការសំខាន់ៗនៃកំណែទម្រង់រដ្ឋបាលសាធារណៈដើម្បីពង្រីកការផ្តល់សេវាសាធារណៈ។ ខណៈដែលកម្ពុជាបានធ្វើកំណែទម្រង់ផ្នែករចនាសម្ព័ន្ធ កិច្ចការសំខាន់ៗទាំងនោះ ដែលរួមមាន ការកែលម្អបរិយាកាសវិនិយោគដោយកាត់បន្ថយចំណាយលើការធ្វើអាជីវកម្ម ការកំណត់តម្លៃថាមពលដែលមានភាពប្រកួតប្រជែង និងការកាត់បន្ថយចំណាយលើផ្នែកភស្តុភារ ត្រូវមានការបង្កើនផលិតភាពរបស់វិស័យសាធារណៈ និងការផ្តល់សេវាសាធារណៈឲ្យកាន់តែមានប្រសិទ្ធភាព។ វិធានការទាំងនេះក៏ជួយទ្រទ្រង់តួនាទីអភិវឌ្ឍនៃរបស់វិស័យឯកជនក្នុងការជំរុញកំណើន និងកាត់បន្ថយភាពក្រីក្រផងដែរ។

**ខណៈដែលកំណើនសារពើពន្ធកាលពីឆ្នាំមុនបង្កើនការវិនិយោគលើវិស័យសាធារណៈ ដំណើរការប្រមូលប្រាក់ចំណូលដ៏ល្អប្រសើរបានជួយដោះស្រាយឱនភាពសារពើពន្ធនេះ។** ឱនភាពសារពើពន្ធ (រួមទាំងជំនួយឥតសំណង) កើនដល់ 1.9 ភាគរយនៃ ផសស

**រូប 19 ៖ ចំណាយទូទៅរបស់រដ្ឋាភិបាល ៖ សមាសភាគសំខាន់ៗ** (ភាគរយនៃ ផសស)




*ប្រភព* ៖ អាជ្ញាធរកម្ពុជា
*សម្គាល់* ៖ e= ការប៉ាន់ស្មាន

**រូប 20 ៖ ប្រាក់បៀវត្សរ៍ក្នុងវិស័យសាធារណៈ** (ភាគរយនៃ ផសស)




*ប្រភព* ៖ អាជ្ញាធរកម្ពុជា
*សម្គាល់* ៖ e= ការប៉ាន់ស្មាន

**រូប 21 ៖ ជារួម ឱនភាពសារពើពន្ធរបស់រដ្ឋាភិបាលស្ទើរតែមានអត្រាថេរនៅឆ្នាំ 2018 ដោយសារការប្រមូលប្រាក់ចំណូលបានល្អ** (ភាគរយនៃ ផសស)




*ប្រភព* ៖ អាជ្ញាធរកម្ពុជា
*សម្គាល់* ៖ e= ការប៉ាន់ស្មាន

**រូប 22 ៖ ប្រាក់បញ្ញើរដ្ឋាភិបាលក្នុងប្រព័ន្ធធនាគារ** (ភាគរយនៃ ផសស)




*ប្រភព* ៖ អាជ្ញាធរកម្ពុជា

នៅឆ្នាំ 2018 កើនពី 1.6 ភាគរយនៅឆ្នាំ 2017។ ប៉ុន្តែ ឱនភាពនេះនៅតែទទួលបានហិរញ្ញប្បទានទាំងស្រុងពីមូលនិធិខាងក្រៅ។ កំណើនសារពើពន្ធនៅឆ្នាំ 2018 បានធ្វើឲ្យមានកំណើនការប្រើប្រាស់។ ចំណាយសាធារណៈត្រូវបានប៉ាន់ស្មានថាកើនដល់ 24.2 ភាគរយនៃ ផសស នៅឆ្នាំ 2018 កើនពី 23.1 ភាគរយនៅឆ្នាំ 2017 (រូប 21)។ ជារួម ដំណើរការសារពើពន្ធរបស់រដ្ឋាភិបាលកម្ពុជានៅតែរឹងមាំ ទោះបីជាមានកំណើនសារពើពន្ធកាលពីឆ្នាំកន្លងទៅក្តី។ ក្រោយដំណើរការសារពើពន្ធល្អប្រសើរជាច្រើនឆ្នាំ រដ្ឋាភិបាលកម្ពុជាទទួលបានប្រាក់បញ្ញើជាច្រើននៅធនាគារជាតិ។ អាជ្ញាធរកម្ពុជាអាចប្រើប្រាស់ប្រាក់បញ្ញើដែលមានចំនួន 14.9 ភាគរយនៃ ផសស ជាខែលការពារសារពើពន្ធ (រូប 22) ដោយសារតែគោលនយោបាយរូបិយវត្ថុ នៅតែរាំងស្ទះដោយសេដ្ឋកិច្ចដុល្លារូបនីយកម្មកម្រិតខ្ពស់នៅកម្ពុជា[២៣]។

### ការវិភាគនិរន្តរភាពបំណុលឆ្នាំ 2018 ដោយធនាគារពិភពលោក/មូលនិធិរូបិយវត្ថុអន្តរជាតិ បង្ហាញពីវិបត្តិបំណុលទាបនៅកម្ពុជា

**ទិន្នន័យផ្លូវការបង្ហាញថា នៅពាក់កណ្តាលឆ្នាំ 2018 កម្ពុជាមានបំណុលសាធារណៈដែលមិនទាន់សងសរុបចំនួន 6.79 ពាន់លានដុល្លា (ឬស្មើនឹង 28.6 ភាគរយនៃ ផសស)។** ក្នុងនោះ បំណុល 0.04 ភាគរយជាបំណុលសាធារណៈក្នុងស្រុក[២៤]។ ជារួម លក្ខខណ្ឌផ្តល់កម្ចីជាកម្ចីសម្បទានដោយមានអត្រាការប្រាក់ (មធ្យមភាគ) 1.37 ភាគរយកាលកំណត់ 25.5 ឆ្នាំ និងថិរវេលាចាប់ផ្តើមទូទាត់សង 8 ឆ្នាំបន្ទាប់។ គិតតាមរូបិយប័ណ្ណសំខាន់ៗ បំណុលជំពាក់ជាប្រាក់ដុល្លាអាមេរិក មានចំនួន 43.2 ភាគរយ ចំណែកបំណុលជំពាក់ជាសិទ្ធិដកប្រាក់ពិសេស (SDR) មានចំនួន 28.1 ភាគរយ និងបំណុលជំពាក់ជាប្រាក់យ័នចិន គឺ 16.1 ភាគរយ។

### ចិនជាអ្នកផ្តល់ឥណទានធំជាងគេ ដែលមានចំនួន 50 ភាគរយនៃបំណុលសរុបរបស់កម្ពុជា

**បំណុលខាងក្រៅដែលកម្ពុជាជំពាក់ចិន ស្មើនឹង 48.4 ភាគរយនៃបំណុលមិនទាន់សងសរុបត្រឹមឆមាសទីមួយក្នុងឆ្នាំ 2018។** អ្នកផ្តល់ឥណទានធំជាងគេទីពីរ និងទីបីគឺជាពហុភាគី គឺធនាគារអភិវឌ្ឍន៍អាស៊ី និងធនាគារពិភពលោក ដែលមានភាគរយ 19.3 ភាគរយ និង 8.0 ភាគរយនៃបំណុលមិនទាន់សងសរុប។ អ្នកផ្តល់ឥណទានធំជាងគេទីបួន និងទីប្រាំគឺសាធារណៈរដ្ឋកូរ៉េ និងជប៉ុន ដែលមានចំនួន 5.1 ភាគរយ និង 4.4 ភាគរយនៃបំណុលមិនទាន់សងសរុប។ បំណុលចាស់ (ក្រោមការចរចា) មានចំនួន 9.1 ភាគរយ។ ការវិភាគនិរន្តរភាពបំណុលឆ្នាំ 2018 ដោយធនាគារពិភពលោក/មូលនិធិរូបិយវត្ថុអន្តរជាតិ បង្ហាញពីវិបត្តិបំណុលទាបនៅកម្ពុជា សំខាន់ដោយសារតែគោលការណ៍របស់អាជ្ញាធរកម្ពុជាដែលទទួលតែកម្ចីសម្បទានប៉ុណ្ណោះនោះ។

### ថវិកាឆ្នាំ 2019 បង្ហាញពីពង្រឹងសារពើពន្ធរបស់អាជ្ញាធរកម្ពុជា

**តាមរយៈគោលនយោបាយពង្រឹងសារពើពន្ធរបស់អាជ្ញាធរកម្ពុជា ឱនភាពថវិកាឆ្នាំ 2019 ត្រូវបានកំណត់ឲ្យមានអត្រាត្រឹមតែ 4.6 នៃ ផសស ធៀបនឹងឱនភាពថវិកា 4.8 ភាគរយនៅឆ្នាំ 2018។** យ៉ាងណាក៏ដោយ ឱនភាពនេះមានអត្រាខ្ពស់ជាងអត្រាឱនភាពប៉ាន់ស្មានឆ្នាំ 2018 ដែលមានត្រឹមតែ 1.9 ភាគរយនៃ ផសស (រូប 23)។ ដើម្បីកាត់បន្ថយឱនភាពថវិកាឆ្នាំ 2019 អាជ្ញាធរកម្ពុជាបាននិងកំពុងខិតខំកែលម្អការប្រមូលប្រាក់ចំណូល និងរឹតត្បិតចំណាយសាធារណៈ។

**រូប 23 ៖ តុល្យភាពសារពើពន្ធ និងការផ្តល់ហិរញ្ញប្បទានដល់កញ្ចប់ថវិកាឆ្នាំ 2019** (ភាគរយនៃ ផសស)




*ប្រភព* ៖ អាជ្ញាធរកម្ពុជា

*សម្គាល់* ៖ e= ការប៉ាន់ស្មាន b= ថវិកា

**រូប 24 ៖ ប្រាក់ចំណូលសម្រាប់កញ្ចប់ថវិកាឆ្នាំ 2019** (ភាគរយនៃ ផសស)




*ប្រភព* ៖ អាជ្ញាធរកម្ពុជា

*សម្គាល់* ៖ e= ការប៉ាន់ស្មាន b= ថវិកា

[២៣] គិតត្រឹមខែ មិថុនា ឆ្នាំ 2018 ប្រាក់បញ្ញើរដ្ឋាភិបាល 31 ភាគរយនៅធនាគារជាតិនៃកម្ពុជាគឺជាប្រាក់ដុល្លា។

[២៤] "ព្រឹត្តិប័ត្រស្ថិតិស្ថិតិបំណុលសាធារណៈនៅកម្ពុជា" លេខ 6 ខែ កញ្ញា ឆ្នាំ 2018 ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**កញ្ចប់ប្រាក់ចំណូល (រួមទាំងជំនួយឥតសំណង) សម្រាប់ថវិកាឆ្នាំ 2019 មានកម្រិតទាប។** ទោះបីជាប្រាក់ចំណូលក្នុងស្រុកត្រូវបានប៉ាន់ស្មានថានឹងកើនឡើងដល់ 19.3 ភាគរយនៃ ផសស នៅឆ្នាំ 2019 កើនពី 18.6 ភាគរយនៃ ផសស នៅឆ្នាំ 2018 ក្តី ក៏អត្រានេះនៅតែទាបជាងអត្រាប្រមូលប្រាក់ចំណូលប៉ាន់ស្មានចំនួន 21.5 ភាគរយនៃ ផសស នៅឆ្នាំ 2018 (រូប 24)។ ចំណាយសាធារណៈត្រូវបានប៉ាន់ស្មានថាមានចំនួន 23.9 ភាគរយនៃ ផសស នៅឆ្នាំ 2019 គឺទាបបន្តិចជាង 24.0 ភាគរយនៃ ផសស នៅឆ្នាំ 2018 (និងចំណាយសាធារណៈប៉ាន់ស្មាន)។

### ចំណាយលើប្រាក់បៀវត្សរ៍នៅឆ្នាំ 2019 ត្រូវបានប៉ាន់ស្មានថាមានចំនួន 7.6 ភាគរយនៃ ផសស

ក្នុងកញ្ចប់ថវិកាឆ្នាំ 2019 ចំណាយលើប្រាក់បៀវត្សរ៍ (ក្រោមជំពូក 64 នៃប្រភេទថវិកា) ត្រូវបានកែតម្រូវ (បំបែក)។ នៅឆ្នាំ 2019 គណនីប្រាក់បៀវត្សរ៍ដែលបានកែតម្រូវ មានចំនួន 7.6 ភាគរយនៃ ផសស (រូប 25) ក្រោមជំពូក 64 (បុគ្គលិក) ចំណែកចំណាយទូទៅរបស់រដ្ឋាភិបាលលើអត្ថប្រយោជន៍សន្តិសុខសង្គម (ដែលជាផ្នែកមួយនៃចំណាយប្រាក់បៀវត្សរ៍រហូតដល់ឆ្នាំ 2018) មានចំនួន 0.8 ភាគរយនៃ ផសស ។ ចំណាយនេះត្រូវបានកំណត់ប្រភេទឡើងវិញក្រោមអត្ថប្រយោជន៍សន្តិសុខសង្គម (ជំពូក 62) ក្រោមប្រភេទមិនមែនប្រាក់បៀវត្សរ៍។ ជំពូក 62 ផ្តល់ហិរញ្ញប្បទានដល់អត្ថប្រយោជន៍សន្តិសុខសង្គមទាំងសម្រាប់មន្ត្រីរាជការ និងអតីតយុទ្ធជន។

### កញ្ចប់ថវិកាឆ្នាំ ២០១៩ បានបង្កើនចំណែកថវិកាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិចំនួន 30 ភាគរយ

**កញ្ចប់ថវិកាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិកើនឡើង 30 ភាគរយក្នុងកញ្ចប់ថវិកាឆ្នាំ 2019** ធៀបនឹងកំណើនតែ 5 ភាគរយនៅក្នុងថវិកាឆ្នាំ 2018។ ក្នុងនោះ ថវិការដ្ឋបាលថ្នាក់ខេត្ត/រាជធានីមានកំណើនច្រើនជាងគេគឺ 39.3 ភាគរយ។ ថវិកាសម្រាប់រដ្ឋបាលក្រុង/ស្រុកកើនឡើង 24 ភាគរយ ចំណែកថវិកាសម្រាប់ឃុំ/សង្កាត់កើនឡើង 20 ភាគរយ (តារាង 1)។

**ថវិកាឆ្នាំ 2019 កំណត់កម្រិតកំណត់នៃប្រាក់កម្ចី (ខាងក្រៅ) ចំនួន 1.4 ពាន់លាននៃសិទ្ធដកប្រាក់ពិសេស (SDR)។** អត្រានេះទាបជាងកម្រិតកំណត់ប្រាក់កម្ចីក្នុងកញ្ចប់ថវិកាឆ្នាំ 2018 ដែលមានរហូតដល់ 114 ពានលាននៃសិទ្ធិដកប្រាក់ពិសេស។ ដំបូងឡើយ កម្រិតកំណត់ប្រាក់កម្ចីឆ្នាំ 2018 (ខាងក្រៅ) ត្រូវបានកំណត់ត្រឹម 1 ពាន់លាននៃសិទ្ធិដកប្រាក់ពិសេស ប៉ុន្តែ ត្រូវបានកែសម្រួលក្នុងកញ្ចប់ថវិកាឆ្នាំ 2019 ដោយបង្កើនរហូតដល់ 514 ពាន់លាននៃសិទ្ធិដកប្រាក់ពិសេស។ ដូច្នេះ កម្រិតកំណត់ប្រាក់កម្ចីសរុបសម្រាប់កញ្ចប់ថវិកាឆ្នាំ 2018 កើនឡើងដល់ 1.514 ពាន់លាននៃសិទ្ធិដកប្រាក់ពិសេស។

## ទស្សនៈវិស័យ

### ដោយសារដំណើរការនាំចេញល្អជាងការរំពឹងទុក ទស្សនៈវិស័យកំណើនត្រូវបានកែសម្រួលឡើងវិញ ដោយធៀបនឹងការព្យាករពីមុន

**ទស្សនៈវិស័យកំណើនត្រូវបានកែសម្រួលឡើងវិញសម្រាប់រយៈពេលខ្លី** ធៀបនឹងការព្យាករពីមុនកាលពីខែ តុលា ឆ្នាំ 2018 (តារាង 2)។ ការកែសម្រួលនេះធ្វើឡើងដោយសារតែដំណើរការនាំចេញដែលល្អជាងការរំពឹងទុក កំណើននៃការប្រើប្រាស់ និងការសាងសង់។ ប៉ុន្តែ នៅពេលដែលការនាំចេញថយចុះបន្តិចដែលស្របនឹងការថយចុះតម្រូវការសកល (មើលប្រអប់ 1 ស្តីពីទស្សនៈវិស័យសេដ្ឋកិច្ចសកល និងតំបន់ និងហានិភ័យ) កំណើនពិតត្រូវបានព្យាករណ៍ថាមានអត្រា 7 ភាគរយនៅឆ្នាំ 2019 និងនៅតែមានអត្រាជិត 7 ភាគរយក្នុងរយៈពេលខ្លី។ គេរំពឹងថាសេដ្ឋកិច្ចកម្ពុជាដែលមានកំណើន 7.5 ភាគរយនៅឆ្នាំ ២០១៨ នឹងថយចុះមកត្រឹមអត្រារយៈពេលវែង 7 ភាគរយ។ កំណើនសេដ្ឋកិច្ចរឹងមាំត្រូវបានរំពឹងថានឹងជួយកាត់បន្ថយភាពក្រីក្រ។ ប៉ុន្តែ ទស្សនៈវិស័យរយៈពេលវែងអាស្រ័យលើសមត្ថភាពរបស់កម្ពុជាក្នុងការស្រូបយកលំហូរវិនិយោគទុនផ្ទាល់ពីបរទេសប្រកបដោយផលិតភាព និងការជំរុញការវិនិយោគក្នុងស្រុក។ មានសក្តានុពលក្នុងការរក្សាកំណើនល្អប្រសើរក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខ ប៉ុន្តែ ចាំបាច់ត្រូវដោះស្រាយបញ្ហារាំងស្ទះរចនាសម្ព័ន្ធជាមុនសិន។

**តារាង 1 ៖ ការបង្កើនកញ្ចប់ថវិកាសម្រាប់ថ្នាក់ក្រោមជាតិឆ្នាំ 2019**

| កញ្ចប់ថវិកាសម្រាប់ថ្នាក់ក្រោមជាតិ (លានរៀល) | កញ្ចប់ថវិកា ឆ្នាំ 2018 | កញ្ចប់ថវិកា ឆ្នាំ 2019 | ការប្រែប្រួល (ភាគរយ) |
|---|---|---|---|
| សរុប | 1,684,674 | 2,199,636 | 30.6% |
| រដ្ឋបាលខេត្ត/រដ្ឋធានី | 1,060,233 | 1,476,946 | 39.3% |
| *ក្នុងនោះមានការផ្ទេរ ពីរដ្ឋបាលកណ្តាល* | *148,814* | *83,808* | *-43.7%* |
| រដ្ឋបាលស្រុក/ក្រុង | 160,400 | 198,890 | 24.0% |
| *ក្នុងនោះមានការផ្ទេរពីរដ្ឋបាលកណ្តាល* | *155,015* | *192,060* | *23.9%* |
| រដ្ឋបាលឃុំ/សង្កាត់ | 434,041 | 523,800 | 20.7% |
| *ក្នុងនោះមានការផ្ទេរពីរដ្ឋបាលកណ្តាល* | *434,041* | *523,800* | *20.7%* |

*ប្រភព* ៖ ច្បាប់ស្តីពីថវិកាឆ្នាំ 2018 និង 2019 (អាជ្ញាធរកម្ពុជា)

**រូប 25 ៖ ចំណាយតាមការប៉ាន់ស្មានឆ្នាំ 2019**
(ភាគរយនៃ ផសស)




*ប្រភព* ៖ អាជ្ញាធរកម្ពុជា
*សម្គាល់* ៖ e= ការប៉ាន់ស្មាន b= ថវិកា

## ហានិភ័យ

**ហានិភ័យសំខាន់ៗរួមមានបណ្តុំនៃលំហូរការវិនិយោគទុនផ្ទាល់ពីប្រទេសចិន និងការផ្តល់ហិរញ្ញប្បទានដល់វិស័យមួយចំនួនតូច និងលទ្ធភាពនៃការព្យួរ EBA ជាបណ្តោះអាសន្ន។** ក្រៅពីនេះ បញ្ហាធាតុអាកាសបានបង្កជាហានិភ័យចំពោះការធ្វើកសិកម្ម។ កិច្ចខិតខំប្រឹងប្រែងរបស់អាជ្ញាធរកម្ពុជាក្នុងការជំរុញការប្រើប្រាស់រូបិយវត្ថុជាតិ ត្រូវបានរាំងស្ទះដោយកំណើននៃការដាក់ប្រាក់បញ្ញើជារូបិយវត្ថុបរទេស។

### កម្ពុជាពឹងផ្អែកកាន់តែខ្លាំងលើប្រទេសចិនក្នុងរក្សាបានការវិនិយោគទុនផ្ទាល់ពីបរទេស និងកំណើនភ្ញៀវទេសចរ

**លំហូរចូលនៃការវិនិយោគផ្ទាល់ពីចិនជាចំណែកច្រើននៃកំណើនលំហូរវិនិយោគបច្ចុប្បន្ន (រូប 26)។** ការថមថយ ឬការបង្វែរលំហូរចូលការវិនិយោគទុនផ្ទាល់ពីបរទេស ជាពិសេស ការវិនិយោគពីប្រទេសចិន នឹងប៉ះពាល់យ៉ាងខ្លាំងដល់ការវិនិយោគក្នុងវិស័យឯកជន និងកំណើន។ ហានិភ័យ គឺពាក់ព័ន្ធនឹងការថយចុះភ្លាមៗនៃការវិនិយោគទុនផ្ទាល់ពីប្រទេសចិន ព្រោះលំហូរចូលនេះភាគច្រើនមានប្រភពពីចិន។ ម្យ៉ាងវិញទៀត ឥទ្ធិពលសំណាយភាយពីប្រទេសដែលមានសេដ្ឋកិច្ចធំៗ ដូចជា ចិន អាចមានតាមរយៈការធ្វើពាណិជ្ជកម្ម និងប្រតិបត្តិការហិរញ្ញវត្ថុ។ ការវិនិយោគទុនផ្ទាល់ពីបរទេស និងវិស័យទេសចរណ៍ដែលទទួលបានឥទ្ធិពលសំណាយភាយកំណើនពីប្រទេសសេដ្ឋកិច្ចធំៗ ដូចជា ចិន អាចធ្វើឲ្យប៉ះពាល់ដល់អត្រាកំណើនរបស់កម្ពុជា។

**កម្ពុជាអាចរក្សាកំណើនចំនួនភ្ញៀវទេសចរ ដោយសារកំណើនភ្ញៀវទេសចរចិន។** ប្រសិនបើគ្មានការរួមចំណែកពីភ្ញៀវទេសចរចិនទេនោះ ចំនួនភ្ញៀវទេសចរសរុបនៅឆ្នាំ 2018 គួរតែបានថយចុះ (រូប 27)។ ដូចបានពិភាក្សាខាងលើ ភ្ញៀវទេសចរចិនមានចំនួនច្រើនជាងគេ (32.6 ភាគរយ ឬស្មើនឹងចំនួនភ្ញៀវទេសចរ 2.03 លាននាក់)។ រាល់ការធ្វើឲ្យអាក់ខានដល់លំហូរចូលនៃភ្ញៀវទេសចរចិន ដូចជា ការថយចុះសន្ទុះកំណើនសេដ្ឋកិច្ចចិន នឹងប៉ះពាល់ធ្ងន់ធ្ងរដល់វិស័យទេសចរណ៍ និងកំណើននៅកម្ពុជា។

**រូប 26 ៖ ការវិនិយោគទុនផ្ទាល់ពីចិនមានការកើនឡើង។ ការវិនិយោគទុនផ្ទាល់ពីបរទេសដែលត្រូវបានអនុម័ត**
(ភាគរយប្រែប្រួលធៀបនឹងឆ្នាំមុន)




*ប្រភព* ៖ អាជ្ញាធរកម្ពុជា

**រូប 27 ៖ ចំនួនភ្ញៀវទេសចរចិននៅតែបន្តកើនឡើង។ ចំនួនភ្ញៀវទេសចរ** (ភាគរយប្រែប្រួលធៀបនឹងឆ្នាំមុន)




*ប្រភព* ៖ អាជ្ញាធរកម្ពុជា

**តារាង 2 ៖ ភាពប្រសើរឡើងនៃទស្សនវិស័យម៉ាក្រូសេដ្ឋកិច្ចក្នុងរយៈពេលខ្លី និងរយៈពេលវែង ធៀបនឹងការព្យាករពីមុន**

| ភាគរយនៃ ផសស លុះត្រាតែមានការបញ្ជាក់ផ្សេងពីនេះ | 2019 | 2020 | 2021 |
|---|---|---|---|
| *ការព្យាករខែ តុលា ឆ្នាំ 2018* | *6.8* | *6.8* | - |
| **កំណើន ផសស (%)** | 7.0 | 6.9 | 6.8 |
| **តម្រូវការក្នុងស្រុក** (ភាគរយប្រែប្រួលធៀបនឹងឆ្នាំមុន) | 9.8 | 8.9 | 10.5 |
| **អតិផរណា** (ភាគរយប្រែប្រួល ៖ មធ្យមភាគ) | 3.3 | 3.0 | 3.1 |
| **តុល្យភាពសារពើពន្ធ** | -3.8 | -3.2 | -2.7 |
| **បំណុលរបស់រដ្ឋាភិបាល** | 30.0 | 30.1 | 31.1 |
| **កំណើនការនាំចេញ** (ភាគរយប្រែប្រួល) | 9.0 | 8.6 | 8.1 |
| **កំណើនការនាំចូល** (ភាគរយប្រែប្រួល) | 7.6 | 7.1 | 6.9 |
| **គណនីចរន្ត** | -9.5 | -9.1 | -9.2 |
| **ការវិនិយោគផ្ទាល់ពីបរទេស** | 10.4 | 9.3 | 9.2 |
| **ទុនបម្រុងអន្តរជាតិសរុប** (ចំនួនខែនៃការនាំចូល) | 6.6 | 6.2 | 6.0 |

*ប្រភព* ៖ ធនាគារពិភពលោក/មូលនិធិរូបិយវត្ថុអន្តរជាតិ ការវិភាគបំណុល និងការប៉ាន់ស្មាន និងការព្យាកររបស់ធនាគារពិភពលោក

*សម្គាល់* ៖ បំណុលរបស់រដ្ឋាភិបាលត្រូវបានព្យាករណ៍ថានឹងកើនឡើងបន្តិចដោយសារការបង្កើនកម្រិតកំណត់ប្រាក់កម្ចី។

**ប្រអប់ 1**

## ទស្សនវិស័យសេដ្ឋកិច្ចតំបន់ និងសកល និងហានិភ័យ[១]

កំណើនសកលត្រូវបានរំពឹងថានឹងមានស្ថិរភាពនៅអំឡុងឆ្នាំ 2020-2021 ក្រោយការងើបឡើងវិញពីការធ្លាក់ចុះជាបណ្ដោះអាសន្ននៅឆ្នាំ 2016។ អត្រាកំណើនសេដ្ឋកិច្ចសកលត្រូវបានព្យាករណ៍ថានឹងថយចុះមកត្រឹម 2.6 ភាគរយនៅឆ្នាំ 2019 ដែលឆ្លុះបញ្ចាំងពីការចុះខ្សោយជារួមរបស់បណ្ដាប្រទេសមានសេដ្ឋកិច្ចជឿនលឿន និងទីផ្សារងើបឡើងធំៗ និងប្រទេសដែលមានសេដ្ឋកិច្ចរីកចម្រើន នៅដើមឆ្នាំ 2019 មុននឹងសម្រេចបានអត្រាថេរ 2.8 ភាគរយនៅអំឡុងឆ្នាំ 2020-2021។ កំណើនរបស់បណ្ដាប្រទេសជឿនលឿន ត្រូវបានព្យាករណ៍ថានឹងថយចុះពី 2.1 ភាគរយនៅឆ្នាំ 2018 មកត្រឹម 1.7 ភាគរយនៅអំឡុងឆ្នាំ 2019-2021 ឆ្ពោះទៅរកអត្រាសក្ដានុពល ដោយសារតែបញ្ហាផ្នែកសមត្ថភាពមានកាន់តែច្បាស់ និងទីផ្សារការងាររួមតូច។ កំណើននៃទីផ្សារងើបឡើងធំៗ និងប្រទេសដែលមានសេដ្ឋកិច្ចរីកចម្រើនទាំងនេះត្រូវបានព្យាករណ៍ថានឹងថយចុះមកត្រឹម 4.0 ភាគរយនៅឆ្នាំ 2019 មុនពេលឈានឡើងដល់ 4.5 ភាគរយនៅអំឡុងឆ្នាំ 2020-2021 ដោយសារតែការងើបឡើងវិញរបស់ប្រទេសដែលមានសេដ្ឋកិច្ចរីកចម្រើនមួយចំនួនតូច (ឧ. អាហ្សង់ទីន អ៊ីរ៉ង់ តួគី) (រូប B1.1)[២]។

ស្ថានភាពសេដ្ឋកិច្ចសកលត្រូវបានរំពឹងថានៅតែប្រឈមនឹងវិបត្តិក្នុងអំឡុងពេលព្យាករណ៍នេះ។ ក្រៅពីការកើនឡើងនៃភាពតានតឹងផ្នែកពាណិជ្ជកម្ម កំណើនពាណិជ្ជកម្មសកលត្រូវបានព្យាករណ៍ថានឹងថយចុះមកត្រឹម 3.3 ភាគរយជាមធ្យមនៅអំឡុងឆ្នាំ 2019-2021 ដែលឆ្លុះបញ្ចាំងពីកំណើនយឺតក្នុងពិភពលោក និងភាពមិនប្រាកដប្រជាកាន់តែខ្លាំងនៃគោលនយោបាយសកល។ ស្ថានភាពហិរញ្ញប្បទានសកលត្រូវបានរំពឹងថានៅតែប្រឈមនឹងការប្រែប្រួល ទោះបីជាមានលក្ខណៈអនុគ្រោះក្ដី។ ចំណុចនេះឆ្លុះបញ្ចាំងពីគោលនយោបាយរូបិយវត្ថុកាន់តែល្អប្រសើររបស់ធនាគារជាតិសំខាន់ៗក្នុងរយៈពេលខ្លី ដោយសារតែទស្សនវិស័យកំណើនសកលមិនល្អ។ ទោះបីជាមានការងើបឡើងវិញក្នុងទីផ្សារក្នុងប្រទេសទាំងនោះ ចាប់ពីអំឡុងពេលកែតម្រូវឡើងវិញនៅឆ្នាំ 2018 ក្ដី នៅតែមានហានិភ័យជាច្រើននៃ "វិបត្តិរូបិយវត្ថុ" ដែលពាក់ព័ន្ធនឹងភាពមិនប្រាកដប្រជានៃគោលនយោបាយសកល។ ភាពងាយរងការប្រែប្រួលនៃទីផ្សារហិរញ្ញវត្ថុ នៅតែប៉ះពាល់ខ្លាំងលើបណ្ដាប្រទេសដែលមានភាពងាយរងគ្រោះខ្ពស់ ទស្សនវិស័យកំណើនខ្សោយ និងគោលនយោបាយមិនច្បាស់លាស់។ គេរំពឹងថា ប្រេងនឹងមានតម្លៃ 64 ដុល្លាក្នុងមួយបារ៉ែល នៅឆ្នាំ 2019 និង 65 ដុល្លាក្នុងមួយបារ៉ែល នៅឆ្នាំ 2020 ដោយមានទស្សនវិស័យមិនច្បាស់លាស់កាន់តែខ្លាំង។ បើទោះជាមានទស្សនវិស័យលើការថយចុះតម្រូវការ ប៉ុន្តែតម្លៃប្រេងត្រូវបានប៉ាន់ប្រមាណថានឹងមានស្ថិរភាពនៅឆ្នាំ 2019 និង 2020 ដោយសារការថយចុះកំណើនការផ្គត់ផ្គង់ និងកម្រិតសារពើភ័ណ្ឌទាប។ តម្លៃផលិតផលកសិកម្មត្រូវបានរំពឹងថានឹងមានអត្រាថេរក្នុងរយៈពេលពីរឆ្នាំខាងមុខ (រូប B1.2)។

[១] រៀបរៀងឡើងដោយ Ekaterine T. Vashakmadze, សេដ្ឋកិច្ចវិទូថ្នាក់ប្រទេសជាន់ខ្ពស់ ធនាគារពិភពលោក។

[២] ទាំងនេះជាការសន្និដ្ឋាននៅក្នុងការវិភាគ ដែលត្រូវបានបោះពុម្ពផ្សាយនៅក្នុងអត្ថបទស្ដីពីទស្សនវិស័យសេដ្ឋកិច្ចសកលរបស់ធនាគារពិភពលោក កាលពីខែ មករា ឆ្នាំ 2019។

**រូប B2.1 ៖ កំណើន ផសស ពិត** (ភាគរយ)




**រូប B2.2 ៖ ការព្យាករលើតម្លៃទំនិញពិភពលោក** (ជាតួលេខប្រាក់ដុល្លារអាមេរិក, 2010=100)




**រូប B2.3 ៖ កំណើនក្នុងតំបន់**




*ប្រភព* ៖ ហិរញ្ញវត្ថុអភិវឌ្ឍន៍ថ្នាក់សកល ខែ មករា ឆ្នាំ 2019 (នឹងមកដល់នៅពេលឆាប់ៗនេះ)

បន្ទាប់ពីថយចុះពី 6.3 ភាគរយនៅឆ្នាំ 2018 មកត្រឹម 6.0 ភាគរយនៅឆ្នាំ 2019 កំណើននៅអាស៊ីបូព៌ា និងប៉ាស៊ីហ្វិក ត្រូវបានព្យាករណ៍ថានឹងរក្សាបានអត្រាកំណើននៅអំឡុងឆ្នាំ 2020-2021។ ទស្សនវិស័យនេះផ្អែកលើការថយចុះនៃកំណើនសកលបន្តិចម្តងៗ និងការថយចុះយ៉ាងឆាប់រហ័សនៃពាណិជ្ជកម្មសកល រួមនឹងស្ថិរភាពថ្លៃទំនិញជារួម និងស្ថានភាពអនុគ្រោះនៃការផ្តល់ហិរញ្ញប្បទានសកល ជាពិសេសក្នុងរយៈពេលខ្លី។ មូលដ្ឋានសន្និដ្ឋានក៏សន្មតថា នឹងមានដំណោះស្រាយជាវិជ្ជមានចំពោះជម្លោះពាណិជ្ជកម្មរវាងចិន និងសហរដ្ឋអាមេរិក ហើយអាជ្ញាធរចិននឹងកែសម្រួលដោយជោគជ័យលើការឆ្លើយតបផ្នែកគោលនយោបាយរបស់ខ្លួនចំពោះភាពរាំងស្ទះ។ កំណើននៅប្រទេសចិនត្រូវបានព្យាករណ៍ថានឹងថយមកត្រឹម 6.2 ភាគរយនៅឆ្នាំ 2019 និង 2020 និងថយចុះបន្តទៀតមកត្រឹម 6.0 ភាគរយនៅឆ្នាំ 2021 ដោយសារតែការសម្រួលឲ្យមានតុល្យភាពឡើងវិញក្នុងប្រទេស និងពីខាងក្រៅ។ កំណើនរបស់បណ្តាប្រទេសផ្សេងទៀតក្នុងតំបន់ ត្រូវបានព្យាករណ៍ថានឹងមានអត្រាថេរប្រមាណ 5.2 ភាគរយក្នុងមួយឆ្នាំនៅអំឡុងឆ្នាំ 2019-2020។ តម្រូវការក្នុងប្រទេសដែលមានភាពរឹងមាំ ត្រូវបានរំពឹងថានឹងជួយប៉ះប៉ូវផលប៉ះពាល់អវិជ្ជមាននៃការនាំចេញដែលថយចុះ។ ខណៈដែលកំណើនក្នុងតំបន់ត្រូវបានព្យាករណ៍ថានៅតែរឹងមាំក្នុងរយៈពេលខ្លីខាងមុខ សក្តានុពលកំណើន ដែលធ្លាក់ចុះយ៉ាងខ្លាំងកាលពីមួយទសវត្សរ៍កន្លងមកដែលបង្ហាញពីកំណើនយឺតដែលអាចមានក្នុងប្រទេសចិន អាចនឹងធ្លាក់ចុះបន្ថែមទៀតក្នុងរយៈពេលវែង ដោយសារតែនិន្នាការប្រជាសាស្ត្រមិនល្អ ជាពិសេសនៅប្រទេសចិន ថៃ និងវៀតណាម។ ការវិវត្តផ្នែកប្រជាសាស្ត្រត្រូវបានព្យាករណ៍ថាមិនប៉ះពាល់កំណើននៅតាមបណ្តាប្រទេសក្នុងតំបន់ទេ(រូប B3.1)។

ហានិភ័យនៅតែជាបញ្ហា។ មានភាពមិនច្បាស់លាស់ច្រើនពាក់ព័ន្ធនឹងទស្សនវិស័យសេដ្ឋកិច្ចសកល ហើយការដោះស្រាយហានិភ័យនៅតែជាបញ្ហា។ បើទោះជាលំបាកនឹងសម្រេចបានក្នុងរយៈពេលខ្លី ប៉ុន្តែការថយចុះកំណើនខ្លាំងជាងការរំពឹងទុកនៅចិន តំបន់អឺរ៉ុប និងសហរដ្ឋអាមេរិក អាចធ្វើឲ្យសេដ្ឋកិច្ចសកលធ្លាក់ចុះ។ ភាពតានតឹងផ្នែកពាណិជ្ជកម្មដែលរីករាលដាលឡើងអាចធ្វើឲ្យរាំងស្ទះដល់សកម្មភាពសេដ្ឋកិច្ចសកលនៅខណៈមានសង្វាក់តម្លៃស្មុគស្មាញ។ ហានិភ័យនៃវិបត្តិហិរញ្ញវត្ថុធ្ងន់ធ្ងរ និងទូលំទូលាយ ដែលអាចប៉ះពាល់ជាអវិជ្ជមានលើទស្សនវិស័យសម្រាប់ទីផ្សារងើបឡើង និងប្រទេសដែលមានសេដ្ឋកិច្ចរីកចម្រើន នៅតែមានកម្រិតខ្ពស់ នៅពេលដែលមានកំណើនបំណុលក្នុងប្រទេសជាច្រើន។ ភាពមិនប្រាកដប្រជាផ្នែកគោលនយោបាយ និងហានិភ័យភូមិសាស្ត្រ នៅតែមានកម្រិតខ្ពស់ និងអាចមានផលអវិជ្ជមានលើទំនុកចិត្ត និងការវិនិយោគទាំងក្នុងប្រទេសរងផលប៉ះពាល់ និងជាសកល។ ភាពមិនច្បាស់លាស់ផ្នែកគោលនយោបាយមានកាន់តែច្រើនក្នុងប្រទេសតំបន់អឺរ៉ុបជាច្រើន រួមទាំងនៅចក្រភពអង់គ្លេស ដែលកំពុងដកខ្លួនចេញពីសហភាពអឺរ៉ុប និងនៅប្រទេសអ៊ីតាលីដែលបរាជ័យផ្នែកសារពើពន្ធបានធ្វើឲ្យមានការវាយតម្លៃទីផ្សារឡើងវិញដោយពិនិត្យទៅលើហានិភ័យក្នុងប្រទេស។

### ភាពមិនប្រាកដប្រជាកាន់តែខ្លាំងផ្នែកពាណិជ្ជកម្មបានបង្កើនហានិភ័យកាន់តែខ្ពស់

**ដូចបានពិភាក្សាខាងលើ កាលពីថ្ងៃទី 18 ខែ មករា ឆ្នាំ 2019 សហភាពអឺរ៉ុបបានយកពន្ធគយធម្មតាឡើងវិញលើអង្ករកម្ពុជាដែលមានចំនួន 175 អឺរ៉ូក្នុងមួយតោននៅឆ្នាំទី 1** ហើយបន្ថយមកត្រឹម 150 អឺរ៉ូក្នុងមួយតោននៅឆ្នាំទីពីរ និង 125 អឺរ៉ូក្នុងមួយតោននៅឆ្នាំទីបី[២៥]។ ក្រៅពីនេះ នៅខែ កុម្ភៈ សហភាពអឺរ៉ុបបានចាប់ផ្តើមដំណើរការមួយដែលអាចធ្វើឲ្យមានការព្យួរជាបណ្តោះអាសន្ននូវប្រព័ន្ធអនុគ្រោះពន្ធ EBA របស់កម្ពុជា[២៦]។ យោងតាមសហភាពអឺរ៉ុប ប្រព័ន្ធ EBA អាចនឹងត្រូវលុបចោល ប្រសិនបើប្រទេសទទួលផលប្រយោជន៍មិនគោរពសិទ្ធិមនុស្ស និងសិទ្ធិការងារសំខាន់ៗ។ ដំណើរការនេះ (ចាប់ផ្តើមនៅខែ កុម្ភៈ ឆ្នាំ 2019) រួមមានការត្រួតពិនិត្យល្អិតល្អន់ និងការធ្វើការជាមួយអាជ្ញាធរកម្ពុជារយៈពេល 6 ខែ ក្រោយមកមានរយៈពេល 3 ខែទៀតដែលសហភាពអឺរ៉ុបចេញរបាយការណ៍ផ្អែកលើលទ្ធផលរកឃើញ។ ក្រោយរយៈពេល 12 ខែ (ខែ កុម្ភៈ ឆ្នាំ 2020) គណៈកម្មការអឺរ៉ុបនឹងបញ្ចប់នីតិវិធីដោយមានការចេញសេចក្តីសម្រេចចុងក្រោយថាតើត្រូវដកការអនុគ្រោះពន្ធ ឬយ៉ាងណា។ គណៈកម្មការសហភាពអឺរ៉ុបនឹងសម្រេចពីវិសាលភាព និងថិរវេលានៃការដកការអនុគ្រោះពន្ធនេះ។ រាល់ការដកការអនុគ្រោះពន្ធនឹងចូលជាធរមានក្រោយរយៈពេល 6 ខែនៃការចេញសេចក្តីសម្រេច (ខែ សីហា ឆ្នាំ 2020)។

**ខ្លឹមសារសង្ខេបស្តីពីពន្ធរបស់សហភាពអឺរ៉ុប ប្រសិនបើមានការព្យួរ EBA លើផលិតផលសំខាន់ៗរបស់កម្ពុជាដែលត្រូវនាំចេញទៅកាន់ទីផ្សារសហភាពអឺរ៉ុប មានបង្ហាញក្នុងតារាងស្តីពីពន្ធ/វិធានការការពារ (តារាង 3)**។ ផលិតផលសំខាន់ៗរបស់កម្ពុជាដែលត្រូវនាំចេញទៅកាន់ទីផ្សារសហភាពអឺរ៉ុប រួមមានសម្លៀកបំពាក់ ស្បែកជើង កង់ និងអង្ករ។ ជារួម ពន្ធរបស់សហភាពអឺរ៉ុបលើផលិតផលសម្លៀកបំពាក់ ស្បែកជើង និងកង់ គឺ 12 ភាគរយ 16 ភាគរយ និង 10 ភាគរយ។ សហភាពអឺរ៉ុបបានដាក់វិធានការការពារលើអង្ករកម្ពុជា (175 អឺរ៉ូ ឬប្រមាណ 200 ដុល្លាក្នុងមួយតោននៅឆ្នាំទីមួយ) ដោយចាប់ផ្តើមពីថ្ងៃទី 18 ខែ មករា ឆ្នាំ 2019 និងបន្ថយមកត្រឹម 150 អឺរ៉ូក្នុងមួយតោននៅឆ្នាំទីពីរ និង 125 អឺរ៉ូក្នុងមួយតោននៅឆ្នាំទីបី[២៧]។

**ការនាំចេញសម្លៀកបំពាក់ មានចំនួនប្រមាណ 80 ភាគរយនៃការនាំចេញសរុបរបស់កម្ពុជាទៅកាន់ទីផ្សារសហភាពអឺរ៉ុប។** ដូច្នេះ ជាការសំខាន់ត្រូវប៉ាន់ស្មានពីផលប៉ះពាល់នៃការព្យួរ EBA លើការនាំចេញផលិតផលសម្លៀកបំពាក់របស់កម្ពុជា។ ក្នុងតារាង 4 ប្រភេទសំខាន់ៗនៃផលិតផលសម្លៀកបំពាក់ដែលផលិតនៅកម្ពុជាត្រូវជាប់ពន្ធ 12 ភាគរយ លើកលែងតែផលិតផលមានលេខកូដ 6104 នៅក្នុងប្រព័ន្ធសម្របសម្រួល (HS) ដែលត្រូវជាប់ពន្ធ 6.5-8 ភាគរយ។

### ការវិភាគការប្រែប្រួលតម្លៃផលិតផលនាំចេញ គឺ សម្លៀកបំពាក់ ស្បែកជើង អង្ករ និងកង់ ជួយកំណត់ទំហំផលប៉ះពាល់នៃការព្យួរ EBA

**ពន្ធរបស់សហភាពអឺរ៉ុប ប្រសិនបើមានការព្យួរ EBA នឹងបង្កើនតម្លៃផលិតផលរបស់កម្ពុជាដែលនាំចេញទៅទីផ្សារសហភាពអឺរ៉ុប។** ហេតុនេះ ទំហំនៃការប្រែប្រួលតម្លៃមានសារៈសំខាន់ក្នុងទស្សនៈទានគោលនយោបាយ។ ប្រសិនបើ ឧទាហរណ៍ តម្រូវការនៃការនាំចេញផលិតផលនេះមានការប្រែប្រួលតម្លៃ (ប្រសិនបើការប្រែប្រួលតម្លៃមានកម្រិតលើសពី 1) នោះ ការកើនឡើងតម្លៃផលិតផលដោយសារការព្យួរ EBA និងសន្មតថា ទំនិញផ្សេងទៀតមិនប្រែប្រួលថ្លៃ (ដូចជា គ្មានការឡើងថ្លៃទំនិញរបស់ប្រទេសនាំចេញផ្សេងទៀត) នឹងធ្វើឲ្យមានការថយចុះបរិមាណនាំចេញយ៉ាងច្រើន និងប៉ះពាល់ជាអវិជ្ជមានលើឧស្សាហកម្មកាត់ដេរនៅកម្ពុជា។ ជាជម្រើសមួយទៀត ប្រសិនបើតម្រូវការនាំចេញផលិតផលរបស់កម្ពុជាគ្មានការប្រែប្រួលតម្លៃ (ឧ. ប្រសិនបើការប្រែប្រួលតម្លៃមានកម្រិតតិចជាង 1) ឧស្សាហកម្មកាត់ដេររបស់កម្ពុជានឹងរងផលប៉ះពាល់តិចតួចពីការព្យួរ EBA។

**តារាង 3 ៖ ផលិតផលនាំចេញសំខាន់ៗរបស់កម្ពុជា និងអត្រាពន្ធរបស់សហភាពអឺរ៉ុប**

| លេខកូដប្រព័ន្ធសម្របសម្រួល (HS) | ផលិតផលនាំចេញសំខាន់ៗ | ចំណែក (%) | តម្លៃ* (លានដុល្លា) | ពន្ធ/ការធានាសុវត្ថិភាព |
|---|---|---|---|---|
| 61+62 | សម្លៀកបំពាក់ | 77.6 | 4,206.3 | 12% |
| 64 | ស្បែកជើង | 13.1 | 729.2 | 16% |
| 87 | កង់ | 6.1 | 331.7 | 10% |
| 10 | អង្ករ | 3.2 | 169.6 | កំពុងចាប់ផ្តើមក្នុងអត្រា 175 អឺរ៉ូ/តោន |

*សម្គាល់* ៖ * ជាតួលេខប៉ាន់ស្មានសម្រាប់ឆ្នាំ 2018 ព្រោះមានទិន្នន័យតែសម្រាប់រយៈពេល 11 ខែដំបូងក្នុងឆ្នាំ 2018 ប៉ុណ្ណោះ។
*ប្រភព* ៖ គេហទំព័ Comtrade របស់អង្គការសហប្រជាជាតិ https://comtrade.un.org/ និងកាលវិភាគបង់ពន្ធគយ, ទិន្នានុប្បវត្តិផ្លូវការរបស់សហភាពអឺរ៉ុប ៖ (https://eur-lex.europa.eu/legal-content/EN/TXT/PDF/?uri=OJ:L:2017:282:FULL&from=EN)

25 សេចក្តីថ្លែងការណ៍ គណៈកម្មការសហភាពអឺរ៉ុប ថ្ងៃទី 19 ខែ មករា ឆ្នាំ 2019។

26 ប្រព័ន្ធ EBA ត្រូវបានអនុម័តដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសហភាពអឺរ៉ុបលេខ 416/2001 ចុះថ្ងៃទី 28 ខែ កុម្ភៈ ឆ្នាំ 2001។ ប្រព័ន្ធនេះគឺជាគំនិតផ្តួចផ្តើមរបស់សហភាពអឺរ៉ុបដែលអនុញ្ញាតឲ្យមានការនាំចូលទំនិញគ្រប់ប្រភេទលើកលែងតែអាវុធពីប្រទេសដែលមានការអភិវឌ្ឍតិចបំផុត ទៅក្នុងប្រទេសក្នុងសហភាពអឺរ៉ុប ដោយមិនបង់ពន្ធ។ EBA គឺជាផ្នែកមួយនៃប្រព័ន្ធអនុគ្រោះពន្ធទូទៅរបស់សហភាពអឺរ៉ុបដែលបានអនុវត្តនៅថ្ងៃទី 5 ខែ មីនា ឆ្នាំ 2001 ដោយមិនកំណត់ថិរវេលា។ កម្ពុជាស្ថិតក្នុងចំណោមប្រទេសដែលមានការអភិវឌ្ឍតិចបំផុតទាំង 48 ដែលទទួលបានការអនុគ្រោះពន្ធនេះ ៖ https://trade.ec.europa.eu/doclib/press/index.cfm?id=1981&title=Cambodia-EU-launches-procedure-to-temporarily-suspend-trade-preferences

27 យោងតាមសេចក្តីសម្រេចរបស់គណៈកម្មការសហភាពអឺរ៉ុប កាលពីថ្ងៃទី 18 ខែ មករា សហភាពអឺរ៉ុបបានយកពន្ធគយធម្មតាឡើងវិញលើផលិតផលនេះក្នុងតម្លៃ 175 អឺរ៉ូក្នុងមួយតោននៅឆ្នាំទីមួយ និងកាត់បន្ថយមកត្រឹម 150 អឺរ៉ូក្នុងមួយតោននៅឆ្នាំទីពីរ និង 125 អឺរ៉ូ/តោននៅឆ្នាំទីបី ៖ http://trade.ec.europa.eu/doclib/press/index.cfm?id=1970។

### ប្រសិនបើមានការព្យួរ EBA ទំហំប៉ាន់ស្មាននៃការថយចុះការនាំចេញផលិតផលសម្លៀកបំពាក់ជាអតិបរមាទៅកាន់ទីផ្សារសហភាពអឺរ៉ុបគឺ 10.4 ភាគរយ

**ដោយប្រើប្រាស់ការប្រែប្រួលដែលមាននៅក្នុងការសិក្សាដែលមានស្រាប់ (ឧបសម្ព័ន្ធ 1) ទំហំប៉ាន់ស្មាននៃការថយចុះការនាំចេញផលិតផលសម្លៀកបំពាក់របស់កម្ពុជាទៅកាន់ទីផ្សារសហភាពអឺរ៉ុប គឺចាប់ពី 8.7 ភាគរយ (កូឡោនទី 5 នៃតារាង 5) រហូតដល់ 10.4 ភាគរយ** (កូឡោនទី 6) ប្រសិនបើមានការព្យួរ EBA ហើយក្រុមហ៊ុននាំចូលនឹងដាក់បញ្ចូលពន្ធទាំងអស់លើផលិតផលសម្លៀកបំពាក់ទៅអ្នកប្រើប្រាស់នៅសហភាពអឺរ៉ុប។ គិតជាបរិមាណ ដោយប្រើប្រាស់ទំហំនៃការនាំចេញសម្លៀកបំពាក់របស់កម្ពុជានៅឆ្នាំ 2018 អត្រាថយចុះដែលប៉ាន់ស្មានមានចាប់ពី 0.02 លានតោន (កូឡោនទី 8) រហូតដល់ 0.03 លានតោន (កូឡោនទី 9)។ គិតជាតម្លៃ ការប៉ាន់ស្មានលើការថយចុះការនាំចេញសម្លៀកបំពាក់គឺចន្លោះពី 320 លានដុល្លា (កូឡោនទី 11) និង 381.4 លានដុល្លា (កូឡោនទី 12)។

### ទំហំប៉ាន់ស្មាននៃការថយចុះការនាំចេញស្បែកជើងទៅកាន់ទីផ្សារសហភាពអឺរ៉ុបគឺ 25.2 ភាគរយ

**ដូចគ្នានេះដែរ ទំហំប៉ាន់ស្មាននៃការថយចុះការនាំចេញស្បែកជើង គឺ 25.2 ភាគរយ** (កូឡោនទី 6)។ បរិមាណ និងតម្លៃនៃការនាំចេញស្បែកជើងរបស់កម្ពុជា ត្រូវបានប៉ាន់ស្មានថានឹងថយចុះចំនួន 0.01 លានតោន (កូឡោនទី 9) និងទឹកប្រាក់ 128.5 លានតោន (កូឡោនទី 12)។ ដូច្នេះ ទំហំប៉ាន់ស្មាននៃការថយចុះការនាំចេញសម្លៀកបំពាក់ និងស្បែកជើងរបស់កម្ពុជា ប្រសិនបើមានការព្យួរ EBA មានទំហំទឹកប្រាក់ 510 លានដុល្លា ឬស្មើនឹង 5.4 ភាគរយនៃការនាំចេញផលិតផលសម្លៀកបំពាក់ និងស្បែកជើងសរុបរបស់កម្ពុជា។ កាលពីឆ្នាំមុន កម្ពុជានាំចេញផលិតផលសម្លៀកបំពាក់ និងស្បែកជើងក្នុងទំហំទឹកប្រាក់សរុប 9.5 ពាន់លានដុល្លា។ ក្នុងនោះ ទីផ្សារសហភាពអឺរ៉ុបទទួលផលិតផលចំនួន 33 ភាគរយ។

**នៅពេលមានការដាក់វិធានការការពាររបស់សហភាពអឺរ៉ុប ទំហំប៉ាន់ស្មាននៃការថយចុះបរិមាណអង្ករកម្ពុជាដែលនាំចេញទៅកាន់ទីផ្សារសហភាពអឺរ៉ុបគឺចាប់ពី 36.6 ភាគរយ** (កូឡោនទី 5) **រហូតដល់ 81.2 ភាគរយ** (កូឡោនទី 6)។ ដូចបានពិភាក្សាខាងលើ ចំនួនថយចុះជាក់ស្ដែងនៃបរិមាណអង្ករនាំចេញគឺ 57.8 ភាគរយធៀបនឹងខែមុន កាលពីខែ កុម្ភៈ ឆ្នាំ 2019[២៨]។ ដូច្នេះ បរិមាណថយចុះជាក់ស្ដែងគឺស្ថិតក្នុងចំនួនថយចុះប៉ាន់ស្មានខាងលើ។ គិតជាបរិមាណ ដោយប្រើប្រាស់បរិមាណនៃការនាំចេញអង្កររបស់កម្ពុជានៅឆ្នាំ 2018 ចំនួនថយចុះប៉ាន់ស្មានគឺចាប់ពី 0.10 លានតោន (កូឡោនទី 8) រហូតដល់ 0.21 លានតោន (កូឡោនទី 9)។ គិតជាតម្លៃ ចំនួនថយចុះប៉ាន់ស្មាននៃបរិមាណអង្ករនាំចេញគឺចន្លោះពី 65.1 លានដុល្លា (កូឡោនទី 11) រហូតដល់ 144.1 លានដុល្លា (កូឡោនទី 12)។ សម្រាប់ផលិតផលកង់ ការសិក្សាមិនបង្ហាញពីការប្រែប្រួលឡើយ។ ដូច្នេះ យើងមិនពិភាក្សាពីចំនួនថយចុះប៉ាន់ស្មាននៃផលិតផលនេះឡើយ។

**តារាង 4 ៖ ប្រភេទនៃផលិតផលសម្លៀកបំពាក់នាំចេញសំខាន់ៗរបស់កម្ពុជា និងអត្រាពន្ធរបស់សហភាពអឺរ៉ុប**

| លេខកូដ HS | ផលិតផលសម្លៀកបំពាក់សំខាន់ៗ | ចំណែក % (2017) | តម្លៃ (គិតជាលានដុល្លា, 2018*) | អត្រាពន្ធគយរបស់សហភាពអឺរ៉ុប |
|---|---|---|---|---|
| 6110 | អាវយឺត អាវចាក់។ល។ (ដេរ ឬចាក់) | 20.7 | 837.4 | 12% |
| 6104 | ឈុតស្ត្រី រ៉ូប សំពត់។ល។ និងខោជើងខ្លី (ដេរ ឬចាក់) | 15.6 | 642.5 | 6.5-8% |
| 6109 | អាវយឺតដៃខ្លី អាវវាលក្លៀក និងអាវកាក់ (ដេរ ឬចាក់) | 9.9 | 414.9 | 12% |
| 6204 | ឈុតស្ត្រី អាវធំ សំពត់រ៉ូប។ល។ និងខោជើងខ្លី | 12.1 | 536.5 | 12% |
| 6203 | ឈុតបុរស អាវធំ ខោជើងវែង។ល។ និងខោជើងខ្លី | 7.7 | 315.3 | 12% |
| 6205 | អាវបុរស | 2.2 | 84.8 | 12% |
| 6108 | ខោក្នុងស្ត្រី ខោទ្រនាប់ ខោអាវស្លៀកគេងយប់ អាវពាក់ងូតទឹក។ល។ (ដេរ ឬចាក់) | 3.2 | 134.5 | 12% |
| 6102 | អាវធំស្ត្រី អាវវាលក្លៀក។ល។ល (ចាក់/សូត្រ), o/t of hd 61.04) | 2.7 | 102.8 | 12% |
| 6112 | ឈុតកីឡា ឈុតជីស្គី និងឈុតហែលទឹក (ដេរ ឬចាក់) | 2.8 | 120.6 | 12% |
| 6103 | ឈុតបុរស អាវធំ ខោជើងវែង។លល និងខោជើងខ្លី (ដេរ ឬចាក់) | 3.2 | 146.2 | 12% |
| | សរុប (ផលិតផលសម្លៀកបំពាក់សំខាន់ៗទាំង 10 ប្រភេទ) | 80.2 | 3335.4 | |

*ប្រភព ៖* គេហទំព័រ Comtrade របស់អង្គការសហប្រជាជាតិ https://comtrade.un.org និងកាលវិភាគពន្ធគយ, ទិន្នានុប្បវត្តិផ្លូវការរបស់គណៈកម្មការអឺរ៉ុប ៖ (https://eurlex.europa.eu/legalcontent/EN/TXT/PDF/?uri=OJ:L:2017:282:FULL&from=EN)

*សម្គាល់ ៖* *ជាតួលេខប៉ាន់ស្មានសម្រាប់ឆ្នាំ 2018 ព្រោះមានទិន្នន័យតែសម្រាប់រយៈពេល 11 ខែដំបូងក្នុងឆ្នាំ 2018 ប៉ុណ្ណោះ។

[២៨] អង្ករគុណភាពខ្ពស់របស់កម្ពុជាលក់ក្នុងតម្លៃ 950-960 ដុល្លា/តោន ចំណែកអង្ករធម្មតា ឬអង្ករស លក់ក្នុងតម្លៃប្រមាណ 420 ដុល្លាក្នុងមួយតោន ៖ https://en.vietstock.vn/2019/02/kingdom-sees-minimal-change-in-rice-exports-between-2016-2018-41-348482.htm។

## ការកាត់បន្ថយចំណាយលើផលិតកម្ម និងការនាំចេញ អាចជួយសម្រាលផលប៉ះពាល់នៃការព្យួរ EBA បាន

**វិធានការបង្កើនភាពប្រកួតប្រជែងនឹងជួយសម្រាលផលប៉ះពាល់អវិជ្ជមានដែលអាចកើតមានឡើងដោយសារការព្យួរ EBA។** អាទិភាពចម្បងគឺការចាប់ផ្តើមការធ្វើកំណែទម្រង់រចនាសម្ព័ន្ធ ជាពិសេស កំណែទម្រង់ដែលអាចជួយកែលម្អបរិយាកាសវិនិយោគ និងកាត់បន្ថយចំណាយលើការធ្វើអាជីវកម្ម ដូចជា ការកំណត់តម្លៃថាមពលដែលមានភាពប្រកួតប្រជែង និងការកាត់បន្ថយចំណាយផ្នែកភស្តុភារ។ សូមមើលប្រអប់ 2 ស្តីពីវិធានការថ្មីៗរបស់អាជ្ញាធរកម្ពុជាដើម្បីសម្របសម្រួលពាណិជ្ជកម្ម និងកាត់បន្ថយចំណាយលើការធ្វើអាជីវកម្ម។ វិនិយោគិនបរទេសបញ្ជាក់ថា កម្លាំងពលកម្មដែលមានតម្លៃទាប ការលើកទឹកចិត្តខ្ពស់ផ្នែកពន្ធ និងការអនុគ្រោះពីទីផ្សារនាំចេញសំខាន់ៗ សុទ្ធសឹងជាហេតុផលដែលជំរុញឲ្យមានការវិនិយោគនៅកម្ពុជា។ នៅពេលដែលមានកំណើនប្រាក់ឈ្នួលយ៉ាងឆាប់រហ័ស ហើយកម្ពុជាកំពុងប្រឈមនឹងលទ្ធភាពនៃការព្យួរ EBA កម្ពុជាកាន់តែលែងសូវមានភាពទាក់ទាញហើយ។ ចំណាយលើការធ្វើអាជីវកម្មនៅកម្ពុជាបច្ចុប្បន្នមិនជំរុញការវិនិយោគ និងសហគ្រិនភាពក្នុងស្រុកឡើយ។ កម្ពុជាឈរនៅលំដាប់ទី 185 ក្នុងចំណោមប្រទេសទាំង 190 ដែលផ្តល់ភាពងាយស្រួលដល់ការធ្វើអាជីវកម្ម។ ចំណាយលើពាណិជ្ជកម្មពឹងផ្អែកយ៉ាងខ្លាំងលើរចនាសម្ព័ន្ធនៃការនាំចេញរបស់កម្ពុជា និងដំណើរការរបស់ក្រុមហ៊ុននាំចេញ។ ការរួមចំណែកនៃវិស័យដឹកជញ្ជូន និងភស្តុភារដល់តម្លៃបន្ថែមនៃការនាំចេញសរុបពីកម្ពុជា កើនដល់ 14 ភាគរយ។ នេះជាអត្រាច្រើនជាងពីរដងធៀបនឹងអត្រារួមចំណែករបស់វិស័យទាំងនេះក្នុងប្រទេសថៃ និងច្រើនជាង 3.5 ដងធៀបនឹងអត្រានៅម៉ាឡេស៊ី ឬវៀតណាម[២៩]។ គុណភាព និងអាំងតង់ស៊ីតេនៃទំនាក់ទំនងសង្វាក់ផ្គត់ផ្គង់រវាងការវិនិយោគផ្ទាល់ពីបរទេស និងក្រុមហ៊ុននៅកម្ពុជា មានកម្រិតទាប។ ក្នុងរយៈពេលខ្លី និងមធ្យម ដោយសារតែចំនួនច្រើននៃការវិនិយោគផ្ទាល់ពីបរទេសនៅកម្ពុជា គោលបំណងគោលនយោបាយយូរអង្វែងដើម្បីសម្របសម្រួលទំនាក់ទំនងផ្នែកខាងក្រោយសម្រាប់ក្រុមហ៊ុនក្នុងស្រុក សំដៅបង្កើនផលិតភាព និងច្បាមយកការរម្លេកចំណេះដឹង ត្រូវអនុវត្តឲ្យបានហ្មត់ចត់។

**តារាង 5 ៖ ការប៉ាន់ស្មានពីការថយចុះបរិមាណនៃការនាំចេញទៅកាន់ទីផ្សារសហភាពអឺរ៉ុប ប្រសិនបើមានការព្យួរ EBA**

| | | ការប្រែប្រួលតម្រូវការ (ពីការសិក្សាមានស្រាប់)[៣] | | ការប៉ាន់ស្មានការថយចុះបរិមាណដែលត្រូវការ(%) | | បរិមាណ (លានតោន)[១] | | | តម្លៃ (លានដុល្លា) | | |
|---|---|---|---|---|---|---|---|---|---|---|---|
| 1 | 2 | 3 | 4 | 5=2x3 | 6=2x4 | 7 | 8-5x7 | 9=6x7 | 10 | 11-5x10 | 12=6x10 |
| ផលប៉ះពាល់នៃការព្យួរ EBA | អត្រាពន្ធរបស់ EU (%)[២] | អប្បបរមា | អតិបរមា | អប្បបរមា | អតិបរមា | ការនាំចេញ (2018) | ការប៉ាន់ស្មានបរិមាណថយចុះអប្បបរមា | ការប៉ាន់ស្មានបរិមាណថយចុះអតិបរមា | ការនាំចេញ(2018) | ការប៉ាន់ស្មានតម្លៃថយចុះអប្បបរមា | ការប៉ាន់ស្មានតម្លៃថយចុះអតិបរមា |
| សម្លៀកបំពាក់ | 12.0 | -0.73 | -0.87 | -8.76 | -10.44 | 0.27 | -0.02 | -0.03 | 3,653.4 | -320.0 | -381.4 |
| ស្បែកជើង | 16.0 | -1.58 | | -25.28 | | 0.04 | -0.01 | | 508.1 | -128.5 | |
| អង្ករ | 26.2 | -1.40 | -3.10 | -36.68 | -81.22 | 0.26 | -0.10 | -0.21 | 177.5 | -65.1 | 144.1 |
| សរុបរង | | | | | | | | | 4,339.0 | -513.6 | -654.0 |
| កង់[៤] | 10.0 | | | | | 1.52 | | | 331.07 | | |
| សរុប | | | | | | | | | 4,670.1 | | |

*ប្រភព* ៖ ការប៉ាន់ស្មានរបស់អ្នកនិពន្ធដោយប្រើប្រាស់ទិន្នន័យពីអាជ្ញាធរកម្ពុជា កាលវិភាគពន្ធគយរបស់សហភាពអឺរ៉ុប និងការប្រែប្រួលដែលលើកឡើងក្នុងឧបសម្ព័ន្ធ 1។

*សម្គាល់* ៖ 1 ការនាំចេញសម្លៀកបំពាក់ ស្បែកជើង និងអង្ករ គិតជាលានតោន ចំណែកកង់គិតជាលានគ្រឿង។

2 សម្រាប់ការនាំចេញអង្កររបស់កម្ពុជា តួលេខនេះផ្អែកតាមវិធានការការពាររបស់សហភាពអឺរ៉ុប។

3 សូមមើលឧបសម្ព័ន្ធ 1 ស្តីពីការប្រែប្រួលដែលបានលើកឡើងក្នុងការសិក្សាផ្សេងៗ។

4 សម្រាប់កង់ ការប្រែប្រួលមិនត្រូវបានបង្ហាញក្នុងការសិក្សាណាមួយឡើយ។

[២៩] សូមមើលប្រអប់ 1 ៖ ការពិនិត្យឡើងវិញលើបរិយាកាសវិនិយោគនៅកម្ពុជា ៖ មេរៀនសម្រាប់ភាពប្រកួតប្រជែងនាពេលអនាគត។ សម្រាប់ខ្លឹមសារលម្អិត សូមមើល បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា ខែ តុលា ឆ្នាំ 2018។

ប្រអប់ 2

## វិធានការសម្របសម្រួលការធ្វើពាណិជ្ជកម្ម និងកាត់បន្ថយចំណាយលើការធ្វើអាជីវកម្ម ដែលបានអនុវត្តកាលពីខែ មីនា ឆ្នាំ 2019

នៅក្នុងវេទិការវាងរដ្ឋាភិបាល និងវិស័យឯកជនកាលពីថ្ងៃទី 29 ខែ មីនា ឆ្នាំ 2019 អាជ្ញាធរកម្ពុជាបានប្រកាសអនុវត្តវិធានការខាងក្រោម ក្នុងការសម្រួលដល់ការធ្វើពាណិជ្ជកម្ម និងកាត់បន្ថយចំណាយលើការធ្វើធុរៈកិច្ច៖

- ការដកតួនាទីត្រួតពិនិត្យរបស់អគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យនីហរ័ណអាហារ័ណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល) នៅតាមច្រកអន្តរជាតិ ដែលរួមមាន ច្រកឆ្លងកាត់ព្រំដែន ដូចជា ប៉ុស្តិ៍ត្រួតពិនិត្យ កំពង់ផែសមុទ្រ តំបន់សេដ្ឋកិច្ចពិសេស និងតំបន់ត្រួតពិនិត្យការនាំចេញនាំចូលនៅកម្ពុជា។
- លុបចោលទីភ្នាក់ងារនាវាចរកម្ពុជា និងជើងសារ (កាំសាប) (គ្រប់គ្រងដោយរដ្ឋ)។
- លុបចោលការចេញវិញ្ញាបនបត្រប្រភពដើម (CO) សម្រាប់ការនាំចេញទំនិញ លើកលែងតែមានការកំណត់ដោយប្រទេសនាំចូល (ប្រកាសអន្តរក្រសួងលេខ 1627 រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម)
- កាត់បន្ថយចំណាយផ្នែកភស្តុភារ ដូចជា ចំណាយលើការផ្ទុក និងកម្រៃសេវាទាំងនៅកំពង់ផែស្វយ័តភ្នំពេញ និងព្រះសីហនុ។ កម្រៃសេវាទាំងនេះរួមមាន តម្លៃផែ ដែលត្រូវបានកាត់បន្ថយ 5 ដុល្លាក្នុងមួយឯកតាសមមូលនឹង ២០ ហ្វូត (TEU) និងតម្លៃកុងតេន័រដែលត្រូវបានកាត់បន្ថយ 20 ដុល្លា (ថយចុះពី 120 ដុល្លា មកត្រឹម 100 ដុល្លា) សម្រាប់កុងតេន័រប្រវែង 20 ហ្វូត និង 40 ដុល្លា (ថយចុះពី 240 ដុល្លាមកត្រឹម 200 ដុល្លា សម្រាប់កុងតេន័រប្រវែង 40 ហ្វូត។ តម្លៃដឹកជញ្ជូនតាមសមុទ្រត្រូវបានកាត់បន្ថយ 50 ភាគរយ (ភស្តុភារកម្ពុជា SITC ឯកភាព)។ តម្លៃកុងតេន័រធំ ត្រូវបានលុបចោល។ ពីមុន មានការគិតកម្រៃសេវា 15 ដុល្លាសម្រាប់កុងតេន័រប្រវែង 20 ហ្វូត, 30 ដុល្លាសម្រាប់កុងតេន័រប្រវែង 30 ហ្វូត និង 30 ដុល្លាសម្រាប់កុងតេន័រប្រវែង 40 ហ្វូត។ កម្រៃសេវាលើកដាក់នៅកំពង់ផែព្រះសីហនុត្រូវបានកាត់បន្ថយ 10 ភាគរយ ចំណែក bonus ត្រូវបានកាត់បន្ថយមកត្រឹម 5 ដុល្លាក្នុងមួយប្រអប់ ដោយថយចុះពីអត្រា 7.5 ដុល្លាក្នុងមួយប្រអប់ហើយ shifting មិនគិតកម្រៃសេវាឡើយ។ កំពង់ផែភ្នំពេញកំពុងពិចារណាពីការកាត់បន្ថយតម្លៃលើកដាក់ទំនិញ តម្លៃច្រកផ្លូវ តម្លៃកុងតេន័រនាំចេញ និងតម្លៃស្តុកលើកឡើងចុះ។
- ការបញ្ចុះតម្លៃអគ្គិសនីនឹងត្រូវលើកមកពិភាក្សាដើម្បីឆ្លើយតបនឹងកំណើនតម្រូវការរយៈពេលខ្លី និងមធ្យមក្នុងប្រទេស។
- រដ្ឋាភិបាលបានប្រកាសពីគោលនយោបាយគាំទ្រសហគ្រាសខ្នាតតូច និងមធ្យម មានជាអាទិ៍ ការបង្កើតធនាគារសហគ្រាសទាំងនេះ ដែលមានដើមទុនដំបូងប្រមាណ 100 លានដុល្លា មូលនិធិសហគ្រិនភាព ដោយមានថវិកាប្រមាណ 5 លានដុល្លាក្នុងមួយឆ្នាំ និងការលើកទឹកចិត្តផ្នែកពន្ធសម្រាប់សហគ្រាសទាំងនេះក្នុងវិស័យអាទិភាព 6 ដែលពាក់ព័ន្ធនឹងកសិឧស្សាហកម្ម និងផលិតកម្ម និងការកែច្នៃអាហារ។
- វិធានការសម្របសម្រួលពាណិជ្ជកម្មក្រោមពន្ធគយរួមមាន ប្រកាសស្តីពីការទទួលការចំណាយលើពន្ធគយស្វ័យប្រវត្តិកម្ម និងមានតម្លាភាព។ ក្រោយការអនុវត្តចាប់ពីថ្ងៃទី 1 ខែ មេសា ឆ្នាំ 2019 កម្រៃសេវាលើការពិនិត្យកុងតេន័រថយចុះ 50 ភាគរយ ដោយថយពី 20 ដុល្លាមកត្រឹម 10 ដុល្លាសម្រាប់កុងតេន័រប្រវែង 20 ហ្វូត និងថយពី 32 ដុល្លាមកត្រឹម 16 ដុល្លាសម្រាប់កុងតេន័រប្រវែង 40 ហ្វូត ព្រមទាំងមានការអនុវត្តការពិនិត្យកុងតេន័រផ្អែកតាមហានិភ័យ។
- វិធានការពាក់ព័ន្ធនឹងការគ្រប់គ្រងពន្ធ រួមមាន ការដកប្រាក់ និងឥណទានពន្ធតម្លៃបន្ថែម រយៈពេលធ្វើសវនកម្មលើពន្ធ ត្រឡប់មកធ្វើរៀងរាល់ 3 ឆ្នាំ ( ប្តូរពីការធ្វើ 10 ឆ្នាំម្តង) ចំណែកការពិន័យលើការបង់ពន្ធយឺតយ៉ាវត្រូវបានកាត់បន្ថយមកត្រឹម 1.5 ភាគរយក្នុងមួយខែ (ថយពី 2 ភាគរយក្នុងមួយខែ)។
- កាត់បន្ថយចំនួនថ្ងៃឈប់សម្រាកបុណ្យជាតិចំនួន 7 ថ្ងៃ ចាប់ពីឆ្នាំ 2020 តទៅ។ បច្ចុប្បន្ន កម្ពុជាមានថ្ងៃឈប់សម្រាកបុណ្យជាតិចំនួនពី 28 ទៅ 30 ថ្ងៃក្នុងមួយឆ្នាំ។ តាមការប៉ាន់ស្មាន ការកាត់បន្ថយចំនួនថ្ងៃនេះធ្វើឲ្យមានកំណើនសេដ្ឋកិច្ចចំនួន 0.5 ភាគរយ។
- ការចុះធ្វើអធិការកិច្ចរោងចក្ររួមតែមួយ (ដោយទីភ្នាក់ងារផ្សេងៗ) ដោយអនុវត្តដោយក្រុមអធិការកិច្ចតែមួយ និងធ្វើតែម្តងក្នុងមួយឆ្នាំ។
- ពន្លឿនការធ្វើវិសោធនកម្មច្បាប់ស្តីពីការវិនិយោគ និងបញ្ចប់សេចក្តីព្រាងច្បាប់ស្តីពីតំបន់សេដ្ឋកិច្ចពិសេស ដែលនឹងត្រូវបញ្ចប់រួចរាល់នៅឆមាសទីមួយក្នុងឆ្នាំ 2019។ ជាគោលការណ៍ ការលើកទឹកចិត្តនឹងត្រូវដកចេញពីច្បាប់ស្តីពីការវិនិយោគបញ្ចូលទៅក្នុងច្បាប់ស្តីពីថវិកា។
- ច្បាប់ស្តីពីការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនឹងត្រូវបញ្ចប់រួចរាល់ត្រឹមពាក់កណ្តាលឆ្នាំ 2019។




*ប្រភព ៖* វេទិការវាងរដ្ឋាភិបាល និងវិស័យឯកជនលើកទី 18 ថ្ងៃទី 29 ខែ មីនា ឆ្នាំ 2019

**ការលុបបំបាត់កង្វះខាតជំនាញក៏ជាកត្តាសំខាន់ក្នុងរយៈពេលខ្លីដែរ ចំណែកការដោះស្រាយកង្វះមូលធនមនុស្សត្រូវធ្វើឡើងឲ្យបានលឿនបំផុត ដើម្បីគាំទ្រដល់គោលបំណងរយៈពេលវែងរបស់កម្ពុជា។** អាទិភាពចម្បងគឺការផ្តោតលើសុខភាព និងអាហារូបត្ថម្ភសម្រាប់វ័យកុមារភាព។ សូមមើលការពិភាក្សាលម្អិតស្តីពីកង្វះជំនាញ និងមូលធនមនុស្សនៅកម្ពុជាក្នុងផ្នែកស្តីពីអត្ថបទជម្រើសដែលមានចំណងជើងថា "វិនិយោគលើអនាគតរបស់កម្ពុជា ៖ សុខភាព និងអាហារូបត្ថម្ភសម្រាប់វ័យកុមារភាព" ខាងក្រោម។

### ការកាត់បន្ថយភាពងាយរងគ្រោះផ្នែកម៉ាក្រូសេដ្ឋកិច្ចគឺជាការចាំបាច់បំផុត

**ត្រូវពិចារណាបន្ថែមទៀតលើវិធានការប្រុងប្រយ័ត្នផ្នែកម៉ាក្រូសេដ្ឋកិច្ច ដូចជា ការកំណត់របស់ធនាគារចំពោះភាពងាយរងការប៉ះពាល់របស់វិស័យសំណង់ និងអចលនទ្រព្យ ដើម្បីកាត់បន្ថយភាពងាយរងគ្រោះរបស់វិស័យធនាគារចំពោះកំណើនការសាងសង់។** ដោយសារតែកំណើនឥណទានក្នុងស្រុកជាបន្តបន្ទាប់ ដែលគាំទ្រភាគច្រើនដល់កំណើនវិស័យសំណង់ និងអចលនទ្រព្យ ដូច្នេះ ការពង្រឹងសមត្ថភាពត្រួតពិនិត្យ និងការត្រៀមខ្លួនទប់ទល់នឹងវិបត្តិក្នុងវិស័យហិរញ្ញវត្ថុ គឺជាវិធីឆ្ពោះទៅមុខ។ កំណើននាពេលថ្មីៗនេះនៃលំហូរការវិនិយោគផ្ទាល់ពីបរទេស អាចថាបានជួយរក្សាកំណើនវិស័យសំណង់ទៅមុខ និងលាក់បាំងភាពងាយរងគ្រោះរបស់វិស័យហិរញ្ញវត្ថុ បន្ទាប់ពីមានការផ្តល់កម្ចីយ៉ាងឆាប់រហ័សកាន់តែច្រើនឡើងក្នុងរយៈពេលជាច្រើនឆ្នាំ។ យ៉ាងណាក៏ដោយ លំហូរចូលយ៉ាងច្រើននៃការវិនិយោគផ្ទាល់ពីបរទេសដែលបច្ចុប្បន្នភាគច្រើនផ្តោតទៅវិស័យសំណង់ ហាក់ដូចជាគ្មាននិរន្តរភាពទេ ព្រោះថា លំហូរចូលនេះតម្រូវឲ្យមានកំណើននៃភាពប្រកួតប្រជែងផ្នែកខាងក្រៅដែលអាចសម្រេចបានតែក្នុងរយៈពេលវែងទេ។ ការថយចុះច្រើននៃលំហូរការវិនិយោគពីបរទេស អាចបើកបង្ហាញពីភាពងាយរងការប៉ះពាល់ និងការប្រឈមនៃវិស័យធនាគារ។







ផ្នែកទី 2

# អត្ថបទជម្រើស៖
# វិនិយោគលើអនាគតរបស់កម្ពុជា៖
# សុខភាព និងអាហារូបត្ថម្ភសម្រាប់វ័យកុមារ

# អត្ថបទជម្រើស៖
## វិនិយោគលើអនាគតរបស់កម្ពុជា៖ សុខភាព និងអាហារូបត្ថម្ភសម្រាប់វ័យកុមារភាព[៣០]

### ១.សេចក្តីផ្តើម

កុមារកម្ពុជាដែលកើតនាពេលបច្ចុប្បន្ននេះនឹងចូលទៅក្នុងទីផ្សារការងារនៅខ្ទង់ឆ្នាំ 2040 ដែលជាពេលដ៏ល្អក្នុងការជំរុញឲ្យកម្ពុជាសម្រេចគោលដៅយ៉ាងធំក្នុងការក្លាយខ្លួនទៅជាប្រទេសដែលមានប្រាក់ចំណូលកម្រិតខ្ពស់។ បច្ចុប្បន្ននេះជាពេលដែលត្រូវសួរសំណួរទាំងនេះ ៖ តើកម្ពុជាត្រៀមខ្លួនរួចជាស្រេចសម្រាប់សេដ្ឋកិច្ចនាពេលអនាគតហើយឬនៅ? តើការកែលម្អវិស័យអប់រំអាចគ្រប់គ្រាន់ដើម្បីជំរុញការត្រៀមខ្លួននេះដែរឬទេ? ប្រសិនបើមិនគ្រប់គ្រាន់ទេ តើត្រូវមានការកែលម្អអ្វីផ្សេងទៀតដើម្បីលើកកម្ពស់គុណភាពកម្លាំងពលកម្ម និងកែលម្អមាគ៌ាអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា? ផ្អែកលើភស្តុតាងយ៉ាងច្រើនស្តីពីមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍវិស័យអប់រំ និងជំនាញ របាយការណ៍នេះមានគោលបំណងឆ្លើយសំណួរទាំងនេះ តាមរយៈ ១) ការសង្ខេបព័ត៌មានដែលបានដឹងស្តីពីការកសាងមូលធនមនុស្សរបស់កម្ពុជា និងការអភិវឌ្ឍសេដ្ឋកិច្ច ដោយផ្តោតលើតួនាទីនៃសុខភាព និងអាហារូបត្ថម្ភសម្រាប់វ័យកុមារភាព និង ២) ការយកលទ្ធផលសំខាន់ៗពីការសិក្សាថ្មីៗមកប្រើដើម្បីកំណត់បញ្ហាប្រឈម និងឱកាសសំខាន់ៗដើម្បីកែលម្អស្ថានភាពអាហារូបត្ថម្ភសម្រាប់វ័យកុមារភាព ព្រមទាំងបង្កើនការត្រៀមកម្លាំងពលកម្មសម្រាប់អនាគតរបស់កម្ពុជាដើម្បីជួយសម្រេចគោលដៅអភិវឌ្ឍន៍របស់កម្ពុជា។

### ២.មូលធនមនុស្ស និងការរួមចំណែកនៃមូលធនមនុស្សដល់ការអភិវឌ្ឍសេដ្ឋកិច្ចរបស់កម្ពុជា

**មានភស្តុតាងកាន់តែច្រើនបង្ហាញពីភាពចាំបាច់ត្រូវវិនិយោគលើមូលធនមនុស្សដើម្បីជំរុញវឌ្ឍនភាពសេដ្ឋកិច្ច និងការអភិវឌ្ឍប្រកបដោយនិរន្តរភាព។** ខណៈដែលការកសាងមូលធនមនុស្សផ្តល់ផលប្រយោជន៍ច្រើនជាចំណេះក្នុងខ្លួន និងជាលក្ខណៈបុគ្គល អត្ថប្រយោជន៍ទាំងនេះមានទៅដល់មនុស្សផ្សេងទៀត និងសេដ្ឋកិច្ចទាំងមូល។ ការប៉ាន់ស្មានថ្មីៗបង្ហាញថា មូលធនមនុស្ស[៣១] មានចំនួនជាងពីរភាគបីនៃទ្រព្យសម្បត្តិសរុបក្នុងពិភពលោក (ប៉ាន់ស្មានថាមានចំនួន 1,143 ទ្រីលាននៅឆ្នាំ 2014)។ ពីមុនធនធានដែលផលិតបាន (អគារ គ្រឿងម៉ាស៊ីន និងហេដ្ឋារចនាសម្ព័ន្ធ) និងធនធានធម្មជាតិ (ដីកសិកម្ម ព្រៃឈើ តំបន់ការពារ រ៉ែ ប្រេង ធ្យូងថ្ម ធនធានឧស្ម័ន) ត្រូវបានចាត់ទុកថាជាមូលដ្ឋាននៃទ្រព្យសម្បត្តិជាតិ។ ទើបតែពេលថ្មីៗនេះទើបទ្រព្យសម្បត្តិសកលត្រូវបានរាប់បញ្ចូលទាំង មូលធនមនុស្ស ឬបរិមាណសរុបនៃជំនាញ សុខភាព ចំណេះដឹង និងភាពរឹងមាំរបស់ប្រជាជន ថាជាសមាសភាពជាក់លាក់នៃទ្រព្យសម្បត្តិជាតិ និងដំណើរការសេដ្ឋកិច្ចរបស់ប្រទេស (Lange និងអ្នកនិពន្ធផ្សេង ឆ្នាំ 2018)។

**ការលើកកម្ពស់គុណភាពមូលធនមនុស្សរបស់កម្ពុជា គឺជាគោលបំណងចម្បងរបស់កម្ពុជាក្នុងការសម្រេចបានឋានៈជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ត្រឹមឆ្នាំ 2030 និងជាប្រទេសដែលមានប្រាក់ចំណូលខ្ពស់ត្រឹមឆ្នាំ 2050[៣២]។** មូលធនមនុស្សកាន់តែមានសារៈសំខាន់ នៅពេលដែលប្រទេសឡើងចំណាត់ថ្នាក់ប្រាក់ចំណូលរបស់ខ្លួន។ មូលធនមនុស្សមានចំណែក 51 ភាគរយនៃទ្រព្យសម្បត្តិសរុបរបស់បណ្តាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាប ហើយចំណែកនេះកើនទៅ 70 ភាគរយនៃទ្រព្យសម្បត្តិសរុបរបស់បណ្តាប្រទេសដែលមានប្រាក់ចំណូលខ្ពស់របស់អង្គការ OECD (Lange និងអ្នកនិពន្ធផ្សេង ឆ្នាំ 2018)។ សមត្ថភាពរបស់កម្លាំងពលកម្មក្នុងការធ្វើអន្តរកម្ម និងប្រែក្លាយមូលធនធម្មជាតិ និងធនធានដែលផលិតបាន ជាការចាំបាច់ក្នុងការបង្កើនលទ្ធផលសេដ្ឋកិច្ច។ ដូច្នេះសមត្ថភាពរបស់កម្ពុជាក្នុងការសម្រេចបានឋានៈជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់គឺជាការសំខាន់។

**យ៉ាងណាក៏ដោយ ចំពោះការអភិវឌ្ឍមូលធនមនុស្ស កម្ពុជាស្ថិតនៅកម្រិតទាប បើប្រៀបធៀបនឹងប្រទេសក្នុងតំបន់ និងសេដ្ឋកិច្ច ដូចគ្នា (តារាង S1)។** កម្ពុជាសម្រេចបានការរីកចម្រើនយ៉ាងច្រើនតាំងពីពាក់កណ្តាលទសវត្សរ៍ឆ្នាំ 1990 មក។ ប៉ុន្តែក្នុងអត្រា 43.3 ភាគរយ សម្បត្តិមូលធនមនុស្សរបស់កម្ពុជាស្ថិតក្រោមមធ្យមភាគរបស់បណ្តាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាប (50.6 ភាគរយ) និងបណ្តាប្រទេសក្នុងតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក (60.2 ភាគរយ)។

**កាលពីខែ តុលា ឆ្នាំ 2018 ធនាគារពិភពលោកបានណែនាំសន្ទស្សន៍មូលធនមនុស្ស(HCI) ជាម៉ាទ្រីស សម្រាប់ព្យាករណ៍មូលធនមនុស្សរបស់ប្រទេស (ប្រអប់ S1)។** សន្ទស្សន៍នេះកំណត់ពីផលប៉ះពាល់នៃការវិនិយោគលើកុមារបច្ចុប្បន្នចំពោះផលិតភាពនាពេលអនាគត និងកំណើនសេដ្ឋកិច្ចរយៈពេលវែង។

---

[៣០] កំណត់សម្គាល់នេះត្រូវបានរៀបរៀងឡើងដោយ Anne Marie Provo និង Somil Nagpal។

[៣១] ត្រូវបានប៉ាន់ស្មានជាតម្លៃបច្ចុប្បន្ននៃប្រាក់ចំណូលនាពេលអនាគតសម្រាប់កម្លាំងពលកម្ម។

[៣២] សូមមើលយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី 4 របស់រាជរដ្ឋាភិបាលកម្ពុជា ខែ កញ្ញា ឆ្នាំ 2018 ទំ. 44។

សន្ទស្សន៍នេះផ្តល់យន្តការសម្រាប់ឲ្យប្រទេសនានាស្វែងយល់ពីបរិមាណ និងគុណភាពមូលធនមនុស្សរបស់ខ្លួន និងជួយឲ្យប្រទេសទាំងនោះកំណត់អាទិភាពសម្រាប់ការអភិវឌ្ឍទ្រព្យសម្បត្តិទាំងនេះ។

**ពិន្ទុសន្ទស្សន៍មូលធនមនុស្សរបស់កម្ពុជាបង្ហាញពីចំណុចខ្វះខាតផ្នែកសុខភាព អាហារូបត្ថម្ភសម្រាប់វ័យកុមារភាព ការអប់រំ និងជំនាញ ដែលរាំងស្ទះដល់ផលិតភាពរបស់កម្លាំងពលកម្មនាពេលអនាគត។** ពិន្ទុរបស់កម្ពុជា គឺ 0.49 មានន័យថា ផ្អែកលើលទ្ធផលនៃសុខភាព និងការអប់រំ កុមារដែលកើតនៅបច្ចុប្បន្ន នៅពេលចម្រើនវ័យ នឹងមានផលិតភាព 49 ភាគរយនៃផលិតភាពសរុបករណីកុមារទាំងទទួលបានការអប់រំពេញលេញ សុខភាពល្អ និងអាហារូបត្ថម្ភល្អប្រសើរនៅវ័យកុមារ[៣៣]។

**សម្រាប់ប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាបដូចជាកម្ពុជា កម្ពុជាសម្រេចបានខ្ពស់បន្តិចជាងការរំពឹងទុកចំពោះសន្ទស្សន៍នេះ។** ប៉ុន្តែ កម្ពុជាត្រូវសម្រេចបានច្រើនថែមទៀតផ្នែកមូលធនមនុស្ស ដើម្បីឈានដល់លំដាប់របស់ប្រទេសក្នុងតំបន់ និងសេដ្ឋកិច្ច ដែលបានជ្រើសរើសមកប្រៀបធៀប។ ជាទូទៅ សន្ទស្សន៍របស់កម្ពុជាឈរនៅលំដាប់ទី 100 ក្នុងចំណោមប្រទេស 157 ដោយកម្ពុជាឈរនៅលំដាប់ក្រោមប្រទេសវៀតណាម និងថៃ ប៉ុន្តែ នៅលើឡាវដែលជាប្រទេសជិតខាង (តារាង S2)។

**កម្ពុជាសម្រេចបានល្អលើការរស់រានរបស់កុមារ និងមនុស្សពេញវ័យ (ចំណុច ខ និង គ, រូប S3) និងពិន្ទុតេស្ត (ចំណុច ឃ, រូប S3) ប៉ុន្តែទាបជាងប្រទេសផ្សេងទៀតក្នុងតំបន់ និងបណ្តាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតទាប ចំពោះការបញ្ចប់ការសិក្សា (ចំណុច ង, រូប S3) និងជំងឺក្រិនកុមារ (ចំណុច ច, រូប 3)។** មួយភាគបីនៃកម្លាំងពលកម្មនាពេលអនាគតរបស់កម្ពុជាបានកើតជំងឺក្រិននៅវ័យកុមារ ដោយសារកង្វះអាហារូបត្ថម្ភ ការថែទាំ និងសុខភាពខ្សោយនៅវ័យកុមារ។ អត្រាខ្ពស់នៃជំងឺក្រិនបង្ហាញថា កុមារលូតលាស់ក្នុងមជ្ឈដ្ឋានខ្វះខាត[៣៤]។ គុណភាពអប់រំគឺជាបញ្ហាចោទ ហើយនៅពេលដែលចំនួនឆ្នាំសិក្សាត្រូវបានកែសម្រួលទៅតាមគុណភាពនៃការសិក្សា គម្លាតនៃការសិក្សាគឺ 2.7 ឆ្នាំ។

**តារាង S1 ៖ ភោគទ្រព្យជាមូលធនមនុស្សក្នុងម្នាក់ៗជាភាគចំណែកនៃភោគទ្រព្យមូលធនមនុស្សសរុបក្នុងម្នាក់ៗនៅកម្ពុជាប្រៀបទៅនឹងប្រទេសនានា**

| ប្រទេស | ភោគទ្រព្យសរុប | មូលធនមនុស្ស | មូលធនមនុស្សជាចំណែកនៃភោគទ្រព្យសរុប (%) |
|---|---|---|---|
| បង់ក្លាដេស | 12714 | 7170 | 56.4 |
| កម្ពុជា | 16933 | 7337 | 43.3 |
| ក្វាតេម៉ាឡា | 43140 | 25450 | 59.0 |
| ប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតទាប | 25,948 | 13117 | 50.6 |
| អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក | 140,042 | 84334 | 60.2 |
| នីការ៉ាហ្គ័រ | 37084 | 16698 | 45.0 |
| ហ្វីលីពីន | 30823 | 17790 | 57.7 |
| វៀតណាម | 27368 | 13740 | 50.2 |

*ប្រភព* ៖ Lang និងអ្នកនិពន្ធផ្សេងទៀត ឆ្នាំ 2018

**តារាង S2 ៖ ពិន្ទុ និងលំដាប់ថ្នាក់សន្ទស្សន៍មូលធនមនុស្សរបស់កម្ពុជា និងប្រទេសក្នុងតំបន់ និងសេដ្ឋកិច្ចដែលជ្រើសរើសមកប្រៀបធៀប**

| ប្រទេស | ពិន្ទុ HCI | លំដាប់ថ្នាក់ HCI |
|---|---|---|
| វៀតណាម | 0.67 | 47 |
| ថៃ | 0.60 | 65 |
| ហ្វីលីពីន | 0.55 | 84 |
| នីការ៉ាហ្គ័រ | 0.53 | 92 |
| កម្ពុជា | 0.49 | 100 |
| បង់ក្លាដេស | 0.48 | 106 |
| ក្វាតេម៉ាឡា | 0.46 | 109 |
| ឡាវ | 0.45 | 111 |

*ប្រភព* ៖ ធនាគារពិភពលោក ឆ្នាំ 2018

[៣៣] ធនាគារពិភពលោក ឆ្នាំ 2018 សន្ទស្សន៍មូលធនមនុស្ស៖ ខ្លឹមសារសង្ខេបសម្រាប់ប្រទេសកម្ពុជា ៖ https://databank.worldbank.org/data/download/hci/HCI_ 2pager_KHM.pdf.។

[៣៤] ជំងឺក្រិន ត្រូវបានកំណត់ថាមានពិន្ទុ z នៃកម្ពស់ធៀបនឹងអាយុ (HAZ)<-2SD។ HAZ ត្រូវបានគណនាដោយយកតួលេខ គម្លាតស្តង់ដារ ដក តួលេខមេដ្យាននៃអាយុ និងភេទ រួចយកលទ្ធផលមកចែកនឹងគម្លាតស្តង់ដារ (SD) (4)។ សម្រាប់ប្រជាជនដែលមានសុខភាពល្អ ប្រមាណ 2.5% នៃកុមារទាំងអស់មាន HAZ<-2SD។ ភាគរយដែលខ្ពស់ជាង <-2SD បង្ហាញពីស្ថានភាពខ្វះខាតការលូតលាស់។ កុមារដែលកើតជំងឺក្រិនជាប្រភេទមួយនៃកុមារដែលមានបញ្ហាទម្ងន់ និងកម្ពស់លូតលាស់យឺត។ សូមមើល Leroy and Frongillo E. 2019 ទស្សនៈវិស័យ ៖ តើជំងឺក្រិនមានអត្ថន័យដូចម្តេច? ការពិនិត្យឡើងវិញល្អិតល្អន់លើភស្តុតាង។ Adv Nutr. 2019;10:196–204; doi: https://doi.org/10.1093/advances/nmy101។

ប្រអប់ S1

## សន្ទស្សន៍មូលធនមនុស្ស

សន្ទស្សន៍មូលធនមនុស្សជាផ្នែកមួយនៃគម្រោងមូលធនមនុស្សរបស់ធនាគារពិភពលោក និងជារង្វាស់ការវិនិយោគរបស់ប្រទេសនានាលើមូលធនមនុស្សជំនាន់ក្រោយ។ សន្ទស្សន៍នេះមានគោលបំណងព្យាករណ៍ពីផលប៉ះពាល់រួមនៃសុខភាព និងការអប់រំលើផលិតភាពនាពេលអនាគត ដែលហៅថា មូលធនមនុស្សនៅពេលអនាគត ដែលកុមារកើតនៅបច្ចុប្បន្នអាចនឹងសម្រេចបាន ក្រោយពេលបញ្ចប់សាលាមធ្យមសិក្សា ដោយសារបរិយាកាសពេលសម្រាលកុមារនោះ មានហានិភ័យនៃសុខភាពទ្រុឌទ្រោម និងកង្វះការអប់រំ។ សន្ទស្សន៍នេះផ្អែកលើកត្តាសំខាន់ៗបី ៖

១. ការរស់រានមានជីវិត ៖ ផ្នែកនេះបង្ហាញថា កុមារកើតនៅថ្ងៃនេះត្រូវរស់រានមានជីវិតរហូតដល់ពេលចាប់ផ្តើមការអប់រំក្នុងប្រព័ន្ធ។ ការរស់រានមានជីវិតត្រូវបានវាស់វែងផ្អែកលើអត្រាមរណៈរបស់កុមារអាយុក្រោម 5 ឆ្នាំ។

២. ចំនួនឆ្នាំដែលត្រូវសិក្សាបំពេញគុណភាព។ ព័ត៌មានស្តីពីបរិមាណនៃការអប់រំដែលកុមារម្នាក់ត្រូវសម្រេចបាននៅអាយុ 18 ឆ្នាំ គួបផ្សំនឹងកម្រិតគុណភាពដែល វាស់វែងដោយយកពិន្ទុដែលកុមារតាមប្រទេសនីមួយៗទទួលបានពីលទ្ធផលតេស្តសិក្សាអន្តរជាតិ។ ការរួមផ្សំនេះ ផ្តល់ចំនួនឆ្នាំដែលត្រូវសិក្សាបំពេញគុណភាព។ វិធីបំពេញគុណភាពសិក្សានេះឆ្លុះបញ្ចាំងពី តថភាពដែលកុមារក្នុងប្រទេសមួយចំនួនតាមពិតរៀនសូត្របានតិចជាងកុមារក្នុងប្រទេសផ្សេងទៀត ទោះបីជាពួកគេចំណាយពេលវេលាប្រហែលគ្នារៀននៅសាលាក្តី។

៣.សុខភាព ៖ ផ្នែកនេះប្រើប្រាស់សូចនាករពីរសម្រាប់ស្ថានភាពសុខភាពរួមក្នុងប្រទេសមួយ ៖ ១) អត្រាកុមារអាយុក្រោម 5 ឆ្នាំដែលកើតជំងឺក្រិន និង ២) អត្រារស់រានរបស់មនុស្សពេញវ័យ ដែលជាចំនួនមនុស្សអាយុ 15 ឆ្នាំដែលនឹងរស់រានមានជីវិតរហូតដល់អាយុ 60 ឆ្នាំ។ សូចនាករទីមួយឆ្លុះបញ្ចាំងពីស្ថានភាពសុខភាពនៅដំណាក់កាលអភិវឌ្ឍន៍ក្នុងផ្ទៃ ជាទារក និងកុមារតូច។ សូចនាករទីពីរឆ្លុះបញ្ចាំងពីលទ្ធផលសុខភាពរបស់កុមារដែលកើតបច្ចុប្បន្នរហូតដល់ពេលពេញវ័យ។

សន្ទស្សន៍ទទួលបានមានលំដាប់ពី 0 ដល់ 1។ ក្នុងប្រទេសមួយដែលកុមារបច្ចុប្បន្នអាចទទួលបានសុខភាពបរិបូរណ៍ (មិនកើតជំងឺក្រិន និងអត្រារស់រាន 100 ភាគរយនៅពេលពេញវ័យ) និងអាចទទួលបានការអប់រំពេញលេញ (ការអប់រំប្រកបដោយគុណភាពរយៈពេល 14 ឆ្នាំ នៅអាយុ 18 ឆ្នាំ) នឹងទទួលបានសន្ទស្សន៍ដែលមានពិន្ទុ 1។ ដូច្នេះ ពិន្ទុ 0.70 បង្ហាញថា ផលិតភាពជាកម្លាំងពលកម្មនាពេលអនាគតសម្រាប់កុមារដែលកើតបច្ចុប្បន្នគឺ 30 ភាគរយទាបជាងកម្រិតដែលគួរសម្រេចបាន ក្នុងករណីពួកគេទទួលបានការអប់រំពេញលេញ និងមានសុខភាពបរិបូរណ៍។




*ប្រភព* ៖ ធនាគារពិភពលោក ឆ្នាំ 2018 គម្រោងមូលធនមនុស្ស, ធនាគារពិភពលោក វ៉ាស៊ីនតោនឌីស៊ី
*https://openknowledge.worldbank.org/handle/10986/30498*

**ការលើកកម្ពស់កម្រិត និងគុណភាពនៃការអប់រំ ជាអាទិភាពចម្បងសម្រាប់ជំរុញការអភិវឌ្ឍមូលធនមនុស្ស និងធានាលទ្ធភាពទទួលបានការងាររបស់កម្លាំងពលកម្មកម្ពុជានាពេលអនាគត។** និយោជកនៅកម្ពុជារងផលប៉ះពាល់ ដោយសារកម្លាំងពលកម្មដែលមិនមានជំនាញគ្រប់គ្រាន់ ច្រើនជាងប្រទេសជិតខាង ចំណែកការវិលត្រឡប់ទៅរៀននៅកម្រិតបឋមសិក្សា និងមធ្យមសិក្សា មានអត្រាទាប (រូប S1 និង S2)។ លទ្ធភាពទទួលបានការអប់រំកម្រិតបឋមសិក្សាបានកើនឡើង ក្នុងនោះ អត្រាចុះឈ្មោះចូលរៀនសរុបមានចំនួន 93 ភាគរយ ចំណែកអត្រាបញ្ចប់ការសិក្សាគឺ 79 ភាគរយ (ឆ្នាំសិក្សា 2017-2018)។ ប៉ុន្តែការអប់រំមិនទាន់មានគុណភាពគ្រប់គ្រាន់ ដោយលទ្ធផលសិក្សាបានបង្ហាញពីពិន្ទុទាបនៅឡើយ។ ផ្អែកតាមការវាយតម្លៃលទ្ធផលសិក្សាអន្តរជាតិសម្រាប់ការអភិវឌ្ឍឆ្នាំ 2018 (PISA-D) កម្ពុជាមានសិស្សច្រើនដែលបានពិន្ទុក្រោមកម្រិតគោលលើជំនាញទាំងបី ៖ 92 ភាគរយសម្រាប់ផ្នែកអំណាន, 90 ភាគរយសម្រាប់ផ្នែកគណិតវិទ្យា និង 95 ភាគរយសម្រាប់ផ្នែកវិទ្យាសាស្ត្រ។ ការអប់រំកម្រិតមធ្យមសិក្សា នៅតែជាបញ្ហាចោទ។ ការចុះឈ្មោះចូលរៀននៅឆ្នាំសិក្សា 2017-2018 សម្រាប់កម្រិតអនុវិទ្យាល័យមានត្រឹមតែ 56.8 ភាគរយប៉ុណ្ណោះ ចំណែកអត្រាបោះបង់ការសិក្សានៅតែមានកម្រិតខ្ពស់ (15.4 ភាគរយ)។ ប្រជាជនដែលមានការអប់រំល្អ និងមានជំនាញខ្ពស់ ជាលក្ខខណ្ឌចាំបាច់ដើម្បីជំរុញការច្នៃប្រឌិតថ្មី និងឱកាសរកប្រាក់ចំណូល ក៏ដូចជាជំរុញកំណើនសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រក្នុង “សេដ្ឋកិច្ចចំណេះដឹង”។

**ទោះជាយ៉ាងណាក៏ដោយ មូលដ្ឋាននៃមូលធនមនុស្ស ការអប់រំ និងការអភិវឌ្ឍជំនាញ ត្រូវបានកំណត់ទុកជាយូរមកហើយមុនពេលកុមារចូលរៀនបឋមសិក្សា ៖ រយៈពេល 1,000 ថ្ងៃដំបូងនៅចន្លោះពេលមានគភ៌រហូតដល់កុមារអាយុបាន 2 ឆ្នាំ ជាដំណាក់កាលដ៏សំខាន់នៃការអភិវឌ្ឍផ្លូវកាយ និងបញ្ញាស្មារតី។** កង្វះអាហារូបត្ថម្ភ កង្វះការថែទាំ និងការកើតជំងឺញឹកញាប់ សុទ្ធតែធ្វើឲ្យកុមារលូតលាស់មិនបានល្អ ឬមិនកើនទម្ងន់ និងកម្ពស់។ ភស្តុតាងបង្ហាញយ៉ាងច្បាស់ថា ជំងឺក្រិន ដែលជាសញ្ញាបង្ហាញពីកង្វះអាហារូបត្ថម្ភ ព្រមទាំង បញ្ហាទម្ងន់ និងកំពស់ ធ្វើឲ្យកុមារតូចខ្សោយបញ្ញាស្មារតី និងកម្លាំងជំរុញ ហើយប៉ះពាល់ដល់ការរៀនសូត្រ សុខភាព និងសក្តានុពលរកប្រាក់ចំណូលនៅដំណាក់កាលក្រោយមកទៀតក្នុងជីវិត[៣៥]។

**ចាប់ពីវ័យកុមារតូចមក ផ្នែកនានានៃមូលធនមនុស្សបំពេញឲ្យគ្នាទៅវិញទៅមក។** ភាពមិនអនុគ្រោះ កាលណាបានកើតឡើងពីមុនពេលចាប់កំណើត នឹងបន្តរហូតដល់ពេលមុនសម្រាល និងក្រោយពេលសម្រាល។ ភាពមិនអនុគ្រោះទាំងនេះអាចរំខានដល់ការរីកចម្រើននៃខួរក្បាល សុខភាព និងការរៀនសូត្រនៅដំណាក់កាលដំបូង។ ការរីកចម្រើនយឺតដែលមាននៅឆ្នាំទីមួយ អាចកាន់តែយ៉ាប់ទៅនៅវ័យកុមារតូច និងបន្តពេញមួយជីវិត[៣៦]។ ផ្ទុយមកវិញ ការផ្តល់អាហារូបត្ថម្ភសមស្របដល់ទារកក្នុងផ្ទៃ និងនៅវ័យកុមារតូច ជួយបង្កើនសុខុមាលភាពផ្នែករូបរាងកាយ និងខួរក្បាលរបស់កុមារ។ ភស្តុតាងរកឃើញពីការសិក្សានៅតាមប្រទេសនៅអាស៊ីអាគ្នេយ៍ បង្ហាញថា ទាំងកុមារដែលមានទម្ងន់ស្រាល និងកុមារធាត់ សុទ្ធតែមានពិន្ទុឆ្លាតវៃ ទាបជាងកុមារដែលមានទម្ងន់សមស្រប[៣៧]។ សមត្ថភាពនៅវ័យកុមារតូចបង្កភាពងាយស្រួលឲ្យរៀនជំនាញថ្មីៗ និងបង្កើតទំនុកចិត្ត និងការលើកទឹកចិត្តឲ្យរៀនសូត្របន្ថែម។

**រូប S1 ៖ និយោជកនៅកម្ពុជារងផលប៉ះពាល់ ដោយសារកម្លាំងពលកម្មដែលមានជំនាញមិនគ្រប់គ្រាន់ ច្រើនជាងប្រទេសផ្សេងទៀត។**




*ប្រភព* ៖ ការអង្កេតសហគ្រាស 2016

**រូប S2 ៖ អត្រាទាបនៃការវិលត្រឡប់ទៅចូលរៀនវិញ**




*ប្រភព* ៖ ការងារនាពេលអនាគតនៅកម្ពុជា ឆ្នាំ 2019, ធនាគារពិភពលោក

៣៥ Sudfeld CR, Charles-McCoy D, Danaei G, et al.. 2015។ ការលូតលាស់យឺតនៃទម្ងន់ និងកម្ពស់ និងការអភិវឌ្ឍរបស់កុមារក្នុងប្រទេសមានប្រាក់ចំណូលទាប និងប្រទេសមានប្រាក់ចំណូលមធ្យម ៖ ការវិភាគច្រើនផ្នែក Pediatrics;135:e1266។

៣៦ Black MM, Walker SP, Fernald LC, et al. 2017។ ការអភិវឌ្ឍរបស់កុមារតូចរហូតដល់អាយុពេញវ័យ ៖ វិទ្យាសាស្ត្រក្នុងវដ្តជីវិត។ Lancet; 389: 77–90.

៣៧ Sandjaja BK, Poh N, Rojroonwasinkul B, et al. . 2013. ទំនាក់ទំនងរវាងសូចនាករផ្នែកនរវិទ្យា និងដំណើរការបញ្ញាស្មារតីក្នុងចំណោមកុមារគ្រប់អាយុចូលរៀននៅអាស៊ីអាគ្នេយ៍។ ទិន្នានុប្បវត្តិចក្រភពអង់គ្លេសស្តីពីអាហារូបត្ថម្ភកុមារ។ 110 (supplement 3): S57–S64។

**ការវិនិយោគដ៏ឆ្លាតវៃលើអាហារូបត្ថម្ភ ការអភិវឌ្ឍផ្នែករូបរាងកាយ បញ្ញាស្មារតី សង្គម និងផ្លូវចិត្តរបស់កុមារ ដោយចាប់ផ្ដើមពីមុនពេលសម្រាលរហូតដល់វ័យចូលរៀនបឋមសិក្សា ជាកត្តាសំខាន់ក្នុងការបង្កើតមូលដ្ឋានមូលធនមនុស្ស។** អន្តរាគមន៍ពីដំបូងមានប្រសិទ្ធភាព និងបង្កើនប្រសិទ្ធផល និងលទ្ធភាពសម្រេចបានការវិនិយោគដ៏ជោគជ័យនៅពេលក្រោយលើការអប់រំ និងការអភិវឌ្ឍជំនាញ។ ផ្ទុយទៅវិញ ភាពខ្វះខាតផ្នែកអាហារូបត្ថម្ភ រូបរាងកាយ និងចិត្តសង្គមនៅដំណាក់កាលដំបូងក្នុងជីវិតនឹងបង្កការលំបាក ហើយពេលខ្លះ មិនអាចប៉ះប៉ូវបាននៅដំណាក់កាលក្រោយក្នុងឆាកជីវិត។

## ៣.ស្ថានភាពសុខភាព និងអាហារូបត្ថម្ភរបស់កុមារនៅកម្ពុជា

**កម្ពុជាសម្រេចបានវឌ្ឍនភាពគួរឲ្យកត់សម្គាល់លើផ្នែកសុខភាពក្នុងរយៈពេលបីទសវត្សរ៍កន្លងមក។** ក្រោយឆ្លងផុតភាពក្រីក្រកម្រិតខ្ពស់នៅអំឡុងទសវត្សរ៍ឆ្នាំ 1990 ស្ថានភាពសុខភាពនៅកម្ពុជាបានប្រសើរឡើងយ៉ាងឆាប់រហ័ស និងមានលទ្ធផលល្អប្រសើរជាងប្រទេសមួយចំនួនដែលជឿនលឿនជាងខ្លួន ចំពោះការកាត់បន្ថយអត្រាមរណៈ និងការបង្កើនអាយុសង្ឃឹមរស់ (តារាង S3)។ កម្ពុជាជាប្រទេសមួយក្នុងចំណោមប្រទេសទាំង 4 ដែលសម្រេចបានគោលដៅអភិវឌ្ឍន៍សហសវត្សរ៍សម្រាប់អត្រាមរណៈមាតា និងកុមារនៅឆ្នាំ 2015[៣៨]។

**ទោះបីជាមានវឌ្ឍនភាពក្នុងផ្នែកជាច្រើនពាក់ព័ន្ធនឹងសុខភាពក្តី ក៏បញ្ហាកង្វះអាហារូបត្ថម្ភរបស់កុមារនៅតែរាំងស្ទះដល់ការអភិវឌ្ឍមូលដ្ឋានមូលធនមនុស្សនៅកម្ពុជា។** បញ្ហាកង្វះអាហារូបត្ថម្ភរបស់កុមារ ដូចជា ជំងឺក្រិន ការស្គមស្គាំង ទម្ងន់ស្រាល និងកង្វះមីក្រូសារជាតិ គឺជាបញ្ហាប្រឈមនៅកម្ពុជា។ ជំងឺក្រិនកុមារថយចុះពីអត្រា 59 ភាគរយនៅឆ្នាំ 1996 មកត្រឹម 32 ភាគរយនៅឆ្នាំ 2014 (រូប S4) ប៉ុន្តែនៅតែចាត់ទុកជាអត្រាខ្ពស់' ធៀបនឹងស្តង់ដារសកល[៣៩]។ កុមារស្គមស្គាំងដែលមានអត្រាជិត 10 ភាគរយ (កង្វះអាហារូបត្ថម្ភធ្ងន់ធ្ងរ) ក៏ស្ថិតនៅក្នុងអត្រា'ខ្ពស់' ផងដែរ[៤០]។

**រូប S3 ៖ ចំពោះសន្ទស្សន៍មូលធនមនុស្ស ជារួមកម្ពុជាសម្រេចបានលទ្ធផលប្រហាក់ប្រហែលនឹងការរំពឹងទុក បើធៀបនឹងប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតទាបផ្សេងទៀត តែបញ្ហាមួយចំនួន ដូចជា ចំនួនឆ្នាំសិក្សា ការរស់រានរបស់មនុស្សពេញវ័យ និងជំងឺស្គមស្គាំងរបស់កុមារ នៅតែជាបញ្ហាចោទ។**




*ប្រភព* ៖ ធនាគារពិភពលោក

[៣៨] បណ្ដាប្រទេសដែលបានដាក់គោលដៅកាត់បន្ថយអត្រាត្រឹមឆ្នាំ 2015 រួមមាន ប្រទេសចំនួន 75 ដែល សរុបមានជាង 95 ភាគរយនៃអត្រាមរណៈមាតា ទារក និងកុមារនៅឆ្នាំ 2005។ សម្រាប់ព័ត៌មានបន្ថែម សូមមើល ៖ UNICEF និង WHO 2015។ រយៈពេលមួយទសវត្សរ៍នៃការតាមដានវឌ្ឍនភាពនៃអត្រារស់រានរបស់មាតា ទារក និងកុមារ។ របាយការណ៍ឆ្នាំ 2015 ទីក្រុងហ្សឺណែវ ៖ អង្គការសុខភាពពិភពលោក។

[៣៩] យោងតាមកម្រិតសុខភាពសាធារណៈរបស់អង្គការសុខភាពពិភពលោក (WHO)។

[៤០] អ្វីគួរឲ្យកត់សម្គាល់នោះគឺថា មានវឌ្ឍនភាពតិចតួចក្នុងការកាត់បន្ថយអត្រាការស្គមស្គាំងនៅអំឡុងឆ្នាំ 2005-2014។ វត្តមានខ្ពស់នៃជំងឺស្គមស្គាំងគឺជាក្ដីកង្វល់ដ៏ធំក្នុងស្ថានភាពដែលកម្ពុជាបានកាត់បន្ថយភាពក្រីក្រធ្ងន់ធ្ងរ និងអសន្តិសុខផ្នែកស្បៀងអាហារ។

**កង្វះអាហារូបត្ថម្ភមាតាបង្កហានិភ័យចំពោះសុខភាពផ្ទាល់ខ្លួន និងផលិតភាពរបស់ស្ត្រី ក៏ដូចជាប៉ះពាល់ដល់អាហារូបត្ថម្ភរបស់កូន ៖ កង្វះអាហារូបត្ថម្ភក្នុងពេលមានផ្ទៃពោះ និងពេលបំបៅដោះកូន អាចបង្កជាបញ្ហាកង្វះមីក្រូសារជាតិ និងធ្វើឲ្យគភ៌លូតលាស់ និងអភិវឌ្ឍមិនបានល្អ។** ក្នុងចំណោមស្ត្រីកម្ពុជាដែលដល់វ័យបន្តពូជ (15 ដល់ 49 ឆ្នាំ) ស្ត្រី 14 ភាគរយមានទម្ងន់ស្រាល ចំណែកស្ត្រី 45 ភាគរយទៀតកើតជំងឺខ្វះគ្រាប់ឈាមក្រហម។ បញ្ហាកង្វះអាហារូបត្ថម្ភទាំងនេះរួមចំណែកធ្វើឲ្យទារកកើតមកមានទម្ងន់ស្រាល (11 ភាគរយ) ដែលអាចបង្ហាញពីការលូតលាស់យឺតនៃទម្ងន់ និងកម្ពស់កុមារ នៅពេលពរពោះ និងការសម្រាលកូនមិនគ្រប់ខែ។ អ្វីដែលសំខាន់នោះគឺ 20 ភាគរយនៃជំងឺក្រិនដែលកើតឡើងចំពោះកុមារអាយុ 1 ដល់ 5 ឆ្នាំ បណ្តាលមកពីទារកដែលមានទម្ងន់ស្រាលក្នុងផ្ទៃ[៤១]។

**ជារួម កុមារក្រីក្រនៅកម្ពុជា** (កុមាររស់នៅទីជនបទ) **ងាយរងគ្រោះដោយសារកង្វះអាហារូបត្ថម្ភ ជាងកុមារមកពីគ្រួសារជីវភាពខ្ពស់ (រូប S5)។** ការកើតជំងឺក្រិនចំពោះគ្រួសារក្រីក្របំផុត (42 ភាគរយ) មានអត្រាទ្វេដង ច្រើនជាងបញ្ចភាគនៃគ្រួសារជីវភាពខ្ពស់បំផុត (18 ភាគរយ) (រូប S6)។ ប៉ុន្តែ ការកើតមានកង្វះអាហារូបត្ថម្ភមាតា និងកុមារក្នុងចំណោមគ្រួសារជីវភាពខ្ពស់បំផុត បង្ហាញថា កង្វះអាហារូបត្ថម្ភនៅកម្ពុជាមិនមែនបណ្តាលមកពីភាពក្រីក្រតែម៉្យាងនោះទេ។ ជាពិសេសការកើតជំងឺក្រិននៅកម្ពុជានៅតែមានអត្រា 3 ដងខ្ពស់ជាងនៅវៀតណាម[៤២]។ ចំណុចនេះបង្ហាញពីសារៈសំខាន់នៃមូលហេតុដែលមិនមែនជាប្រាក់ចំណូល ដែលបង្កជាបញ្ហាកង្វះអាហារូបត្ថម្ភនៅកម្ពុជា។

**តារាង S3 ៖ សូចនាករអភិវឌ្ឍន៍មនុស្សនៅកម្ពុជា** (2000-2014)

| សូចនាករ | 2000 | 2014 |
|---|---|---|
| **ប្រជាជនសរុប** | 12,152,354 | 15,270,790 |
| **អត្រាបង្កកំណើតសរុប** | 3.8 | 2.7 |
| **អាយុសង្ឃឹមរស់** | 65.6 | 68.3 |
| **អត្រាមរណៈរបស់កុមារអាយុក្រោម 5 ឆ្នាំ (អត្រាស្លាប់ក្នុងកំណើតរស់ 1,000 នាក់)** | 83 | 35 |
| **អត្រាមរណៈទារក (អត្រាស្លាប់ក្នុងកំណើតរស់ 1,000 នាក់)** | 80 | 29 |
| **អត្រាមរណៈរបស់ទារកទើបកើត (អត្រាស្លាប់ក្នុងកំណើតរស់ 1,000 នាក់)** | 37 | 18 |
| **ផលធៀបអត្រាមរណៈមាតា (អត្រាស្លាប់ក្នុងកំណើតរស់ 100,000 នាក់)** | 437 | 170 |

*ប្រភព* ៖ CDHS ឆ្នាំ 2000 និងឆ្នាំ 2014

**រូប S4 ៖ កុមារអាយុក្រោម 5 ឆ្នាំ ដែលមានបញ្ហាកង្វះអាហារូបត្ថម្ភនៅកម្ពុជា, 2000-2014**




*ប្រភព* ៖ ការអង្កេតសុខភាព និងប្រជាសាស្ត្រ នៅកម្ពុជា ឆ្នាំ 2014

**រូប S5 ៖ របាយប្រជាសាស្ត្រនៃការកើតជំងឺក្រិន និងការស្គមស្គាំងកុមារ** (អាយុក្រោម 5 ឆ្នាំ)




*ប្រភព* ៖ ការអង្កេតសុខភាព និងប្រជាសាស្ត្រ នៅកម្ពុជា ឆ្នាំ 2014

[៤១] Christian P, Lee SE, Donahue AM អ្នកនិពន្ធផ្សេងទៀត ឆ្នាំ 2013. ហានិភ័យនៃកង្វះអាហារូបត្ថម្ភកុមារដែលពាក់ព័ន្ធនឹងទម្ងន់ទារកស្រាលក្នុងផ្ទៃ និងការសម្រាលកូនមិនគ្រប់ខែក្នុងប្រទេសមានប្រាក់ចំណូលទាប និងប្រទេសមានប្រាក់ចំណូលមធ្យម។ ទិន្នានុប្បវត្តិអន្តរជាតិស្តីពីការសិក្សាជម្ងឺរាតត្បាត។ 42: 1340–55។

[៤២] យោងតាមការអង្កេតកម្រងសូចនាករចម្រុះឆ្នាំ 2011 នៅវៀតណាម ប្រេវ៉ាឡង់នៃការកើតជំងឺក្រិនគឺ 6.1 ភាគរយក្នុងចំណោមកុមារមកពីបញ្ចភាគនៃគ្រួសារស្តុកស្តម្ភបំផុត។

**ការកើតជំងឺក្រិននៅកម្ពុជា មានអត្រាប្រហាក់ប្រហែលគ្នានឹងប្រទេសក្នុងតំបន់ដែលយកមកប្រៀបធៀប ប៉ុន្តែ កម្ពុជាត្រូវពន្លឿនវឌ្ឍនភាពឲ្យទាន់ប្រទេសជិតខាង ដូចជា ម៉ាឡេស៊ី ថៃ និងវៀតណាម (រូប S7)។** អ្វីដែលគួរឲ្យកត់សម្គាល់នោះគឺថា ជំងឺក្រិនកុមារនៅតែជាបញ្ហាប្រឈមទូទៅនៅតំបន់អាស៊ាន (ឥណ្ឌូនេស៊ី ហ្វីលីពីន ឡាវ និងមីយ៉ាន់ម៉ា) ដែលមានកុមារប្រមាណមួយភាគបី កើតជំងឺក្រិន ផ្អែកតាមការប៉ាន់ស្មានពេលថ្មីៗបំផុត ។

**បញ្ហាកង្វះអាហារូបត្ថម្ភនៅកម្ពុជាបង្កផលប៉ះពាល់រយៈពេលខ្លី និងរយៈពេលវែងលើបុគ្គល និងសង្គមជាតិទាំងមូល។** មានការប៉ាន់ស្មានថា កង្វះអាហារូបត្ថម្ភជាមូលហេតុធ្វើឲ្យមានអត្រាមរណៈកុមារកម្ពុជាជាង 60 ភាគរយនៅឆ្នាំ 2010។ សម្រាប់កុមារដែលរស់រាន ផលវិបាកនៃកង្វះអាហារូបត្ថម្ភនៅវ័យកុមារតូច រួមមាន ការអភិវឌ្ឍយឺតផ្នែកបញ្ញាស្មារតី ការរៀនមិនពូកែ លទ្ធភាពរកប្រាក់ចំណូលទាបនៅពេលពេញវ័យ និងចំណាយច្រើនលើបញ្ហាសុខភាព និងលទ្ធភាពខ្ពស់នៃការកើតជំងឺរ៉ាំរ៉ៃមិនឆ្លង នៅពេលពេញវ័យ។ មានការប៉ាន់ស្មានថា ចំណាយទូទាំងប្រទេសលើបញ្ហាកង្វះអាហារូបត្ថម្ភ[៤៣] មានប្រមាណ ចន្លោះ 250 ដល់ 400 លានដុល្លាក្នុងមួយឆ្នាំ នៅឆ្នាំ 2010 ឬស្មើនឹងចន្លោះពី 1.5 ដល់ 2.5 ភាគរយនៃ ផសស[៤៤]។

## ៤.កត្តាជំរុញឲ្យមានបញ្ហាកង្វះអាហារូបត្ថម្ភលើកុមារ

**បុព្វហេតុនៃបញ្ហាកង្វះអាហារូបត្ថម្ភនៅកម្ពុជា មានច្រើនពាក់ព័ន្ធគ្នា និងពហុវិស័យ។** ក្របខណ្ឌ UNICEF គឺជាគំរូទស្សនទានដ៏ល្អសម្រាប់វាយតម្លៃកត្តាជំរុញឲ្យមានបញ្ហាកង្វះអាហារូបត្ថម្ភក្នុងបរិបទមួយ (រូប S8)។ ការកាត់បន្ថយបញ្ហាកង្វះអាហារូបត្ថម្ភកុមារនៅកម្ពុជា ទាមទារឲ្យមានអន្តរាគមន៍នានា ដើម្បី ក) កែលម្អភ្លាមៗកត្តាដែលបង្កបញ្ហាកង្វះអាហារូបត្ថម្ភ ដោយបង្កើនការទទួលទានអាហារូបត្ថម្ភ ការថែទាំ និងព្យាបាលជំងឺ ខ) ទប់ស្កាត់ និងកាត់បន្ថយកង្វះអាហារូបត្ថម្ភ ដោយបង្កើនសុខភាពមាតា ការថែទាំ និងស្ថានភាពអាហារូបត្ថម្ភ និង គ) ដោះស្រាយកត្តាបុព្វហេតុ (ដូចជា អសន្តិសុខស្បៀង កង្វះការថែទាំស្ត្រី និងកុមារ កង្វះលទ្ធភាពទទួលបានសេវាសុខភាព និងទឹកស្អាត អនាម័យ[WASH])។

### ក.ការប្រព្រឹត្តិដែលធ្វើឲ្យមានកង្វះអាហារូបត្ថម្ភ

ការបង្កើនគុណភាពអាហាររបស់ស្ត្រី និងកុមារជាកត្តាចម្បងក្នុងការសម្រេចបានលទ្ធផលអាហារូបត្ថម្ភល្អប្រសើរនៅកម្ពុជា។ របបអាហារភាគច្រើននៅកម្ពុជាគឺបាយ និងមានភស្តុតាងតិចតួចដែលបង្ហាញថា ស្ត្រីបង្កើនបរិមាណ និងគុណភាពរបបអាហារដើម្បីបំពេញតម្រូវការនៅពេលមានផ្ទៃពោះ[៤៥]។ ផ្ទុយទៅវិញ ការវិភាគបែបគុណភាពបង្ហាញថា ជាញឹកញាប់ ស្ត្រីមានផ្ទៃពោះមានការប្រព្រឹត្តអវិជ្ជមានមួយ ឬច្រើន ដូចជា ការមិនបរិភោគអាហារពេលណាមួយដើម្បីកុំឲ្យឡើងទម្ងន់ និងថៃរាង និងងាយសម្រាលកូន ការមិនបរិភោគអាហារពេលណាមួយដើម្បីកុំឲ្យចាញ់កូន និងការញុំាអាហារមានជាតិស្ករ និងអាហារសម្រន់ផ្អែមជ្រុល[៤៦]។

**រូប S6 ៖ បញ្ហាកង្វះអាហារូបត្ថម្ភកុមារអាយុក្រោម 5 ឆ្នាំ តាមកម្រិតទ្រព្យសម្បត្តិ, 2014, កម្ពុជា**




*ប្រភព* ៖ ការអង្កេតសុខភាព និងប្រជាសាស្ត្រ ឆ្នាំ 2014 នៅកម្ពុជា

**រូប S7 ៖ ប្រេវ៉ាឡង់នៃការកើតជំងឺក្រិនពីពេលមួយទៅពេលមួយក្នុងបណ្ដាប្រទេសនៅអាស៊ីបូព៌ា និងប៉ាស៊ីហ្វិក**




*ប្រភព* ៖ សូចនាករអភិវឌ្ឍន៍ពិភពលោក

---

៤៣ រួមមាន កង្វះអាហារូបត្ថម្ភមាតា កង្វះមីក្រូសារជាតិស្ត្រី និងកុមារ ការកើតជំងឺក្រិនកុមារ ការស្គមស្គាំង និងទម្ងន់ស្រាល និងការបំបៅដោះកូនមិនបានគ្រប់គ្រាន់។

៤៤ Bagriansky J, Champa N, Pak K និងអ្នកនិពន្ធដទៃទៀត ឆ្នាំ 2014 ផលវិបាកផ្នែកសេដ្ឋកិច្ចនៃបញ្ហាកង្វះអាហារូបត្ថម្ភនៅកម្ពុជា ធ្វើឲ្យខាតបង់ទឹកប្រាក់ជាង 400 លានដុល្លាក្នុងមួយឆ្នាំ។ ទិន្នានុប្បវត្តិអាស៊ីប៉ាស៊ីហ្វិកស្ដីពីអាហារូបត្ថម្ភគ្លីនិក 23(4); 524-31។

៤៥ តាមពិត ការវិភាគថ្មីៗ បង្ហាញថា ផ្អែកលើកម្រិតបរិភោគបាយបច្ចុប្បន្ន ការបំពេញបានលក្ខខណ្ឌសម្រាប់ខ្លាញ់ និងវីតាមីន B មិនអាចធ្វើទៅបានទេ បើមិនបរិភាគលើសពីកម្រិតកាឡូរីដែលអនុញ្ញាតនោះ។ សម្រាប់ព័ត៌មានបន្ថែម សូមមើល កម្មវិធីស្បៀងអាហារពិភពលោក 2017។ ការលុបបំបាត់ការខ្វះខាតសារជាតិចិញ្ចឹម ៖ របាយការណ៍សង្ខេប ទីក្រុងរ៉ូម ៖ កម្មវិធីស្បៀងអាហារពិភពលោក។

៤៦ MOH, UNICEF, HKI, iDE, និង Melon Rouge ឆ្នាំ 2017 ការចិញ្ចឹមបីបាច់ទារកនៅរយៈពេល 1000 ថ្ងៃដំបូង និងកុមារតូចនៅកម្ពុជា ទីក្រុងភ្នំពេញ iDE។

**ការបំបៅដោះកូន[៤៧] នៅកម្ពុជាមានកម្រិតខ្ពស់ធៀបនឹងបណ្ដាប្រទេសដែលយកមកប្រៀបធៀប (ចំណុច ក និង ខ, រូប S9) ប៉ុន្តែបង្ហាញពីសញ្ញាថយចុះពីពេលមួយទៅពេលមួយ (ចំណុច គ និង ឃ, រូប S9)។** ការបំបៅដោះកូនជាប្រភពផ្ដល់សារជាតិចិញ្ចឹមដ៏សំខាន់នៅដំណាក់កាលដំបូងនៃជីវិត និងមានផលប្រយោជន៍យ៉ាងច្រើនចំពោះសុខភាព និងការវិវត្តរបស់កុមារដោយមិនពាក់ព័ន្ធនឹងការលូតលាស់ឃើតនៃទម្ងន់ និងកម្ពស់កុមារ។ កុមារដែលបានបំបៅដោះកាន់តែយូរមានអត្រាទាបនៃការកើតជំងឺ និងស្លាប់ និងឆ្លាតវៃជាងកុមារដែលបានបំបៅដោះក្នុងរយៈពេលខ្លី ឬមិនបានបំបៅដោះ ហើយនឹងបន្តផ្ដល់ប្រយោជន៍រហូតដល់ដំណាក់កាលក្រោយទៀតក្នុងជីវិត[៤៨]។ មានភស្តុតាងជាច្រើនដែលបង្ហាញថាការបំបៅដោះកូនអាចការពារការធាត់ជ្រុល និងជំងឺទឹកនោមផ្អែមនៅដំណាក់កាលក្រោយមកទៀតក្នុងជីវិត។

**ការថយចុះអត្រាបំបៅដោះកូននៅកម្ពុជាកើតមានភាគច្រើនក្នុងចំណោមម្ដាយរស់នៅទីប្រជុំជន និងម្ដាយមកពីគ្រួសារជីវភាពខ្ពស់។** ការប្រើប្រាស់កាន់តែទូលំទូលាយនៅអាស៊ាននៃទឹកដោះគោសម្រាប់កុមារ ដែលធ្វើឲ្យកុមារប្រឈមនឹងកង្វះសារជាតិចិញ្ចឹម និងជំងឺ។ កត្តាដែលពាក់ព័ន្ធនឹងការប្រើប្រាស់ទឹកដោះគោកាន់តែច្រើន រួមមាន ការមិនសូវមានពេលបំបៅដោះកូនដោយសារតែស្ត្រីត្រូវធ្វើការ ភាពសុខស្រួល និងកង្វះការគាំទ្រក្នុងសង្គម និងអត្ថប្រយោជន៍ដែលផ្សាយថាបានមកពីការប្រើប្រាស់ម្សៅទឹកដោះគោ[៤៩]។ ការសិក្សាថ្មីៗបង្ហាញពីការផ្សព្វផ្សាយផលិតផលម្សៅទឹកដោះគោយ៉ាងផុសផុលនៅតាមទីកន្លែងសាធារណៈ និងឯកជន ទោះជាមានការដាក់បទប្បញ្ញត្តិប្រឆាំងនឹងសកម្មភាពនេះក្ដី។ ការពង្រីកទីផ្សារយ៉ាងទូលំទូលាយបានផ្លាស់ប្ដូរការយល់ឃើញ និងអនុសាសន៍របស់អ្នកជំនាញសុខភាព ដែលជាញឹកញាប់លើកកម្ពស់ការប្រើប្រាស់ផលិតផលទឹកដោះគោ ជាជាងផ្ដល់ការគាំទ្រដល់ការបំបៅដោះដែលមានគុណភាព[៥០]។

**អំឡុងពេលនៃការផ្ដល់អាហារបន្ថែម (ពីខែទី 6 ដល់ខែទី 24) ជាដំណាក់កាលដ៏សំខាន់សម្រាប់អាហារូបត្ថម្ភ និងការលូតលាស់របស់កុមារ។** ដូចគ្នានឹងនិន្នាការជាសកលដែរ មានអត្រាជិតទ្វេដងនៃការកើតជំងឺក្រិនក្នុងចំណោមកុមារកម្ពុជានៅពេលចាប់ផ្ដើមផ្ដល់អាហារបន្ថែម។ ទារកមានអាយុក្រោម ចន្លោះពី 9 ដល់ 11 ខែប្រមាណ 16 ភាគរយ និងទារកមានអាយុចន្លោះពី 18 ដល់ 23 ខែ ប្រមាណ 34 ភាគរយកើតជំងឺក្រិន[៥១]។ និន្នាការនេះបណ្ដាលមកពីការផ្ដល់អាហារបន្ថែមដែលមិនសូវមានគុណភាព និងអនាម័យ និងមានបរិមាណតិច ការប្រើប្រាស់ទឹកមិនស្អាត និងការកើនឡើងនៃការប្រឈមនឹងការកើតជំងឺ នៅពេលដែលកុមារកាន់តែសកម្ម (ជាពិសេសក្នុងមជ្ឈដ្ឋានគ្មានអនាម័យ)។

**រូប S8 ៖ ក្របខណ្ឌទស្សនទានសម្រាប់ការកំណត់មូលហេតុដែលនាំឱ្យមានកង្វះអាហារូបត្ថម្ភ**




*ប្រភព* ៖ អាស៊ាន, UNICEF, និង WHO 2016 របាយការណ៍ថ្នាក់តំបន់ស្ដីពីសន្តិសុខអាហារូបត្ថម្ភនៅអាស៊ាន លេខ 2 ទីក្រុងបាងកក ៖ UNICEF។

---

[៤៧] ការចាប់ផ្ដើម ចិរវេលា និងការចិញ្ចឹមទារក និងកុមារតូចដោយបំបៅដោះតែមួយមុខ មានសារៈសំខាន់ក្នុងការបង្កើនស្ថានភាពអាហារូបត្ថម្ភសម្រាប់វ័យកុមារភាព និងទប់ស្កាត់មរណភាពទារក (Black អ្នកនិពន្ធផ្សេងទៀត ឆ្នាំ 2008)។ អង្គការសុខភាពពិភពលោកស្នើឲ្យមានការចាប់ផ្ដើមបំបៅដោះក្នុងរយៈពេលមួយម៉ោងក្រោយពេលសម្រាល និងបន្តបំបៅដោះកូនតែមួយមុខគត់រហូតដល់កុមារអាយុបាន 6 ខែ និងបន្តរហូតដល់កុមារអាយុបាន 24 ខែ។

[៤៨] Victora CG, Bahl R, Barros AJ អ្នកនិពន្ធផ្សេងទៀត ឆ្នាំ 2016. ការបំបៅដោះកូនក្នុងសតវត្សរ៍ទី 21 ៖ ការសិក្សាពីជំងឺរាតត្បាតយន្តការ និងផលប៉ះពាល់ពេញមួយជីវិត។ Lancet; 387: 475-90។

[៤៩] Pries AM, Huffman SL, Mengkheang K អ្នកនិពន្ធផ្សេងទៀត ឆ្នាំ 2016 ការផ្សព្វផ្សាយយ៉ាងទូលំទូលាយពីផលិតផលម្សៅទឹកដោះគោដែលជំនួសឲ្យទឹកដោះម្ដាយនៅទីក្រុងភ្នំពេញ ប្រទេសកម្ពុជា និងអត្រាខ្ពស់នៃការប្រើប្រាស់ម្សៅទឹកដោះគោសម្រាប់ទារក និងកុមារ។ អាហារូបត្ថម្ភមាតា និងកុមារ 12(Suppl. 2): 38-51។

[៥០] MOH, UNICEF, HKI, iDE, និង Melon Rouge ឆ្នាំ 2017 ការចិញ្ចឹមបីបាច់ទារកនៅរយៈពេល 1000 ថ្ងៃដំបូង និងកុមារតូចនៅកម្ពុជា ទីក្រុងភ្នំពេញ iDE។

[៥១] វិទ្យាស្ថានជាតិស្ថិតិ ឆ្នាំ 2015 ការអង្កេតសុខភាព និងប្រជាសាស្ត្រនៅកម្ពុជា ឆ្នាំ 2014។

**ការផ្តល់អាហារបន្ថែមតាមរបៀបប្រសើរឡើង ជាកត្តាចាំបាច់ក្នុងការធានាឲ្យកុមារកម្ពុជាទទួលបានសារជាតិចិញ្ចឹមគ្រប់គ្រាន់។** កុមារត្រូវការការផ្តល់អាហារបន្ថែមគ្រប់គ្រាន់ សមស្របតាមវ័យ មានសុវត្ថិភាព និងទាន់ពេលវេលានៅវ័យ ពី 6 ដល់ 24 ខែបន្ថែមលើការបំបៅដោះ។ គុណភាព និងបរិមាណអាហារបន្ថែម[៥២] នៅកម្ពុជា មានកម្រិតទាប។ មានទារក និងកុមារតូចតិចតួចប៉ុណ្ណោះដែលទទួលបានអាហារចម្រុះគ្រប់ជីវជាតិអប្បរមាដែលសមស្រប (48 ភាគរយ)។ អត្រានេះជាអត្រាទាបធៀបនឹងប្រទេសក្នុងតំបន់ ដូចជា ឥណ្ឌូនេស៊ី (52.6 ភាគរយ) និងវៀតណាម (59 ភាគរយ) (រូប S10)។ លើសពីនេះទៀត កម្ពុជាមានភាពខុសគ្នាយ៉ាងច្រើនរវាងអាហារជីវជាតិចម្រុះសម្រាប់កុមារមកពីគ្រួសារជីវភាពខ្ពស់បំផុត (69 ភាគរយ) និងអាហារជីវជាតិចម្រុះសម្រាប់កុមារមកពីគ្រួសារក្រីក្របំផុត (33 ភាគរយ)[៥៣]។ អ្វីដែលសំខាន់នោះគឺ កុមារតូចប្រមាណមួយភាគបី ដែលមកពីគ្រួសារជីវភាពខ្ពស់បំផុត មិនទទួលបានអាហារដែលមានជីវជាតិចម្រុះជាអប្បបរមាឡើយ។

## ខ.កង្វះលទ្ធភាពអាចរកបាន និងលទ្ធភាពទិញអាហារមានសារជាតិចិញ្ចឹម

**កំណើនចំណីអាហារនៅកម្ពុជា (ឧ. បរិមាណស្រូវ/អង្ករគ្រប់គ្រាន់ទូទាំងប្រទេស) បានធ្វើឲ្យប្រសើរឡើងតែបន្តិចបន្តួចចំពោះលទ្ធភាពអាចរកអាហារបាន** (គឺ លទ្ធភាពតាមភូមិសាស្ត្រ និងកម្រិតសេដ្ឋកិច្ចក្នុងការទទួលបានរបបអាហារចម្រុះ និងសំបូរសារជាតិចិញ្ចឹម)។ អសន្តិសុខស្បៀងធ្ងន់ធ្ងរនៅតែជាបញ្ហាដ៏ធំនៅតាមតំបន់មួយចំនួន (តំបន់ក្រីក្រ និងដាច់ស្រយាល)។ គ្រួសារកសិករភាគច្រើនអាចបំពេញតម្រូវការអាហារចាំបាច់ (បាយ) ប៉ុន្តែត្រូវពឹងផ្អែកលើប្រាក់ចំណូល និងការស្វែងរកអាហារក្នុងព្រៃ ដើម្បីទទួលបានអាហារដែលសំបូរសារជាតិចិញ្ចឹម។ លទ្ធភាពចូលដល់ទីផ្សារតាមតំបន់ភូមិសាស្ត្រមិនមែនជាបញ្ហាចោទឡើយ ព្រោះគ្រួសារភាគច្រើនអាចទៅដល់ទីផ្សារក្នុងរយៈពេល 30 នាទី ហើយជាមធ្យម ទីផ្សារទាំងនេះមានអាហារ 270 មុខ។

**រូប S9 ៖ ទម្លាប់នៃការផ្តល់អាហារដល់ទារកនិងកូនក្មេងនៅកម្ពុជា ប្រៀបជាមួយប្រទេសនានា**

ក.ទម្លាប់នៃការចាប់ផ្តើមដំបូងនៃការបំបៅដោះ (ក្នុងរង្វង់មួយម៉ោងក្រោយទារកកើត)




ខ.ទារកដែលមិនបានបំបៅដោះ តាមក្រុមអាយុ




គ.ការចាប់ផ្តើមបំបៅដោះកូន (ក្នុងរយៈពេលមួយម៉ោងក្រោយពេលសម្រាល) នៅកម្ពុជា 2000-2014




ឃ.ការបំបៅដោះកូនតែមួយមុខគត់ (ទារកអាយុ 0-5 ខែ) នៅកម្ពុជា 2000-2014




[៥២] ក្រោយរយៈពេល 6 ខែដំបូង ភាពញឹកញាប់នៃការបំបៅដោះកូន ជីវជាតិអាហារផ្សេងៗ និងសមាសធាតុសារធាតុចិញ្ចឹមក្នុងអាហារបន្ថែម បង្កផលប៉ះពាល់លើស្ថានភាពអាហារូបត្ថម្ភរបស់ទារក និងកុមារតូច និងពាក់ព័ន្ធបំផុតនឹងការកើតជំងឺក្រិន។ សូមមើល Bhutta អ្នកនិពន្ធផ្សេងទៀត ឆ្នាំ 2013។

[៥៣] ជីវជាតិអាហារផ្សេងៗជាអប្បបរមាជាភាគរយកុមារអាយុ 6-23 ខែដែលទទួលបានអាហារយ៉ាងហោចណាស់ពីក្រុមអាហារ 4 មុខពីមុនមក។ សម្រាប់កុមារដែលបៅដោះម្តាយ ភាពញឹកញាប់នៃអាហារអប្បបរមាជាការផ្តល់អាហាររឹងឬអាហារពាក់កណ្តាលរឹងយ៉ាងតិច 2 ដងក្នុងមួយថ្ងៃសម្រាប់ទារកអាយុ 6-8 ខែ, យ៉ាងតិច 3 ដងក្នុងមួយថ្ងៃសម្រាប់កុមារអាយុ 9-23 ខែ។ សម្រាប់កុមារដែលមិនបៅដោះម្តាយ ភាពញឹកញាប់នៃអាហារពេលអប្បបរមា ជាការផ្តល់អាហាររឹង ឬពាក់កណ្តាលរឹង ឬទឹកដោះគោយ៉ាងតិច 4 ដងក្នុងមួយថ្ងៃសម្រាប់កុមារអាយុ 6-23 ខែ។

**ម្យ៉ាងវិញទៀត លទ្ធភាពទិញអាហារដែលសំបូរសារជាតិចិញ្ចឹម គឺជាបញ្ហាទូទៅ។** ការប៉ាន់ស្មានថ្មីៗបង្ហាញថា មានគ្រួសារតែ 21 ភាគរយប៉ុណ្ណោះដែលមានលទ្ធភាពទិញអាហារដែលមានសារជាតិចិញ្ចឹម[៥៤] ចំណែកគ្រួសារកសិករក្រីក្រប្រឈមនឹងអសន្តិសុខស្បៀងខ្លាំងជាងគេ។ ការចំណាយប្រចាំថ្ងៃជាមធ្យមរបស់ប្រទេសចំពោះអាហារចិញ្ចឹមចាំបាច់ដែលបានកែសម្រួល[៥៥] នៅខេត្តរតនគិរី/មណ្ឌលគិរី (6.06 ដុល្លា) មានអត្រាខ្ពស់ជិត 2 ដងធៀបនឹងមធ្យមភាគទូទាំងប្រទេស (3.62 ដុល្លា)។ មានការប៉ាន់ស្មានថា គ្រួសារ 66 ភាគរយនៅខេត្តភាគឦសានគ្មានលទ្ធភាពទិញអាហារដែលមានសារជាតិចិញ្ចឹមឡើយ[៥៦]។

**ក្រៅពីនេះ ភស្តុតាងវិទ្យាសាស្ត្រ និងភស្តុតាងពីការរៀបរាប់បង្ហាញពីការប្រឈមកាន់តែខ្លាំងរបស់ប្រជាជនកម្ពុជាទៅនឹងគ្រោះថ្នាក់នៃចំណីអាហារ។** ប្រព័ន្ធស្បៀងអាហារនៅកម្ពុជាកំពុង "ផ្លាស់ប្តូរ" ដោយកំណើនបញ្ហាសុវត្ថិភាពចំណីអាហារនឹងក្លាយជាបន្ទុកធំ ឬហួសសមត្ថភាពបច្ចុប្បន្នរបស់កម្ពុជា[៥៧]។ ជំងឺឆ្លងតាមអាហារបង្កជាបញ្ហាសុខភាព និងជំងឺដល់ប្រជាជនក្រីក្រ តែ

**រូប S10 ៖ ការផ្តល់អាហារបន្ថែមដល់កុមារអាយុ 6-23 ខែ នៅកម្ពុជា និងបណ្តាប្រទេសដែលជ្រើសរើសមកប្រៀបធៀប**




*ប្រភព* ៖ UNICEF-មូលដ្ឋានទិន្នន័យស្តីពីសូចនាករនៃការផ្តល់អាហារដល់កុមារ និងទារក។ ឆ្នាំថ្មីបំផុត តាមប្រទេស។

ចំពោះផលប៉ះពាល់ជាក់លាក់លើកុមារក្តី មិនទាន់មានការយល់ដឹងច្បាស់នៅឡើយទេ។ បញ្ហាសុវត្ថិភាពចំណីអាហារនៅកម្ពុជាមានចាប់ពីកម្រិតស្ថាប័ន (កម្សោយផ្នែកគោលនយោបាយ ការកំណត់អាទិភាព និងការមានទិន្នន័យ) រហូតដល់កម្រិតបុគ្គល (ទីតាំងលក់អាហារមិនសមស្រប និងគ្មានអនាម័យ កង្វះការយល់ដឹងពីការគ្រប់គ្រងសីតុណ្ហភាព ដែលបង្កជាបញ្ហាចោទនៅពេលរក្សាទុកយូរពេកមុនយកទៅចំអិនហូប។ ការប្រព្រឹត្តិដែលមិនគិតគូរពីអនាម័យខ្លួនប្រាណ ដោយសារកង្វះការយល់ដឹង ឬកង្វះហេដ្ឋារចនាសម្ព័ន្ធនៅជិតតំបន់រស់នៅ)[៥៨]។

## គ.ចំណុចខ្វះខាតក្នុងការផ្តល់សេវាអាហារូបត្ថម្ភដោយវិស័យសុខាភិបាល

ទោះបីជាមានភាពប្រសើរឡើងជាច្រើនលើវិសាលភាពនៃការផ្តល់សេវាសុខភាព និងអាហារូបត្ថម្ភមាតា និងកុមារក្តី ក៏នៅតែមានចំណុចខ្វះខាតលើវិសាលភាព និងបញ្ហាវិសមភាព (រូប S11)។ មានការអន្តរាគមន៍ជាអាហារូបត្ថម្ភផ្អែកតាមភស្តុតាង និងមានលទ្ធផលខ្ពស់ជាច្រើន ដែលអាចកាត់បន្ថយអត្រាកើតជំងឺក្រិនបាន 20 ភាគរយ[៥៩] នៅពេលអនុវត្តឲ្យដល់កម្រិត 90 ភាគរយ។ យោងតាមការអង្កេតសុខភាព និងប្រជាសាស្ត្រនៅកម្ពុជា ឆ្នាំ 2014 មានកុមារតែពីរភាគបីប៉ុណ្ណោះ (65 ភាគរយ) ដែលទទួលបានការចាក់ថ្នាំបង្ការសំខាន់ៗទាំងអស់នៅអាយុ 12 ខែ។ កុមារអាយុ 12-23 ខែ ជាងមួយភាគបួន មិនទទួលបានការចាក់ថ្នាំបង្ការពេញលេញ ហើយកុមារជាច្រើនក្នុងចំណោមនេះរស់នៅក្នុង "សហគមន៍ដែលមានហានិភ័យខ្ពស់" ដូចជា សហគមន៍ជនជាតិដើមភាគតិច ប្រជាជននៅជនបទ និងទីប្រជុំជនដាច់ស្រយាល/ក្រៅផ្លូវការ និងកុមារដែលមានគ្រួសារធ្វើចំណាកស្រុក។ កុមារត្រឹមតែ 59 ភាគរយប៉ុណ្ណោះដែលទទួលបានថ្នាំទម្លាក់ព្រូនពីរដងក្នុងមួយឆ្នាំ ហើយកុមារ 70 ភាគរយទទួលបានគ្រាប់ថ្នាំវីតាមីន A ពីរដងក្នុងមួយឆ្នាំ[៦០]។

**មានចំណុចរាំងស្ទះជាច្រើនដល់ការកែលម្អសេវាអាហារូបត្ថម្ភតាមរយៈវិស័យសុខាភិបាល ដូចជា** ១) សេវានៅតាមទីតាំងសុខាភិបាលមិនសូវមានគុណភាព និងចាំបាច់ត្រូវបង្កើនស្តង់ដារវិជ្ជាជីវៈ និងជំនាញដែលពាក់ព័ន្ធនឹងការពិគ្រោះយោបល់លើអាហារូបត្ថម្ភ

៥៤ កម្មវិធីស្បៀងអាហារពិភពលោក ឆ្នាំ 2017 ខ្លឹមសារសង្ខេបស្តីពីការវិភាគការលុបបំបាត់កង្វះខាតសារជាតិចិញ្ចឹម ក្រុងភ្នំពេញ WFP។

៥៥ អាហារមានសារជាតិចិញ្ចឹមដែលបានកែសម្រួលចាំបាច់ ត្រូវបានជ្រើសរើសជាសំណាកដោយប្រើប្រាស់កម្មវិធីប្រហាក់ប្រហែល ដើម្បីកំណត់អាហារមានសារជាតិចិញ្ចឹមដែលចំណាយតិចបំផុតសម្រាប់គ្រួសារមួយ រួមទាំងបុគ្គលដែលងាយរងគ្រោះដោយសារបញ្ហាអាហារូបត្ថម្ភ ដែលត្រូវបានកែសម្រួលដើម្បីរួមបញ្ចូលអាហារសំខាន់ៗ (បាយ និងត្រី)។ គំរូនេះមិនឆ្លុះបញ្ចាំងពីអ្វីដែលមនុស្សបរិភោគ និងគ្មានគោលបំណងផ្តល់អនុសាសន៍ស្តីពីអ្វីដែលមនុស្សគួរបរិភោគឡើយ។ ផ្ទុយទៅវិញ គំរូនេះផ្អែកលើការកំណត់របៀបបំពេញតម្រូវការម៉ាក្រូ/មីក្រូសារជាតិចិញ្ចឹមរបស់សមាជិកគ្រួសារមួយ ដោយចំណាយតិចបំផុត និងផ្អែកលើអាហារដែលមានក្នុងទីផ្សារមូលដ្ឋាន និងការកែសម្រួលតិចតួចលើការចង់បានក្នុងមូលដ្ឋាន។

៥៦ កម្មវិធីស្បៀងអាហារពិភពលោក ឆ្នាំ 2017។

៥៧ ធនាគារពិភពលោក ឆ្នាំ 2019 សារៈសំខាន់ៗនៃសុវត្ថិភាពអាហារ ៖ ការបង្កើនវឌ្ឍនភាពក្នុងបណ្តាប្រទេសមានប្រាក់ចំណូលទាប និងប្រទេសមានប្រាក់ចំណូលមធ្យម។ វ៉ាស៊ីនតោនឌីស៊ី ៖ ធនាគារពិភពលោក។

៥៨ សូមមើល ៖ "ការដោះស្រាយបញ្ហាសុវត្ថិភាពចំណីអាហារក្នុងបណ្តាប្រទេសមានប្រាក់ចំណូលមធ្យមនៅអាស៊ីបូព៌ា និងប៉ាស៊ីហ្វិក" ធនាគារពិភពលោក ឆ្នាំ 2019, បច្ចុប្បន្នភាពសេដ្ឋកិច្ចអាស៊ីបូព៌ា និងប៉ាស៊ីហ្វិក ៖ ខែ មេសា ឆ្នាំ 2019 វ៉ាស៊ីនតោនឌីស៊ី ៖ ធនាគារពិភពលោក។

៥៩ Bhutta ZA, Das JK, Rizvi A អ្នកនិពន្ធផ្សេងទៀត ឆ្នាំ 2013. ការអន្តរាគមន៍ផ្អែកតាមភស្តុតាងសម្រាប់ការបង្កើនស្ថានភាពអាហារូបត្ថម្ភមាតា និងកុមារ ៖ តើអាចធ្វើអ្វី និងត្រូវចំណាយប៉ុន្មាន? The Lancet 382: 452–77។

៦០ វិទ្យាស្ថានជាតិស្ថិតិ ឆ្នាំ 2015 ការអង្កេតសុខភាព និងប្រជាសាស្ត្រនៅកម្ពុជា ឆ្នាំ 2014។

**រូប S11 ៖ វិសាលភាពនៃការផ្តល់សេវាសុខភាព និងអាហារូបត្ថម្ភសំខាន់ៗសម្រាប់មាតា និងកុមារ តាមបញ្ចភាគនៃទ្រព្យសម្បត្តិនៅកម្ពុជា 2014**




*ប្រភព* ៖ CDHS ឆ្នាំ 2014

ការផ្សព្វផ្សាយពីការលូតលាស់ និងការអន្តរាគមន៍ផ្លាស់ប្តូរការប្រព្រឹត្តិលើផ្នែកអាហារូបត្ថម្ភមាតា ទារក និងកុមារតូច ២) កង្វះលទ្ធភាពរកបានសេវាអាហារូបត្ថម្ភក្នុងសហគមន៍ និងតាមរយៈការចុះដល់សហគមន៍ផ្សព្វផ្សាយ ៣) មានតម្រូវការ និងការយល់ដឹងតិចតួចអំពីសេវាទប់ស្កាត់ និងផ្សព្វផ្សាយអាហារូបត្ថម្ភ[61]។

### ឃ.កង្វះលទ្ធភាពទទួលបានសេវាកម្មទឹកស្អាត និងអនាម័យល្អប្រសើរ

**លទ្ធភាពទទួលបានសេវាកម្មទឹកស្អាត និងអនាម័យល្អប្រសើរពាក់ព័ន្ធនឹងសន្ទស្សន៍មូលធនមនុស្ស (រូប S12) ចំណែកការបន្ទោរបង់ពាសវាលពាសកាលពាក់ព័ន្ធនឹងការកើតជំងឺក្រិនកុមារនៅកម្ពុជា (រូប S13)។** ការបន្ទោរបង់ពាសវាលពាសកាលក្នុងសហគមន៍បង្កគ្រោះថ្នាក់ដល់ការអភិវឌ្ឍផ្នែករូបរាងកាយ និងបញ្ញាស្មារតីរបស់កុមារ សូម្បីតែកុមារដែលរស់នៅក្នុងគ្រួសារដែលមានបង្គន់ក៏ដោយ។ កុមារដែលរស់នៅក្នុងមជ្ឈដ្ឋានគ្មានអនាម័យ (ដែលនៅក្បែរ និងស្រូបយកលាមកមនុស្ស និងសត្វជាញឹកញាប់) អាចមានបញ្ហាពោះវៀន កើតជំងឺរាករូស ខ្វះអាហារូបត្ថម្ភ និងកើតជំងឺក្រិន។

នៅកម្ពុជា លទ្ធភាពទទួលបានសេវាកម្មទឹកស្អាត និងអនាម័យល្អប្រសើរ មានភាពប្រសើរឡើងច្រើនកាលពីមួយទសវត្សរ៍កន្លងមក តែនៅមានការខ្វះចន្លោះ និងមានភាពចាំបាច់ក្នុងការផ្តោតលើគុណភាពសេវាកម្មផងដែរ។ កម្ពុជាសម្រេចបានសេវាកម្មទឹកស្អាតល្អប្រសើរ 75 ភាគរយ និងទទួលបានសេវាកម្មអនាម័យល្អប្រសើរ 49 ភាគរយនៅឆ្នាំ 2015[៦២]។ ប៉ុន្តែអត្រានេះនៅតែទាបខ្លាំងជាងមធ្យមភាគរបស់បណ្តាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាប (90 ភាគរយ និង 52 ភាគរយរៀងគ្នា)។ ក្នុងតំបន់ប្រជុំជន អត្រាលទ្ធភាពទទួលបានសេវាកម្មទឹកស្អាតល្អប្រសើរគឺ 78 ភាគរយសម្រាប់គ្រួសារក្រីក្របំផុត និង 99 ភាគរយសម្រាប់គ្រួសារស្តុកស្តម្ភបំផុត ចំណែកអត្រាលទ្ធភាពទទួលបានសេវាកម្មអនាម័យល្អប្រសើរគឺ 36 ភាគរយ និង 100 ភាគរយរៀងគ្នា[៦៣]។ ទោះបីជាមានវឌ្ឍនភាព

**រូប S12 ៖ លទ្ធភាពទទួលបានសេវាកម្មទឹកស្អាត និងអនាម័យល្អប្រសើរ និងសន្ទស្សន៍មូលធនមនុស្ស**




*ប្រភព* ៖ ការប៉ាន់ស្មានតាមគំរូរបស់ ILO, ឆ្នាំ 2016

[៦១] ធនាគារពិភពលោក ឆ្នាំ 2019 លទ្ធផលរកឃើញបឋម ៖ ការវាយតម្លៃប្រព័ន្ធផ្តល់ហិរញ្ញប្បទានដល់វិស័យសុខាភិបាលនៅកម្ពុជា។

[៦២] កម្មវិធីពិនិត្យតាមដានរួមរបស់ WHO/UNICEF (JMP) ឆ្នាំ 2017 (ធ្វើបច្ចុប្បន្នភាពនៅខែ កក្កដា ឆ្នាំ 2017)។ សម្គាល់ ៖ អនាម័យល្អប្រសើរសំដៅលើភាពប្រសើរឡើងផ្នែកអនាម័យដោយមិនរួមបញ្ចូលប្រើបង្គន់រួម។ ប្រសិនបើប្រើបង្គន់រួម អត្រានេះគឺ 57 ភាគរយ។

[៦៣] កម្មវិធីពិនិត្យតាមដានរួមរបស់ WHO/UNICEF (JMP) ឆ្នាំ 2015។

ល្អប្រសើរក្តី ក៏សមាមាត្រប្រជាជនដែលបន្ទោរបង់ពាសវាលពាសកាលនៅតែមានកម្រិតខ្ពស់បំផុត ធៀបនឹងបណ្តាប្រទេសនៅអាស៊ីបូព៌ា និងប៉ាស៊ីហ្វិក។ ប្រជាជនកម្ពុជាតែ24 ភាគរយប៉ុណ្ណោះ ដែលមានលទ្ធភាពទទួលបានសេវាកម្មទឹកស្អាតមានសុវត្ថិភាពនៅឆ្នាំ 2015[៦៤][៦៥]។ ការដោះស្រាយបញ្ហាប្រឈមពាក់ព័ន្ធនឹងការផ្តល់សេវាកម្មទឹក និងអនាម័យអាចជាកត្តាដ៏សំខាន់ដែលចូលរួមចំណែកដល់ការអភិវឌ្ឍធនធានមនុស្សនៅកម្ពុជា។

### ង.បញ្ហាធនធានសម្រាប់ស្ត្រីក្នុងការទទួលបានការថែទាំល្អបំផុត

**រូប S13 ៖ ការលូតលាស់យឺតនៃទម្ងន់ និងកម្ពស់កុមារ (ពិន្ទុ z នៃកំពស់ធៀបនឹងអាយុ) សម្រាប់គ្រួសារដែលមាន និងគ្មានបង្គន់ ទៅតាមកម្រិតផ្សេងៗនៃការបន្ទោរបង់ពាសវាលពាសកាល (2010)**




*ប្រភព* ៖ ការប៉ាន់ស្មានតាមគំរូរបស់ ILO, ឆ្នាំ 2016

**រូប S14 ៖ អត្រាស្ត្រីកម្ពុជាដែលប្រឡូកក្នុងកម្លាំងពលកម្ម ធៀបនឹងប្រទេសក្នុងតំបន់**




*ប្រភព* ៖ ការប៉ាន់ស្មានតាមគំរូរបស់ ILO, ឆ្នាំ 2016

**ការចូលរួមរបស់ស្ត្រីក្នុងកម្លាំងពលកម្មមានអត្រាខ្ពស់ជាងប្រទេសផ្សេងទៀតក្នុងតំបន់** (រូប S14) **និងគាំទ្រដល់វិស័យកម្មន្តសាល។** អត្រាស្ត្រីកម្ពុជាវ័យ ពី 15 ដល់ 64 ឆ្នាំដែលធ្វើការយ៉ាងតិច 1 ម៉ោងកាលពីសប្តាហ៍មុន គឺ 80 ភាគរយ ធៀបនឹងអត្រាជាមធ្យមត្រឹមតែ 66 ភាគរយសម្រាប់ប្រទេសនៅអាស៊ីបូព៌ា និងប៉ាស៊ីហ្វិក។ ស្ត្រីកម្ពុជាជិត 23 ភាគរយធ្វើការក្នុងវិស័យកម្មន្តសាលនៅឆ្នាំ 2015 ធៀបនឹងអត្រាត្រឹមតែ 21 ភាគរយនៅថៃ និង 19 ភាគរយនៅវៀតណាម[៦៦]។ វិស័យកម្មន្តសាលបានជួយបង្កើនអត្រាការងារទទួលបានប្រាក់ឈ្នួល។ នៅឆ្នាំ 2016 មានស្ត្រីធ្វើការ 42 ភាគរយដែលមានការងារទទួលបានប្រាក់ឈ្នួល។ ក្នុងនោះស្ត្រីជិត 50 ភាគរយបម្រើការក្នុងវិស័យកាត់ដេរ។ ក្រៅពីនេះ មានការកើនឡើងយ៉ាងច្រើននៃចំនួនការងារដែលទទួលបានប្រាក់ឈ្នួលរបស់ស្ត្រីក្នុងវិស័យសេវា និងសំណង់នៅអំឡុងឆ្នាំ 2011-2016 (រូប S15)។

**ស្ត្រីកម្ពុជាដែលធ្វើការក្នុងឧស្សាហកម្មសម្លៀកបំពាក់ និងស្បែកជើង ប្រឈមនឹងការលំបាកក្នុងការគ្រប់គ្រងតុល្យភាពការងារ និងតួនាទីថែទាំ ទោះបីជាច្បាប់ស្តីពីការងារបានចែងពីចំណុចនេះក្តី។** កម្មការនីរោងចក្រសម្លៀកបំពាក់ និងស្បែកជើងភាគច្រើន មិនអាចយកកូនមករស់នៅជាមួយខ្លួនបានទេ ដោយសារតែការចំណាយខ្ពស់លើថ្លៃស្នាក់នៅ និងការថែទាំកុមារ។ ជាទូទៅ កម្មការនីរោងចក្រកាត់ដេរដែលមានកូនត្រូវចំណាយប្រហែល 50 ភាគរយលើការរស់នៅ និងការអប់រំរបស់កុមារច្រើន

**រូប S15 ៖ ការងារទទួលបានប្រាក់ឈ្នួលរបស់ស្ត្រី តាមវិស័យ នៅកម្ពុជា**




*ប្រភព* ៖ CSES ឆ្នាំ 2011 និង ឆ្នាំ 2016. ក្នុង ៖ Gavalyugova, Dimitria and Wendy Cunningham. ឆ្នាំ 2019 “ការវិភាគយេនឌ័រក្នុងទីផ្សារការងារនៅកម្ពុជា” ធនាគារពិភពលោក។ សរសេរមិនទាន់ចប់ ។

---

៦៤ សេវាកម្មទឹកស្អាតដែលត្រូវបានគ្រប់គ្រងដោយសុវត្ថិភាពសំដៅលើប្រភពផ្តល់ទឹកពិសាល្អប្រសើរដែលស្ថិតនៅក្នុងបរិវេណអគារ មានតាមតម្រូវការ និងមិនបំពុលដោយលាមក និងសារធាតុគីមី។ សេវាកម្មអនាម័យដែលត្រូវបានគ្រប់គ្រងដោយសុវត្ថិភាពសំដៅលើហេដ្ឋារចនាសម្ព័ន្ធអនាម័យល្អប្រសើរដែលមិនត្រូវបានប្រើប្រាស់រួមជាមួយគ្រួសារផ្សេងទៀត និងមានការបន្ទោរបង់លាមកដោយសុវត្ថិភាពក្នុងទីតាំងដើម ឬត្រូវបានដឹកជញ្ជូន និងធ្វើប្រព្រឹត្តកម្មនៅក្រៅទីតាំង។

៦៥ កម្មវិធីពិនិត្យតាមដានរួមរបស់ WHO/UNICEF (JMP) ឆ្នាំ 2017។ កត់សម្គាល់ថា គ្មានការប៉ាន់ស្មានពី។ សេវាកម្មអនាម័យដែលត្រូវបានគ្រប់គ្រងដោយសុវត្ថិភាពឡើយ។

៦៦ Gavalyugova, Dimitria and Wendy Cunningham ឆ្នាំ 2019 “ការវិភាគយេនឌ័រក្នុងទីផ្សារការងារនៅកម្ពុជា” ធនាគារពិភពលោក។ កំពុងសរសេរមិនទាន់ចប់។

ជាងកម្មការនីនៅលីវ[៦៧]។ លើសពីនេះទៀត ការអនុវត្តរបស់រោងចក្រ ជាទូទៅ មិនគោរពតាមបទប្បញ្ញត្តិស្តីពីការថែទាំកុមារ និងការបំបៅដោះកូន ដោយរោងចក្រដែលស្ថិតក្រោមការអង្កេត 72 ភាគរយមិនអនុលោមតាមបទប្បញ្ញត្តិដែលកំណត់ឲ្យមានបន្ទប់ថែទាំកុមារដែលអាចប្រើប្រាស់បាន និងមណ្ឌលថែទាំកុមារដែលដំណើរការ[៦៨]។

**ទោះបីជាកើតមានករណីដូចខាងលើហើយ ច្បាប់ស្តីពីការងារមិនមានមាត្រាចែងពី ស្ត្រីកម្ពុជាដែលធ្វើការជាច្រើននោះឡើយ។** ទោះបីជាស្ត្រីត្រូវបានចាត់ទុកថាជាចលករជំរុញឧស្សាហកម្មកាត់ដេរផ្លូវការក្តី ប៉ុន្តែការចូលរួមចំណែករបស់ស្ត្រីក៏កើនឡើងដែរក្នុងការងារឯកជនដែលទទួលបានប្រាក់ឈ្នួល ដូចជា វិស័យសេវា (ឧ. បដិសណ្ឋារកិច្ច និងអប់រំ) កសិកម្ម និងសំណង់ ដែលភាគច្រើននៅតែមានលក្ខណៈក្រៅផ្លូវការ។ ឧទាហរណ៍ ស្ត្រីធ្វើការជាង 500,000 នាក់ស្ថិតក្នុងវិស័យការងារទទួលបានប្រាក់ឈ្នួលក្រៅផ្លូវការក្នុងវិស័យសេវា និងសំណង់[៦៩]។ ស្ត្រីដែលធ្វើការក្នុងវិស័យក្រៅប្រព័ន្ធទាំងនេះមិនសូវទទួលបានការការពារផ្លូវការដូចកម្មករនិយោជិតក្នុងរោងចក្រកាត់ដេរធំៗឡើយ (ឧទាហរណ៍ ការការពារមាតា បន្ទុកការងារ ប្រាក់ឈ្នួល ការបំបៅដោះកូន ការថែទាំកុមារ។ល។)។

**អាស្រ័យហេតុនេះ ស្ត្រីកម្ពុជាមិនសូវមានពេលវេលាមើលថែកូនតូចឡើយ។** ដោយសារតែការចំណាយខ្ពស់ ការលំបាក និងកង្វះសុវត្ថិភាពក្នុងការផ្លាស់ផ្ទះ ឬធ្វើដំណើរទៅមកជាមួយម្តាយជាញឹកញាប់ ម្តាយទុកកូនតូចឲ្យនៅជាមួយអ្នកថែទាំផ្សេងទៀត (ឧ. ជីដូន អ្នកជិតខាង បងប្អូនបង្កើត) ក្នុងរយៈពេលយូរ។ មានការព្រួយបារម្ភចំពោះអ្នកថែទាំទាំងនេះថាគាត់ថែទាំមិនបានល្អ និងជួយអភិវឌ្ឍកុមារ ជាពិសេសជីដូន ដែលមិនសូវមានជំនាញ និងសមត្ថភាពក្នុងការមើលថែកុមារតូច[៧០]។ យោងតាម DHS ឆ្នាំ 2014 កុមារកម្ពុជាម្នាក់ក្នុងចំណោមកុមារ 10 នាក់ដែលមានអាយុក្រោម 5 ឆ្នាំត្រូវគេទុកចោលដោយមិនទទួលបានការថែទាំគ្រប់គ្រាន់[៧១]។

**មានភស្តុតាងកាន់តែច្រើនបានបង្ហាញតួនាទីថែទាំរបស់ស្ត្រី និងកុមារ ថាជាកត្តាបង្កបញ្ហាកង្វះអាហារូបត្ថម្ភ។** តួនាទីយេនឌ័រតាមប្រពៃណី និងប្រព័ន្ធសង្គមទន់ខ្សោយក្នុងការផ្តល់ការថែទាំ និងចំណីអាហារដល់កុមារ (ទាំងផ្លូវការ និងក្រៅផ្លូវការ) អាចប៉ះពាល់ដោយហួសពីការស្មានទៅលើការផ្តល់ចំណីអាហារ និងអាហារូបត្ថម្ភដល់ទារក និងកុមារតូច។ ការវិភាគថ្មីៗបង្ហាញថាមានទំនាក់ទំនងគ្នារវាងតួនាទីផលិតភាព និងតួនាទីបន្តពូជរបស់ស្ត្រី ដោយអត្ថប្រយោជន៍ដែលទទួលបានពីប្រាក់ចំណូលបន្ថែមអាចកាត់បន្ថយអត្រាបំបៅដោះកូន ប៉ុន្តែបង្កើនការផ្តល់អាហារបំប៉នបន្ថែម។ ក្នុងចំណោមកុមារអាយុពី 0 ដល់ 5 ឆ្នាំទាំងអស់ ការងាររបស់ម្តាយ និងការងារពេញមួយឆ្នាំ សុទ្ធតែពាក់ព័ន្ធនឹងលទ្ធផលប្រសើរឡើងដល់ មាត្រសាស្ត្រ ព្រមទាំងការផ្តល់ចំណីអាហារដល់ទារក និងកុមារតូច។ ប៉ុន្តែកត្តាទាំងពីរនេះអាចផ្តល់ផល អាក្រក់ (ការស្គមស្គាំង ទម្ងន់ស្រាល និងកម្ពស់ទាបធៀបនឹងអាយុ) ក្នុងចំណោមកុមារអាយុក្រោម 2 ឆ្នាំ ធៀបនឹងកុមារទាំងអស់ដែលអាយុក្រោម 5 ឆ្នាំ (រូប S16 និង S17)។

**រូប S16 ៖ លទ្ធផលនៃការផ្តល់អាហារចិញ្ចឹមដល់ទារក និងកុមារតូច (អាយុ 0-23 ខែ) ដែលពាក់ព័ន្ធនឹងការចូលរួមចំណែករបស់ម្តាយក្នុងកម្លាំងពលកម្ម, 2014**




*ប្រភព* ៖ ការគណនារបស់អ្នកនិពន្ធពី CDHS ឆ្នាំ 2014។ MAD: អាហារដែលអាចទទួលយកបានជាអប្បបរមា MDD: អាហារផ្សេងៗជាអប្បបរមា *MMF:* ភាពញឹកញាប់នៃអាហារជាអប្បបរមា *p<0.10 **p<0.05 ***p<0.01

៦៧ សូមមើលផ្នែកអត្ថបទជម្រើសស្តីពីវិស័យកាត់ដេរក្នុងទស្សនៈវិស័យ, ខែ តុលា ឆ្នាំ 2016 បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា ធនាគារពិភពលោក។

៦៨ អង្គការអន្តរជាតិខាងការងារ (ILO) ឆ្នាំ 2018 កម្មវិធីរោងចក្រកាន់តែប្រសើរនៅកម្ពុជា ៖ ឆ្ពោះទៅរកសមភាពយេនឌ័រ ៖ មេរៀនពីការវាយតម្លៃការអនុលោមតាមរបស់រោងចក្រ ទីក្រុងហ្សឺណែវ ៖ ILO។

៦៩ សូមមើលផ្នែកអត្ថបទជម្រើសស្តីពីការងារនាពេលអនាគតនៅកម្ពុជា, ខែ មេសា ឆ្នាំ 2018 បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា ធនាគារពិភពលោក។

៧០ សូមមើល ឧ.៖ ធនាគារពិភពលោក និង Planete Enfants & Developpement. លទ្ធផលនៃកិច្ចពិគ្រោះយោបល់ស្តីពីទស្សនទាននៃការថែទាំកុមារតាមសហគមន៍ សម្រាប់កម្មការនីរោងចក្រកាត់ដេរ។ សរសេរមិនទាន់ចប់ ឬមិនទាន់បោះពុម្ព

៧១ ត្រូវបានកំណត់និយមន័យជាការទុកចោលឲ្យនៅតែឯង ឬស្ថិតក្រោមការមើលថែរបស់កុមារ នៅអាយុក្រោម 10 ឆ្នាំ។

លើសពីនេះ មានការថយចុះនៃការផ្តល់ចំណីអាហារដល់ទារក និងកុមារតូច បើរាប់បញ្ចូលតែស្ត្រីដែលធ្វើការក្នុងវិស័យក្រៅពីកសិកម្ម (រូប S16)។

### ច.កង្វះខាតការទទួលបាន និងប្រសិទ្ធភាពនៃការចំណាយសាធារណៈលើសុខភាព និងអាហារូបត្ថម្ភសម្រាប់កុមារ[៧២]

**កម្ពុជាចំណាយថវិកាជាច្រើនលើវិស័យសុខាភិបាល (ប្រមាណ 6-7 ភាគរយនៃ ផសស) បើធៀបនឹងប្រទេសផ្សេងទៀត (រូប S18) ប៉ុន្តែខ្ទង់ចំណាយសាធារណៈលើវិស័យសុខាភិបាលមានកម្រិតទាប (1.3 ភាគរយនៃ ផសស នៅឆ្នាំ 2015)។** ចំណាយសាធារណៈមានចំនួន 22 ភាគរយនៃចំណាយសរុបលើវិស័យសុខាភិបាលសរុប ប៉ុន្តែចំណាយរបស់រដ្ឋាភិបាលលើថ្លៃសុខាភិបាលក្នុងមនុស្សម្នាក់ៗ នៅតែមានកម្រិតទាបធៀបនឹងប្រទេសផ្សេងទៀតក្នុងតំបន់ប្រមាណ 16 ដុល្លា (រូប S19)។ ការបង្កើនចំណាយសាធារណៈលើវិស័យសុខាភិបាលត្រូវបានជំរុញដោយកំណើនម៉ាក្រូសេដ្ឋកិច្ច ជាជាងការកំណត់យកវិស័យនេះជាអាទិភាព (រូប S20 និង S21)។

**អត្រានៃចំណាយខ្ពស់ពីការចំណាយផ្ទាល់ខ្លួន និងការពឹងផ្អែកលើហិរញ្ញប្បទានខាងក្រៅ គឺជាបញ្ហាប្រឈមក្នុងការរក្សានិរន្តរភាពហិរញ្ញប្បទាននៃសេវាសុខាភិបាលឲ្យបានជាសកលសម្រាប់មនុស្សគ្រប់រូប។** ចំណាយលើផ្នែកសុខភាពភាគច្រើនជាចំណាយពីការចំណាយផ្ទាល់ខ្លួន។ ក្នុងចំណោមវិស័យនានា វិស័យសុខាភិបាលនៅកម្ពុជាទទួលបានចំណែកហិរញ្ញប្បទានធំជាងគេពីជំនួយអភិវឌ្ឍន៍ពីបរទេស ប៉ុន្តែការផ្តល់ហិរញ្ញប្បទានពីខាងក្រៅបានថយចុះតាំងពីឆ្នាំ 2011។ ត្រឹមឆ្នាំ 2017 ហិរញ្ញប្បទានពីខាងក្រៅមានចំនួនជិតពាក់កណ្តាលនៃចំនួនឆ្នាំ 2002 (រូប S22)។

**រូប S17 ៖ លទ្ធផលមាត្រសាស្ត្ររបស់ទារក និងកុមារតូច (អាយុ0-23 ខែ) ដែលពាក់ព័ន្ធនឹងការចូលរួមចំណែករបស់ម្តាយក្នុងកម្លាំងពលកម្ម, 2014**




*ប្រភព* ៖ ការគណនារបស់អ្នកនិពន្ធពី CDHS 2014។ *p<0.10 **p<0.05 ***p<0.01

**រូប S18 ៖ ចំណាយសរុបរបស់កម្ពុជាលើវិស័យសុខាភិបាលមានកម្រិតខ្ពស់ជាងបណ្តាប្រទេសក្នុងតំបន់**

ចំណាយសរុបលើវិស័យសុខាភិបាលធៀបនឹង ផសស, 2015




*ប្រភព* ៖ មូលដ្ឋានទិន្នន័យចំណាយលើវិស័យសុខាភិបាលទូទាំងពិភពលោក, WHO

**រូប S19 ៖ ចំណាយរបស់កម្ពុជាលើវិស័យសុខាភិបាលសាធារណៈសម្រាប់មនុស្សម្នាក់មានអត្រាទាបបំផុតធៀបនឹងបណ្តាប្រទេសក្នុងតំបន់**

ចំណាយលើវិស័យសុខាភិបាលសាធារណៈសម្រាប់មនុស្សម្នាក់, 2015




*ប្រភព* ៖ មូលដ្ឋានទិន្នន័យចំណាយលើវិស័យសុខាភិបាលទូទាំងពិភពលោក, WHO

[៧២] ដោយសារតែសារៈសំខាន់នៃការអន្តរាគមន៍អាហារូបត្ថម្ភសម្រាប់ការបង្កើនអាហារូបត្ថម្ភ និងការលូតលាស់របស់កុមារ ផ្នែកនេះផ្អែកលើលទ្ធផលរកឃើញបឋមពីរបាយការណ៍ដែលដឹកនាំដោយ Emiko Masaki ៖ ការវាយតម្លៃការផ្តល់ហិរញ្ញប្បទានដល់វិស័យសុខាភិបាលនៅកម្ពុជា, ធនាគារពិភពលោក។ សរសេរមិនទាន់ចប់។ របាយការណ៍នេះផ្តោតលើនិន្នាការនៃការចំណាយសាធារណៈលើវិស័យសុខាភិបាល ជាប្រភពនៃការផ្តល់សេវាអាហារូបត្ថម្ភ។

**ទោះបីជា ចំណាយលើវិស័យសុខាភិបាលសាធារណៈបានកើនឡើងយឺតយ៉ាវក្ដី ក៏គំនិតផ្ដួចផ្ដើមថ្មីៗក្នុងការផ្ដល់ហិរញ្ញប្បទានសុខភាព និងការផ្ដល់សេវា បានជួយបង្កើនផលិតភាព និងប្រសិទ្ធភាពរបស់ការវិនិយោគវិស័យសុខាភិបាលក្នុងលើកកម្ពស់កម្រិតសុខភាព និងអាហារូបត្ថម្ភ របស់ប្រជាជនកម្ពុជា។** ជាពិសេស ការពង្រីកមូលនិធិសមធម៌សុខភាព និងប្រព័ន្ធផ្ដត់ផ្ដង់សេវានៃឥណទានឥតសំណងបាន 1) កៀរគរធនធានដល់ការផ្ដល់សេវាជួរមុខ 2) បង្កើនការលើកទឹកចិត្ត និងគណនេយ្យភាពរបស់បុគ្គលិកសុខាភិបាល 3) ត្រួតពិនិត្យជាប្រព័ន្ធ និងផ្អែកតាមវចនាសម្ព័ន្ធ 4) បង្កើតប្រព័ន្ធទិន្នន័យដែលពង្រឹងតម្លាភាព និង 5) បង្កើនសេវាសាធារណៈដែលមានការឆ្លើយតប និងផ្ដោតការយកចិត្តទុកដាក់លើប្រជាពលរដ្ឋ។

**គួរឲ្យសោកស្ដាយដែលប្រព័ន្ធសំខាន់ៗខាងហិរញ្ញប្បទានសុខាភិបាល និងខាងផ្ដត់ផ្ដង់សេវាទាំងនេះ បានដោះស្រាយបញ្ហាអាហារូបត្ថម្ភតែក្នុងកម្រិតតិចតួចប៉ុណ្ណោះ។** ការវិនិយោគលើអាហារូបត្ថម្ភក្នុងវិស័យសុខាភិបាល មានកម្រិតទាប មិនស៊ីសង្វាក់គ្នា និងភាគច្រើនជាការផ្ដល់ហិរញ្ញប្បទានពីខាងក្រៅ (រូប S23)។ កម្មវិធីជាតិអាហារូបត្ថម្ភរបស់កម្ពុជាប្រតិបត្តិការតាមខ្សែបណ្ដោយដោយមិនបានផ្សារភ្ជាប់ ជាអចិន្ត្រៃយ៍ទៅក្នុងប្រព័ន្ធផ្ដល់សេវាសុខាភិបាលសាធារណៈ និងអ្នកផ្ដល់សេវាជួរមុខ។

**ក្នុងកម្មវិធីសុខាភិបាលទាំងមូល កម្មវិធីអាហារូបត្ថម្ភកំពុងប្រឈមនឹងការប្រែប្រួលការផ្ដល់ហិរញ្ញប្បទានពីខាងក្រៅ។** មានវឌ្ឍនភាពតិចតួចក្នុងការដាក់បញ្ចូលការផ្ដល់ហិរញ្ញប្បទាននេះក្នុងថវិកាជាតិ នៅពេលដែលកម្មវិធីជាតិសុខភាពមាតា និងកុមារ[៧៣] ទទួលបានចំណែកថវិកា 6-7 ភាគរយនៃថវិកាសរុបសម្រាប់ក្រសួងសុខាភិបាលនៅឆ្នាំ 2016-2018 កម្មវិធីជាតិអាហារូបត្ថម្ភទទួលបានចំណែកថវិកាតិចជាង 1 ភាគរយ (ថវិកាមធ្យមប្រចាំឆ្នាំ គឺ 127,000 ដុល្លា) នៃចំណែកថវិកាសម្រាប់កម្មវិធីសុខភាពមាតា និងកុមារ (រូប S24)។ មានការរំពឹងថា នឹងមានការរាំងស្ទះលើការផ្ដល់សេវាដូចដែលបានកំណត់ខាងលើ។

**មានសក្ដានុពលនៃការផ្ដល់ហិរញ្ញប្បទានក្នុងស្រុកសម្រាប់កម្មវិធីសុខភាព និងអាហារូបត្ថម្ភកុមារតូចតាមរយៈមូលនិធិឃុំ/សង្កាត់ ប៉ុន្តែគេមិនទាន់អាចសម្រេចបានសក្ដានុពលនេះឡើយ។** ក្រោមអាណត្តិទូទៅរបស់ឃុំ/សង្កាត់ អាជ្ញាធរមូលដ្ឋានមានអំណាចគាំទ្រការវិនិយោគសេវាសង្គម និងកិច្ចគាំពារសង្គម រួមទាំងអាហារូបត្ថម្ភ និងសុខភាពមាតា និងកុមារ។ ការបែងចែកមូលនិធិឃុំ/សង្កាត់ប្រចាំឆ្នាំកើនឡើងជាបន្តបន្ទាប់ចំនួន 2 ភាគរយតាំងពីឆ្នាំ 2003 និងកើនដល់ចំនួនថវិកាសរុប 93 លានដុល្លានៅឆ្នាំ 2017 ប៉ុន្តែ មានចំណែកថវិកាត្រឹមតែមួយភាគបីនៃថវិកាសរុប (ជាមធ្យម 6,3000 ដុល្លាក្នុងមួយឃុំ/សង្កាត់) ប៉ុណ្ណោះដែលត្រូវបានប្រើប្រាស់សម្រាប់សកម្មភាពអភិវឌ្ឍន៍[៧៤]។ ជារួម ទោះបីជាមូលនិធិសរុបបានកើនឡើងក្ដី ក៏ការវិនិយោគលើការអភិវឌ្ឍក្នុងមនុស្សម្នាក់ នៅតែមានកម្រិតទាបនៅឡើយ (2.37 ដុល្លាក្នុងម្នាក់នៅឆ្នាំ 2017) និងមានអត្រាកើនតិចតួចធៀបឆ្នាំ 2013[៧៥]។ ទោះជាយ៉ាងនេះក្ដី ដំណើរការរៀបចំផែនការវិនិយោគឃុំ និងនីតិវិធីលទ្ធកម្មស្មុគស្មាញ តែងរឹតត្បិតការវិនិយោគរបស់ឃុំ/សង្កាត់លើសេវាសង្គម/គម្រោងអភិវឌ្ឍន៍ក្នុងមូលដ្ឋាន។

**រូប S20 ៖ ចំណាយលើវិស័យសុខាភិបាលសាធារណៈក្នុងមនុស្សម្នាក់ បានកើនឡើងតាំងពីមួយទសវត្សរ៍មុន។**




*ប្រភព* ៖ ការប៉ាន់ស្មានរបស់អ្នកនិពន្ធ

**រូប S21 ៖ កំណើនសេដ្ឋកិច្ចរឹងមាំរបស់កម្ពុជាមិនបានជំរុញឲ្យមានការវិនិយោគប្រដំប្រសងគ្នាលើវិស័យសុខាភិបាលសាធារណៈឡើយ។**




*ប្រភព* ៖ ទស្សនៈវិស័យសេដ្ឋកិច្ចពិភពលោករបស់ IMF, មូលដ្ឋានទិន្នន័យស្ដីពីចំណាយលើវិស័យសុខាភិបាលទូទាំងពិភពលោក, WHO

---

៧៣ រួមមានអនុកម្មវិធីសម្រាប់សុខភាពបន្តពូជ ការថែទាំមាតា និងទារក សុខភាពកុមារ (រួមទាំងការចាក់ថ្នាំបង្ការ) និងអាហារូបត្ថម្ភ។

៧៤ រហូតដល់ឆ្នាំ 2013 ទើបបញ្ញត្តិច្បាប់កំណត់ថា ចំណាយផ្នែករដ្ឋបាលមិនត្រូវលើសពីមួយភាគបីនៃការផ្ដល់មូលនិធិសរុប។ នៅឆ្នាំ 2017 ចំណាយផ្នែករដ្ឋបាលកើនឡើងដល់ 61 ភាគរយនៃចំណាយសរុប។ ការចំណាយបែបនេះនេះឆ្លុះបញ្ចាំងពីបញ្ហាដែលអាចកើតមានពាក់ព័ន្ធនឹងប្រសិទ្ធភាពបែងចែកថវិកា ព្រោះកាលណាតម្លើងប្រាក់បៀវត្សរ៍ ការចំណាយអភិវឌ្ឍន៍លើគម្រោងមូលធន នឹងត្រូវកាត់ ហើយបណ្ដាលឲ្យត្រូវកាត់បន្ថយប្រសិទ្ធភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

៧៥ ធនាគារពិភពលោក ឆ្នាំ 2018 ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈចម្រុះវិស័យនៅកម្ពុជា ៖ វិមជ្ឈការ និងកំណែទម្រង់រដ្ឋបាលសាធារណៈ ៖ សមិទ្ធផល ការសម្របសម្រួល បញ្ហាប្រឈម និងជំហានបន្ទាប់។ ក្រុងភ្នំពេញ ៖ ធនាគារពិភពលោក។

**រូប S22 ៖ សមាសភាគនៃការផ្តល់ហិរញ្ញប្បទានដល់វិស័យសុខាភិបាលនៅកម្ពុជា និងក្រុមប្រទេសដែលយកមកប្រៀបធៀប។**




*ប្រភព* ៖ មូលដ្ឋានទិន្នន័យស្តីពីចំណាយលើវិស័យសុខាភិបាលទូទាំងពិភពលោក, WHO ឆ្នាំ 2017 SHI: ការធានារ៉ាប់រងសុខភាពសង្គម CPS: របបសោធនដោយមានភាគទាន OPP: លើសពីការចំណាយផ្ទាល់ខ្លួន

**រូប S23 ៖ ការចំណាយលើវិស័យសុខាភិបាលតាមកម្មវិធី និងប្រភព** (ទិន្នន័យមានឆ្នាំចុងក្រោយបង្អស់)




*ប្រភព* ៖ UNAIDS, មូលដ្ឋានទិន្នន័យពិនិត្យតាមដានជំងឺអេដស៍ទូទាំងពិភពលោក 2018។ របាយការណ៍ជំងឺគ្រុនចាញ់ទូទាំងពិភពលោក, WHO ឆ្នាំ 2017។ របាយការណ៍ជំងឺរបេងទូទាំងពិភពលោក, WHO ឆ្នាំ 2018។ *WHO/UNICEF*, JRF, ឆ្នាំ 2018។

*សម្គាល់* ៖ ផ្សេងៗ រួមបញ្ចូលចំណាយពីការចំណាយផ្ទាល់ខ្លួន និងការធានារ៉ាប់រងសុខភាព។

**រូប S24 ៖ ថវិកាសម្រាប់កម្មវិធីសុខភាពមាតា និងកុមារ* តាមអនុកម្មវិធី ក្រសួងសុខាភិបាល ឆ្នាំសារពើពន្ធ ឆ្នាំ 2016-2018**




*ប្រភព* ៖ អគ្គនាយកដ្ឋានថវិកា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សេចក្តីសង្ខេបថវិកាសម្រាប់ឆ្នាំសារពើពន្ធ ឆ្នាំ 2016, ឆ្នាំ 2017, ឆ្នាំ 2018

## ៥.ជម្រើសគោលនយោបាយ

ប្រសិនបើគ្មានកិច្ចខិតខំប្រឹងប្រែង និងការយកចិត្តទុកដាក់ខ្ពស់ក្នុងការដោះស្រាយបញ្ហាសុខភាព និងអាហារូបត្ថម្ភនៅវ័យកុមារភាព កម្ពុជាលំបាកនឹងមានមូលដ្ឋានមូលធនមនុស្សរបស់ខ្លួនដែលស្របទៅនឹងគោលបំណងអភិវឌ្ឍន៍ជាតិរបស់ខ្លួន។ នៅប្រទេសវៀតណាម ក្រៅពីការកាត់បន្ថយភាពក្រីក្រយ៉ាងឆាប់រហ័ស និងកំណើនសេដ្ឋកិច្ចរឹងមាំ យ៉ាងហោចណាស់មានសមិទ្ធផលបីដែលអាចរួមចំណែកដល់ការកាត់បន្ថយយ៉ាងឆាប់រហ័សនូវអត្រាកើតជំងឺក្រិន គឺការកំណត់យកអាហារូបត្ថម្ភជាចំណុចអាទិភាពដោយរដ្ឋាភិបាលជាតិ គោលនយោបាយជំរុញការផ្តល់អាហារដល់ទារក និងកុមារ និងកិច្ចខិតខំប្រឹងប្រែងកាត់បន្ថយកង្វះមីក្រូសារជាតិចិញ្ចឹម[៧៦]។

ការបង្កើនវិសាលភាព និងប្រសិទ្ធភាពនៃការវិនិយោគរបស់បុគ្គលម្នាក់ៗ វិស័យសាធារណៈ និងវិស័យឯកជន អាចជួយធានាបានថា កុមារទទួលបានការចាប់ផ្តើមប្រកបដោយភាពឆ្លាតវៃ ដែលត្រៀមខ្លួនកុមារសម្រាប់ការបង្កើនការអប់រំ និងអភិវឌ្ឍជំនាញរបស់ពួកគេឲ្យបានជាអតិបរមា។ ការវិនិយោគទាំងនេះនឹងបន្តជួយដល់កម្ពុជាក្នុងការទាញប្រយោជន៍ពីភាគលាភប្រជាសាស្ត្រ និងបង្កើនធនធានផលិត និងធនធានធម្មជាតិរបស់ខ្លួនឲ្យបានជាអតិបរមា។ អ្នកតាក់តែងគោលនយោបាយអាចចាត់វិធានការជាច្រើនខាងក្រោម ដើម្បីរួមចំណែកដល់ការសម្រេចបានវឌ្ឍនភាពលើផ្នែកនេះ ៖

1. **រៀបចំផែនការមេដែលមានវិសាលភាពទូលំទូលាយស្តីពីមូលធនមនុស្ស ដែលចាប់ផ្តើមតាំងពីរយៈពេលប៉ុន្មានឆ្នាំដំបូងសម្រាប់ជាត្រីវិស័យដល់ការវិនិយោគក្នុងស្រុក។** គេអាចចាត់វិធានការភ្លាមៗដើម្បីបង្កើតចក្ខុវិស័យជាយុទ្ធសាស្ត្រដើម្បីបង្កើនមូលធនមនុស្សដែលនៅពេលតែមួយ 1) បំពេញតម្រូវការនៃការអភិវឌ្ឍជំនាញរយៈពេលខ្លី និងការបង្កើនគុណភាពអប់រំក្នុងរយៈពេលមធ្យម និង 2) គាំទ្រការវិនិយោគរយៈពេលវែងលើផ្នែកសុខភាព អាហារូបត្ថម្ភ និងការអភិវឌ្ឍរបស់កុមារតូច។ យុទ្ធសាស្ត្រទាំងពីរនេះគួរតែត្រូវអនុវត្តនៅពេលដំណាលគ្នា ដើម្បីបញ្ចៀសការបាត់បង់សក្តានុពលរបស់កុមារតូច ដែលអាចកើតឡើង ប្រសិនបើអនុវត្តការវិនិយោគទាំងនេះដាច់ដោយឡែកពីគ្នា។ ដូចលើកឡើងខាងក្រោម វឌ្ឍនភាពអាចសម្រេចទៅបានតាមរយៈការផ្សារភ្ជាប់កម្មវិធី និងការអន្តរាគមន៍ថ្នាក់វិស័យ និងការជំរុញការចូលរួមរបស់វិស័យឯកជន និងក្រុមគ្រួសារ។

### យុទ្ធសាស្ត្រជាក់លាក់ថ្នាក់វិស័យ

ដើម្បីលុបបំបាត់គម្លាតលទ្ធផលអាហារូបត្ថម្ភក្នុងដំណាក់កាលដំបូងនៃជីវិត ត្រូវចាត់វិធានការជាច្រើនដើម្បី 1) កំណត់យកអាហារូបត្ថម្ភជាចំណុចអាទិភាពដោយផ្អែកលើធនធានរបស់វិស័យដែលមានស្រាប់ និង 2) ផ្តោតលើការកែលម្អគុណភាពដើម្បីបង្កើនប្រសិទ្ធភាពនៃការចំណាយលើវិស័យសាធារណៈ។

2. **ទាញប្រយោជន៍ពីកំណែទម្រង់ប្រព័ន្ធផ្តល់ហិរញ្ញប្បទានដល់វិស័យសុខាភិបាល និងប្រព័ន្ធផ្តល់សេវា ដើម្បីបង្កើនវិសាលភាព និងគុណភាពនៃសេវាសុខភាព និអាហារូបត្ថម្ភមាតា និងកុមារនៅតាមទីកន្លែងសាធារណៈ។** អាទិភាពទីមួយគឺការធានាបានការទទួលបាន និងគុណភាពនៃសេវាអាហារូបត្ថម្ភ ដូចជា ការពិគ្រោះយោបល់ស្តីពីអាហារូបត្ថម្ភមាតា (ជាពិសេសតាមរយៈការថែទាំមុនពេលសម្រាល) ការចុះពិនិត្យតាមដានកុមារជាប្រចាំ រួមទាំងការចាក់ថ្នាំបង្ការ និងការលើកកម្ពស់ការផ្តល់អាហារដល់ទារក និងកុមារតូច និងការគ្រប់គ្រង និងព្យាបាលបញ្ហាកង្វះអាហារូបត្ថម្ភស្រួចស្រាវ ដែលសុទ្ធសឹងជាវិធានការយ៉ាងសំខាន់ៗដែលត្រូវធ្វើឡើងឲ្យបានលឿនបំផុតដើម្បីបង្កើនស្ថានភាពអាហារូបត្ថម្ភ។ ការវិនិយោគតូចៗលើការកសាងសមត្ថភាព និងការកៀរគរធនធានសម្រាប់កម្មវិធីជាតិអាហារូបត្ថម្ភ អាចជំរុញឲ្យមានការប្រើប្រាស់ប្រព័ន្ធសុខាភិបាលសំខាន់ ដើម្បីបង្កើនគុណភាព បរិមាណ ការអនុវត្តការងារ និងប្រសិទ្ធផលនៃការចំណាយលើផ្នែកអាហារូបត្ថម្ភដោយវិស័យសុខាភិបាល។
3. **ជំរុញការចូលរួមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (ឃុំ/សង្កាត់) ក្នុងការបង្កើនប្រសិទ្ធភាពធនធាននៅកម្រិតមូលដ្ឋាន និងបង្កើន ការយល់ដឹងរបស់សហគមន៍ស្តីពីសារៈសំខាន់នៃអាហារូបត្ថម្ភកុមារតូច។** គេអាចកែសម្រួលទិសដៅហិរញ្ញវត្ថុ និងប្រព័ន្ធថ្នាក់ក្រោមជាតិឲ្យរួមចំណែកដល់អាហារូបត្ថម្ភ ដោយប្រើប្រាស់កញ្ចប់ធនធានដែលមានស្រាប់។ សំណើបង្កើនការបែងចែកមូលនិធិឃុំ/សង្កាត់ ផ្តល់ឱកាសដល់ការបង្កើនវិសាលភាព និងគុណភាពនៃការចំណាយលើផ្នែកអាហារូបត្ថម្ភ ដែលអាចសម្រេចបានតាមរយៈ ១) ការគាំទ្ររបស់មន្ត្រីឃុំ/សង្កាត់ដល់ការគ្រប់គ្រង និងរៀបចំមូលនិធិសង្គម ២) គោលការណ៍ណែនាំច្បាស់លាស់ និងការកសាងសមត្ថភាព (បច្ចេកទេស និងការយកចិត្តទុកដាក់) ក្នុងការគ្រប់គ្រងមូលនិធិទាំងនេះនៅកម្រិតមូលដ្ឋាន និង ៣) ទំនាក់ទំនងជិតស្និទ្ធជាមួយវិស័យសុខាភិបាលដើម្បីផ្តល់ការណែនាំ និងការធានាគុណភាព និងការគាំទ្រដល់វិស័យសុខាភិបាលនៅកម្រិតសហគមន៍ និងការលើកកម្ពស់អាហារូបត្ថម្ភ។
4. **គាំទ្រការផ្លាស់ប្តូរការប្រព្រឹត្តិ និងការផ្លាស់ប្តូរក្នុងសង្គម តាមរយៈពហុយុទ្ធសាស្ត្រទំនាក់ទំនងផ្នែក និងការចូលរួមជាមួយវិស័យឯកជន។** តួនាទីរបស់រដ្ឋាភិបាលកម្ពុជាក្នុងការកែលម្អស្ថានភាពសុខភាព និងអាហារូបត្ថម្ភសម្រាប់វ័យកុមារភាពមានលើសពីការផ្តល់សេវា។ វិស័យសាធារណៈអាចវិនិយោគ

[៧៦] Keefe M ស្ថិតលើមាគ៌ាដ៏ឆាប់រហ័ស ៖ ការកាត់បន្ថយអត្រាកើតជំងឺក្រិននៅវៀតណាម ៖ ក្នុងការថែបំប៉នមនុស្សរាប់លាននាក់ ៖ រឿងរ៉ាវនៃការកែប្រែពាក់ព័ន្ធនឹងអាហារូបត្ថម្ភ។ Eds: S Gillespie, J Hodge, S Yosef, and R Pandya-Lorch. Washington, DC: IFPRI.

លើការអន្តរាគមន៍នានាដើម្បីមានឥទ្ធិពលលើបទដ្ឋានសង្គម និងផ្តល់ព័ត៌មានដែលអាចមានឥទ្ធិពលលើការសម្រេចចិត្តរបស់បុគ្គលក្នុងការផ្លាស់ប្តូរការ ប្រព្រឹត្តិយូរអង្វែង និងប្រកបដោយនិរន្តរភាព។ បទពិសោធន៍នៅប្រទេសវៀតណាម និងបង់ក្លាដេស បង្ហាញថា ការរៀបចំយុទ្ធនាការផ្សព្វផ្សាយទូទាំងប្រទេស រួមនឹងការពិគ្រោះយោបល់នៅតាមទីតាំងសុខាភិបាល និង/ឬការកៀរគរសហគមន៍ អាចជំរុញឲ្យមានការផ្តល់អាហារបន្ថែមដោយជោគជ័យ[៧៧,៧៨]។ កម្ពុជាអាចអនុវត្តវិធីសាស្រ្តស្រដៀងគ្នាទាំងនេះ ដើម្បីមានឥទ្ធិពលលើការប្រព្រឹត្តិរបស់ប្រជាពលរដ្ឋ និងធ្វើឲ្យមានការផ្លាស់ប្តូរក្នុងសង្គមយូរអង្វែងពាក់ព័ន្ធនឹងអាហារូបត្ថម្ភមាតា ទារក និងកុមារតូច និងឥរិយាបថរក្សាអនាម័យក្នុងគ្រួសារ និងអនាម័យចំណីអាហារ។ ការសម្រួលដល់ប្រតិបត្តិការរបស់តួអង្គក្នុងវិស័យឯកជន (អ្នកកែច្នៃអាហារ អ្នកផ្តល់សេវាកម្មអនាម័យ និងអ្នកផ្គត់ផ្គង់ទឹកស្អាត) អាចទាញប្រយោជន៍ពីជំនាញរបស់តួអង្គទាំងនេះ ដើម្បីបង្កើតយុទ្ធសាស្រ្តធ្វើទីផ្សារ និងកាត់បន្ថយរបាំងរារាំងអ្នកប្រើប្រាស់មិនឲ្យទទួលបានផលិតផល និងបង្កើនអត្ថប្រយោជន៍ផលិតផលដែលបានយល់ឃើញ។

5. **បង្កើនការទទួលបាន និងលទ្ធភាពទិញអាហារដែលសំបូរសារជាតិចិញ្ចឹម និងផលិតផលអាហារបំប៉ន។** វិធីសាស្រ្តសង្វាក់តម្លៃដែលផ្តោតការយកចិត្តទុកដាក់លើអាហារូបត្ថម្ភ អាចរួមចំណែកដល់ការបង្កើនការផ្គត់ផ្គង់អាហារដែលសំបូរសារជាតិចិញ្ចឹម និងការកែច្នៃអាហារដែលបង្កើនគុណតម្លៃអាហារូបត្ថម្ភរបស់ផលិតផលអាហារ។ មានកិច្ចខិតខំប្រឹងប្រែងជាច្រើនក្នុងការបង្កើនផលិតភាព និងពិពិធកម្មកសិកម្ម ធ្វើយ៉ាងណាឲ្យការវិនិយោគលើកសិកម្មផ្តោតលើការស្រាវជ្រាវធាតុចូល ការផ្សព្វផ្សាយ និងការបង្កើតទីផ្សារអាហារដែលសំបូរសារជាតិចិញ្ចឹមនៅមូលដ្ឋាន (ឧ. ផ្លែឈើ បន្លែ ប្រូតេអ៊ីនសត្វ និងគ្រាប់ធុញ្ញជាតិមិនទាន់កែច្នៃ) អាចជួយបង្កើនគុណភាពរបបអាហារនៅកម្ពុជា។ ការផ្តោតលើភាពជាដៃគូរវាងវិស័យសាធារណៈ និងវិស័យឯកជន អាចទ្រទ្រង់ដល់ក្រុមហ៊ុនផលិតផលិតផលអាហារបំប៉នដោយមានការការពារ និងជាការធ្វើអាជីវកម្ម ដើម្បីបង្កើនលទ្ធភាពទទួលបាន និងលទ្ធភាពទិញ។ កិច្ចខិតខំប្រឹងប្រែងទាំងនេះត្រូវរួមផ្សំនឹងការបង្កើនលិខិតបទដ្ឋាន និងការអនុវត្តច្បាប់តឹងរ៉ឹងចំពោះក្រុមហ៊ុនក្នុងវិស័យឯកជនដែលធ្វើទីផ្សារផលិតផល/ភេសជ្ជៈដែលប៉ះពាល់ដល់សុខភាព និងផលិតផលជំនួសទឹកដោះម្តាយ និងការជំរុញការចូលរួមរបស់វិស័យឯកជនក្នុងការគ្រប់គ្រងដោយខ្លួនឯង។

6. **ពង្រីកទំហំ និងភាពស៊ីជម្រៅនៃកិច្ចគាំពារសង្គម និងគោលនយោបាយស្តីពីការងារ ដើម្បីផ្តល់លទ្ធភាពឲ្យគ្រួសារនៅកម្ពុជាវិនិយោគលើមនុស្សជំនាន់ក្រោយ។** ការចូលរួមរបស់ស្រ្តីក្នុងកម្លាំងពលកម្មនៅកម្ពុជា មានតម្លៃជាមូលដ្ឋាន និងសំខាន់ជាគន្លឹះ ហើយត្រូវរក្សាឲ្យបាន។ របៀបវារៈគោលនយោបាយរយៈពេលមធ្យមរួមមាន ការពង្រឹងប្រព័ន្ធគាំទ្រសង្គមផ្លូវការ និងក្រៅផ្លូវការ ដែលអាចកាត់បន្ថយការលំបាករបស់ស្រ្តីក្នុងការរក្សាតុល្យភាពរវាងការងារ និងការមើលថែកូន និងបង្កើនស្ថានភាពអាហារូបត្ថម្ភ និងការអភិវឌ្ឍរបស់កុមារ។ ជម្រើសផ្សេងៗរួមមាន ៖

ក. អនុវត្តការផ្ទេរសាច់ប្រាក់សម្រាប់មាតា និងកុមារ ដើម្បីជំរុញតម្រូវការ និងលុបបំបាត់របាំងរារាំងលទ្ធភាពទទួលបានសេវាសុខភាព និងអាហារូបត្ថម្ភ និងកែលម្អការទទួលទានអាហារ។ ខណៈដែលកម្មវិធីនេះនឹងត្រូវអនុវត្តនៅពេលឆាប់ៗខាងមុខ ត្រូវយកចិត្តទុកដាក់លើ ការរក្សាសុចរិតភាព និងទំនុកចិត្តលើប្រព័ន្ធសុខាភិបាលសាធារណៈ ក្នុងការផ្តល់សេវាដែលមានគុណភាព។ ការវិនិយោគលើប្រព័ន្ធមួយ ដើម្បីផ្ទេរអត្ថប្រយោជន៍ដែលរំពឹងទុកដោយភាពងាយស្រួល មានភាពស៊ីសង្វាក់គ្នា និងតម្លាភាព អាចជួយធានាមិនឲ្យមានការខុស ទៅនឹងការសន្យា។

ខ. ពង្រីកបន្ថែម និងកែសម្រួលកិច្ចគាំពារមាតា ដើម្បីជំរុញឲ្យស្រ្តីចូលរួមចំណែកពេញលេញក្នុងកម្លាំងពលកម្ម។ ការបង្កើតជម្រើសដែលអាចអនុវត្តបានសម្រាប់ការ ពង្រីកទំហំ (ថេរវេលានៃកិច្ចគាំពារ) និងភាពស៊ីជម្រៅ (អ្នកដែលអាចក្លាយជាអ្នកទទួលផល) នៃកិច្ចគាំពារមាតា ជាលក្ខខណ្ឌចាំបាច់ដើម្បីគ្របដណ្តប់លើស្រ្តីឲ្យបាន កាន់តែច្រើន ដោយមិនគិតពីវិស័យនៃការងារ។ របបដោយមានការបង់ភាគទាន ប្រហែលជាអាចគាំទ្រដល់ការពង្រីកនេះបាន។

គ. បង្កើនការទទួលបាន និងលទ្ធភាពចំណាយលើជម្រើសថែទាំកុមារ។ ខណៈដែលច្បាប់ស្តីពីការងារចែងពីការថែទាំកុមារនៅនឹងកន្លែង ចំណុចនេះប្រហែលជាមិនអាចទៅរួច ឬមិនសមស្របក្នុងបរិបទកម្ពុជា ជាពិសេសសម្រាប់កម្មកររោងចក្រកាត់ដេរ។ ការពង្រីកគំរូនៃការថែទាំកុមារ

៧៧ Rawat R, Nguyen PH, Tran LM, Hajeebhoy N, Nguyen H Van, Baker J, Frongillo EA, Ruel MT, Menon P. ការផ្តល់សិទ្ធិធ្វើជំនួញក្នុងសង្គម និងការរៀបចំយុទ្ធនាការផ្សព្វផ្សាយទូទាំងប្រទេស បានបង្កើនប្រេវ៉ាឡង់នៃការផ្តល់អាហារបន្ថែមគ្រប់គ្រាន់នៅវៀតណាម ៖ ការវាយតម្លៃកម្រងកម្មវិធីដោយជ្រើសរើសសំណាងដោយមិនព្រាងទុកមុន J Nutr ឆ្នាំ 2017;147:670–9។

៧៨ Menon P,Nguyen PH, Saha KK,Khaled A, Sanghvi T, Baker J,Kaosar A, Haque R, Frongillo EA, RuelMT និងអ្នកនិពន្ធផ្សេងទៀត ឆ្នាំ 2016 ការរួមបញ្ចូលការពិគ្រោះយោបល់ទូលំទូលាយដោយអ្នកផ្តល់សេវាសុខាភិបាលជួរមុខ រួមជាមួយនឹងការរៀបចំយុទ្ធនាការផ្សព្វផ្សាយទូទាំងប្រទេស បានប៉ះពាល់ខ្លាំងលើការផ្តល់អាហារបន្ថែម និងការលូតលាស់របស់កុមារ ៖ លទ្ធផលនៃការវាយតម្លៃកម្រងកម្មវិធីមិនជ្រើសរើសជាមុននៅបង់ក្លាដេស, J Nutr;146(10):2075–84។

តាមសហគមន៍ និងការថែទាំកុមារក្នុងវិស័យឯកជន រួមនឹងស្តង់ដារគុណភាពរឹងមាំ និងការកសាងសមត្ថភាព អាចបង្កើនគុណភាពនៃការផ្តល់ការថែទាំដល់កុមារដែលមានម្តាយធ្វើការ។

ឃ. បង្កើតការគាំទ្រក្នុងសង្គម និងដាក់សម្ពាធឲ្យឪពុកជួយថែទាំកូន។ ដោយសារតែស្ត្រីមិនសូវមានពេលវេលាច្រើន គេអាចពង្រឹងកិច្ចខិតខំប្រឹងប្រែងបង្កើនការថែទាំ និងការផ្តល់អាហារដល់កុមារតូច តាមរយៈការចូលរួមចំណែករបស់ឪពុកក្នុងការជួយមើលថែកូន។

**7. ជំរុញឲ្យមានការវិនិយោគលើសេវាកម្មផ្គត់ផ្គង់ទឹក និងសេវាកម្មអនាម័យ ដើម្បីឲ្យប្រជាជនខ្វះខាតទទួលបានសេវាទាំងនេះ។** ដើម្បីសម្រេចបានវិសាលភាពនៃសេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជាសកលត្រឹមឆ្នាំ 2025 កម្ពុជាត្រូវការថវិកាចំនួន 211 លានដុល្លាក្នុងមួយឆ្នាំ[៧៩]។ លក្ខខណ្ឌនេះមិនអាចសម្រេចបានដោយវិស័យសាធារណៈតែឯងនោះទេ ដូច្នេះត្រូវពិចារណាពីជម្រើសនៃការទាញប្រយោជន៍ពីការផ្តល់ហិរញ្ញប្បទានដល់វិស័យឯកជន និងការវិនិយោគលើគ្រួសារ។ គួរផ្តោតសំខាន់លើការបង្កើតបរិយាកាសគ្រប់គ្រងដែលធានាបានគុណភាព និងសុវត្ថិភាពរបស់ទឹកបរិភោគ ក៏ដូចជាការពង្រឹងការគាំទ្រដល់ការបង្កើនបរិស្ថានប្រកបដោយអនាម័យក្នុងគ្រួសារ ជាពិសេសនៅតាមទីជនបទ។



(*រូបថត* ៖ Igor Dashevskiy)

[៧៩] ធនាគារពិភពលោក ឆ្នាំ 2015 ការវាយតម្លៃការផ្តល់សេវាកម្មផ្គត់ផ្គង់ទឹកស្អាត និងអនាម័យនៅកម្ពុជា ៖ ការប្រែក្លាយហិរញ្ញវត្ថុទៅជាសេវាសម្រាប់មនុស្សជំនាន់ក្រោយ។

# ឧបសម្ព័ន្ធ ១ ៖ ការប្រែប្រួលតម្លៃសម្លៀកបំពាក់ ស្បែកជើង និងអង្ករក្នុងពិភពលោក

| អ្នកនិពន្ធ | អត្ថបទ | វិធីសាស្ត្រ | ការប្រែប្រួលតម្លៃ |
|---|---|---|---|
| **អង្ករ** | | | |
| Wen S. Chern, Kimiko Ishibashi, Kiyoshi Taniguchi, Yuki Tokoyama (2002) | ការវិភាគពីឥរិយាបថប្រើប្រាស់គ្រឿងឧបភោគបរិភោគរបស់គ្រួសារជប៉ុន | Heckman | -1.8 (ជប៉ុន) |
| Erkan Erdil (2006) | ប្រព័ន្ធតម្រូវការផលិតផលកសិកម្មក្នុងបណ្តាប្រទេសសមាជិក OECD | គំរូ Rotterdam និង AIDS | -2.9 (អ៊ីតាលី)<br>-3.1 (ហូឡង់)<br>-1.5 (ន័រវែស)<br>-1.4 (ព័រទុយហ្គាល់)<br>-2.0 (ស៊ុយអែត) |
| Noel D. Uri, Jonathan D. Jones (1989) | ការប្រែប្រួលតម្លៃនៃតម្រូវការនាំចេញទំនិញកសិកម្មសហរដ្ឋអាមេរិកដែលត្រូវបានពិចារណាឡើងវិញ | មុខងារនៃការនាំចេញ | -0.6 (សហរដ្ឋអាមេរិក) |
| **សម្លៀកបំពាក់** | | | |
| Donatella Baiardi, Carlucci Bianchi, Eleonora Lorenzini (2015) | ការប្រែប្រួលតម្លៃ និងប្រាក់ចំណូលរបស់ក្រុមហ៊ុននាំចេញសម្លៀកបំពាក់ធំៗ ៖ ភស្តុតាងពីការវិភាគទិន្នន័យ | មុខងារនៃការនាំចេញ | -0.92 (ចិន)<br>-0.73 (បារាំង)<br>-0.75 (អាល្លឺម៉ង់)<br>-0.96 (ហុងកុង)<br>-0.74 (ហុងកុង)<br>-0.72 (ហូឡង់)<br>-0.87 (ចក្រភពអង់គ្លេស)<br>-1.25 (សហរដ្ឋអាមេរិក) |
| Nadezhda Ivanova (2005) | ការប៉ាន់ស្មានពីការប្រែប្រួល នៃទំនិញនាំចូល និងទំនិញក្នុងស្រុកដែលបែងចែកតាមប្រភេទនៅរុស្សី | មុខងារនៃតម្រូវការ | -1.13 (រុស្សី) |
| **ស្បែកជើង** | | | |
| Nadezhda Ivanova (2005) | ការប៉ាន់ស្មានពីការប្រែប្រួលតម្លៃនៃទំនិញនាំចូល និងទំនិញក្នុងស្រុកដែលបែងចែកតាមប្រភេទនៅរុស្សី | មុខងារនៃតម្រូវការ | -1.01 (រុស្សី) |
| Jan Kemper (2018) | ភាពខុសគ្នាផ្នែកវប្បធម៌ដែលពាក់ព័ន្ធនឹងការប្រែប្រួលតម្លៃតាមប្រព័ន្ធអនឡាញ | មុខងារនៃតម្រូវការ | -1.58 (សហភាពអឺរ៉ុប) |
| **សម្លៀកបំពាក់ និងស្បែកជើង** | | | |
| Jan Kemper (2018) | ភាពខុសគ្នាផ្នែកវប្បធម៌ដែលពាក់ព័ន្ធនឹងការប្រែប្រួលតម្លៃតាមប្រព័ន្ធអនឡាញ | មុខងារនៃតម្រូវការ | -1.07 (អូទ្រីស)<br>-0.97 (បែលហ្សិច)<br>-1.76 (បារាំង)<br>-2.74 (អាល្លឺម៉ង់)<br>-1.22 (ហូឡង់)<br>-0.48 (ស៊ុយអែត) |

# ឧបសម្ព័ន្ធ ២ ៖ សូចនាករសំខាន់ៗប្រទេសកម្ពុជា

| | 2016 | 2017e | 2018e | 2019f | 2020f | 2021f |
|---|---|---|---|---|---|---|
| **លទ្ធផល និងកំណើនសេដ្ឋកិច្ច** | | | | | | |
| ផសស ពិត (% ប្រែប្រួល ពីមួយឆ្នាំទៅមួយឆ្នាំ) | 7.0 | 7.0 | 7.5 | 7.0 | 6.9 | 6.8 |
| ការនាំចេញ GNFS[1/] | 61.3 | 60.7 | 63.3 | 63.6 | 64.9 | 65.8 |
| ការនាំចូល GNFS | 65.7 | 64.1 | 66.6 | 65.3 | 65.1 | 65.7 |
| តម្រូវការក្នុងស្រុក (% ប្រែប្រួល ឆ្នាំ) | 9.9 | 8.5 | 10.0 | 9.9 | 8.9 | 10.5 |
| ផសស សម្រាប់មនុស្សម្នាក់ៗ (US$ ណូមីណល) | 1,264.9 | 1,375.8 | 1,476.8 | 1,640.3 | 1,789.9 | 1,951.9 |
| **រូបិយវត្ថុ និងតម្លៃ** | | | | | | |
| អតិផរណា តម្លៃសម្រាប់អ្នកប្រើប្រាស់ (% ប្រចាំឆ្នាំ រយៈពេលមធ្យម) | 3.5 | 3.1 | 3.2 | 3.3 | 3.0 | 3.1 |
| M2 (% នៃ ផសស) | 70.9 | 79.4 | 88.8 | 96.0 | 103.2 | 110.4 |
| ឥណទានក្នុងស្រុកទៅវិស័យឯកជន (% នៃ ផសស) | 69.5 | 74.5 | 82.8 | 91.1 | 100.2 | 110.2 |
| អត្រាប្តូរប្រាក់ណូមីណល (រូបិយវត្ថុក្នុងស្រុកធៀបនឹងដុល្លារអាមេរិក) | 4,058.0 | 4,062.0 | 4,067.0 | 4,075.0 | 4,050.0 | 4,030.0 |
| សន្ទស្សន៍អត្រាប្តូរប្រាក់ពិត (២០១០=១០០) | 104.9 | 105.2 | 108.6 | 110.3 | 111.2 | 113.7 |
| អត្រាការប្រាក់រយៈពេលខ្លី (% ក្នុងមួយឆ្នាំ) | 11.9 | 11.7 | 11.3 | 11.0 | 11.0 | 11.0 |
| **សារពើពន្ធ** | | | | | | |
| ចំណូល (% នៃ ផសស) | 20.7 | 21.4 | 22.3 | 21.2 | 21.6 | 22.0 |
| ការចំណាយ(% នៃ ផសស) | 22.1 | 23.1 | 24.2 | 23.9 | 23.6 | 23.6 |
| សមតុល្យសារពើពន្ធសរុប(% នៃ ផសស) | -1.4 | -1.6 | -1.9 | -2.6 | -2.0 | -1.6 |
| សមតុល្យសារពើពន្ធចម្បង(% នៃ ផសស) | -1.0 | -1.2 | -1.5 | -2.1 | -1.5 | -1.1 |
| បំណុលរួមរបស់រដ្ឋាភិបាល (% នៃផសស) | 29.1 | 30.3 | 30.6 | 30.0 | 30.1 | 31.1 |
| **គណនីខាងក្រៅ** | | | | | | |
| កំណើនការនាំចេញ ទំនិញដឹកត្រឹមផែ (ណូមីណល គិតជាដុល្លារ ភាគរយប្រចាំឆ្នាំ) | 8.6 | 5.3 | 5.3 | 9.0 | 8.6 | 8.1 |
| កំណើនការនាំចូល ទំនិញដឹកដល់អ្នកទិញ (ណូមីណល គិតជាដុល្លារ ភាគរយប្រចាំឆ្នាំ) | 8.6 | 4.0 | 4.1 | 7.6 | 7.1 | 6.8 |
| ការនាំចេញទំនិញ (% នៃ ផសស) | 45.5 | 45.2 | 46.8 | 46.8 | 47.5 | 47.7 |
| ការនាំចូលទំនិញ (% នៃផសស) | 56.9 | 55.6 | 57.6 | 56.6 | 56.6 | 57.4 |
| សេវាកម្ម សុទ្ធ (% នៃ ផសស) | 7.0 | 7.0 | 7.4 | 8.1 | 9.0 | 9.9 |
| សមតុល្យគណនេយ្យចរន្ត (គិតជាលានដុល្លារ បច្ចុប្បន្ន)[2/] | -2,040.2 | -2,155.5 | -2,502.9 | -2,540.7 | -2,702.1 | -3,012.4 |
| សមតុល្យគណនេយ្យចរន្ត (% នៃ ផសស) | -10.2 | -9.7 | -10.5 | -9.5 | -9.1 | -9.2 |
| ការវិនិយោគទុនផ្ទាល់ពីបរទេស (សុទ្ធ គិតជាលានដុល្លារបច្ចុប្បន្ន) | 2,164.4 | 2,381.0 | 3,238.6 | 2,835.8 | 2,802.4 | 3,044.6 |
| ការវិនិយោគទុនផ្ទាល់ពីបរទេស លំហូរសុទ្ធ(% នៃ ផសស) | 10.8 | 10.8 | 13.4 | 10.4 | 9.3 | 9.2 |
| ប្រាក់បម្រុងរូបិយវត្ថុបរទេស សុទ្ធ(គិតជាលានដុល្លារ បច្ចុប្បន្ន) | 6,730.8 | 8,757.9 | 10,143.7 | 10,650.9 | 11,183.5 | 11,742.7 |
| (ខែរំពឹងទុកនៃការនាំចូលទំនិញ និងសេវាកម្ម) | 5.7 | 6.6 | 6.3 | 6.6 | 6.2 | 6.0 |
| ប្រាក់បម្រុងរូបិយវត្ថុបរទេស ដុល | 1.187 | 1.301 | 1.158 | 1.050 | 1.050 | 1.050 |
| សម្គាល់ ៖ ផសស ណូមីណល (គិតជាលានដុល្លារ បច្ចុប្បន្ន) | 20,019.0 | 22,109.6 | 23,720.4 | 26,749.3 | 29,619.2 | 32,753.4 |

*ប្រភព* ៖ អាជ្ញាធរកម្ពុជា មូលនិធិរូបិយវត្ថុអន្តរជាតិ និងការប៉ាន់ប្រមាណ និងការព្យាករណ៍របស់បុគ្គលិកធនាគារពិភពលោក។

*e* = ការប៉ាន់ប្រមាណ f= ការទស្សន៍ទាយ p = ការព្យាករណ៍

*1/* ទំនិញ និងសេវាកម្មដែលមិនបានគិតបញ្ចូល

*2/* មិនរួមបញ្ចូលការផ្ទេរទេ។

# ឯកសារយោង


Annual Reports (2013–18), Ministry of Agriculture, Forestry and Fisheries

Annual Reports (2016–18), National Bank of Cambodia

Balance of Payment Statistics (2018), National Bank of Cambodia

Banking Supervision Reports (2016–17), National Bank of Cambodia

Budget Law (2018), Royal Government of Cambodia

Cambodian National Accounts Statistics (2017), National Institute of Statistics, Ministry of Planning

Cambodia Tourism Statistics (2017–18), Ministry of Tourism

Cambodia Public Debt Statistical Bulletin, Volume 6, September 2018, Ministry of Economy and Finance

Cambodia Socioeconomic Surveys (2004–17), National Institute of Statistics, Ministry of Planning

Cambodia Doing Business Ranking (2018), World Bank

Cambodia Enterprise Survey (2016), World Bank

Cambodia Investment Climate Assessment (2018), World Bank

Donatella Baiardi, Carlucci Bianchi, Eleonora Lorenzini (2015): The price elasticity of export demand for US agricultural commodities reconsidered, 38, 14-30, https://doi.org/10.1016/j.asieco.2015.03.003

East Asia and Pacific Economic Update (April 2019), World Bank

Erkan Erdil (2006): Demand systems for agricultural products in OECD countries, Applied Economics Letters, 13:3, 163-169, DOI: 10.1080/13504850500393386

IMF Article IV Staff Report (2018), International Monetary Fund

Jan Kemper (2018): Cross-cultural differences in online price elasticity. http://ecis2018.eu/wp-content/uploads/2018/09/2016-doc.pdf

Logistic Performance Index (2016), World Bank

Monetary Statistic Bulletin (2018), National Bank of Cambodia

Nadezhda Ivanova (2005): Estimation of own-and cross-price elasticities of disaggregated imported and domestic goods in Russia.http://siteresources.worldbank.org/INTRANETTRADE/Resources/Topics/Accession/elasticities_NIvanova_sep2005_eng.pdf

Noel D. Uri, Jonathan D. Jones (1989): The price elasticity of export demand for US agricultural commodities reconsidered, Agricultural Systems, 28:4, 273-297, https://doi.org/10.1016/0308-521X(88)90071-6

Wen S. Chern, Kimiko Ishibashi, Kiyoshi Taniguchi, Yuki Tokoyama (2002): Analysis of food consumption behaviour by Japanese households. http://www.fao.org/3/a-ae025t.pdf

ក្រុមធនាគារពិភពលោក

**ធនាគារពិភពលោក**
ប្រចាំនៅប្រទេសកម្ពុជា
អគារ Exchange Square
ជាន់ទី 10 IBRD និងជាន់ទី 11 IFC
ផ្លូវលេខ 51-61 និងផ្លូវលេខ 102-106
សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ
ភ្នំពេញ ប្រទេសកម្ពុជា
គេហទំព័រ: www.worldbank.org/cambodia